# ជំពូក ១

## សេចក្តីផ្តើម

អ្នកត្រួតពិនិត្យត្រូវទទួលខុសត្រូវសំរាប់មួយក្រុម នតំបន់យុទ្ធនាការអង្កេត (EAs) និងត្រួតពិនិត្យដោយផ្ទាល់ដល់អ្នកចុះសំភាសន៍ដែលកំណត់តាមតំបន់អង្កេតទាំងនេះ ។ ជាមធ្យមអ្នកត្រួតពិនិត្យម្នាក់ត្រូវមានចាត់ អោយត្រួតពិនិត្យដល់អ្នកចុះសំភាសន៍ ៦នាក់ ៣ ពួក ។ អត្ថបទណែនាំសំរាប់អ្នកត្រួតពិនិត្យត្រូវមានរៀបចំឡើងដើម្បីណែនាំអ្នកក្នុងការបំពេញភារកិច្ច និងមុខងារ ។ គំរោងជាបឋមគឺ :

1. ដើម្បីផ្តល់អោយអ្នកនូវពតិមានព្រឹត្តិការណ៏គ្រប់គ្រាន់អំពីចរិតលក្ខណៈប្រតិបត្តិការអង្កេត និង

2. ដើម្បីផ្តល់នូវពតិមានចាំបាច់ និងសេចក្តីណែនាំដល់អ្នក ដើម្បីដោះស្រាយនូវបញ្ហាទាំងឡាយណាដែលអ្នកចុះសំភាសន៍មានជួបប្រទះនៅក្នុងការងាររបស់គេ ។

អត្ថបទណែនាំនេះរួមមានផ្នែកខ ( ដែលត្រូវពិភាក្សាដូចខាងក្រោម )

(1). តួនាទីរបស់អ្នកជាអ្នកត្រួតពិនិត្យ

(2). របៀបកំណត់ផ្នែកគំរូនៅភូមិ /PSU; និង

(3). របៀបជ្រើសរើសគំរូ

ថែមពីលើអត្ថបទណែនាំនេះ អ្នកក៏ត្រូវដឹងអោយបានច្បាស់លាស់នូវអត្ថបទសំរាប់អ្នកចុះសំភាសន៍ដែរ ដែលជាសារពិពណ៌នាអំពីភារកិច្ចរបស់អ្នកចុះសំភាសន៍ និងផ្តល់នូវសេចក្តីណែនាំលំអិត អំពីរបៀបអនុវត្ត យុទ្ធនាការ ។ នៅពេលប្រតិបត្តិការជាក់ស្តែង មានការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SESC) អត្ថបទណែនាំទាំង នេះនឹងជាប្រភពសំខាន់ដូចគ្នាសំរាប់អ្នកត្រួតពិនិត្យ និងអ្នកចុះសំភាសន៍ ។ ដូច្នេះអ្នកត្រូវកាន់អត្ថបទណែនាំទាំងនេះតាមជាមួយអ្នកនៅពេលអ្នកចុះយុទ្ធនាការ ។

### 1. 1 ការចាត់ចែងការងារអង្កេត

រចនាសម្ព័នមានការចាត់ចែងការងារអង្កេតត្រូវមានបង្ហាញដូចក្រោមខាងក្រោម ។ ទីប្រឹក្សាជាន់ខ្ពស់ស្ថិតិ មានមុខងារជា នាយកគំរោងរួមជាមួយនិងអ្នកជំនាញការស្ថិតិជាបុគ្គលិកគំរោង ADB ។ ពួកគេនឹងទទួលខុសត្រូវនូវគំរោងអង្កេត និងជ្រើសគំរូ ប្រព័ននិងកម្មវីធីកែច្នៃទិន្នន័យ ត្រួតពិនិត្យលើបច្ចេកទេសនៅគ្រប់ដំណាក់កាលប្រតិបត្តិការអង្កេត បណ្តុះបណ្តាលមន្ត្រីចុះយុទ្ធនាការ វិភាគលទ្ធផលអង្កេត និងរៀបចំ រាយការណ៏បញ្ចប់ ។

# រចនាសម្ព័ន្ធចាត់ចែងការងារអង្កេត




នាយកវិទ្យាស្ថានជាតិស្ថិតិមានមុខងារជានាយកអង្កេត និងនាយករង ៣នាក់មានមុខងារជាអ្នកសំរបសំរួលតាមតំបន់ ។ នាយកអង្កេតនឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងត្រួតត្រាមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងមន្ត្រីដែលចូលរួមពីមន្ត្រីផែនការខេត្រ និងមន្ត្រីបំរើអោយការអង្កេតដែលមានមុខងារ ជាអ្នកត្រួតពិនិត្យ និងអ្នកចុះសំភាសន៍ ។ ការងាររបស់អ្នកចុះសំភាសន៍ត្រូវមានត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ (អ្នកត្រួតពិនិត្យម្នាក់ត្រួតពិនិត្យ ការងាររបស់អ្នកចុះសំភាសន៍ ៦នាក់ ៣ពួក) ដែលជាអ្នកពិនិត្យផ្ទៀងផ្ទាត់ដល់បញ្ជីរសំណួរដែលមានបំពេញ រួចហើយ ។ មន្ត្រីថ្នាក់កណ្តាលនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីផែនការខេត្រ និងមន្ត្រីបំរើអោយការអង្កេតនឹងចូលរួមជាអ្នកត្រួតពិនិត្យ ។ ជោគជ័យនៃយុទ្ធនាការនឹងអាស្រ័យដោយការខិតខំប្រឹងប្រែង ជ្រើសរើសមន្ត្រី

បណ្តុះបណ្តាល និងការចាត់ចែងដល់មន្ត្រីវិជ្ជាស្ថានជាតិស្ថិតិ និងមន្ត្រីខេត្ត ។ ការចូលរួមពីមន្ត្រីខេត្តសំរាប់ការងារត្រួតពិនិត្យនិងការងារចុះសំភាសន៏មានភាពងាយស្រួលក្នុងការបង្ហាប បញ្ហាដល់អ្នកធ្វើការនៅឃុំ និងភូមិ អោយរួមសហការណ៏យ៉ាងសកម្មក្នុងការងារអង្កេត ។

# ជំពូក ២

## តួនាទីអ្នកត្រួតពិនិត្យនៃ SESC

ជំពូកនេះមានផ្តល់នូវទស្សនៈ និងគោលបំណងនៃតួនាទីរបស់អ្នកជាអ្នកត្រួតពិនិត្យក្នុងប្រតិបត្តិការ អង្កេត និងភារកិច្ចសំភាសន៍ និងការទទួលខុសត្រូវរបស់អ្នក ។ ក្នុងតំបន់នីមួយៗរបស់អ្នកដែលមានកំណត់ហើយ ជាបឋមអ្នកត្រូវមានទំនាក់ទំនងដូចខាងក្រោម

1. ត្រូវពិនិត្យអោយមានពេញលេញ និងត្រឹមត្រូវដល់ការចុះបញ្ជីគ្រួសារ និងអាគារដែលមាន លំនៅដ្ឋាន និង

2. ត្រូវពិនិត្យអោយមានពេញលេញ និងត្រឹមត្រូវដល់ការងារចុះសំភាសន៍តាមគ្រួសារទាំងអស់ ដែលមាននៅក្នុងលំនៅដ្ឋាន ។

### 2. 1 ការសំគាល់អ្នកត្រួតពិនិត្យ

អ្នកត្រួតពិនិត្យ ត្រូវមានអនុញ្ញាត្តិជាអ្នកដំណាង អោយវិជ្ជាស្ថានជាតិស្ថិតិ សំរាប់យុទ្ធនាការចុះអង្កេត SESC 96 នៅតាមតំបន់កំណត់របស់អ្នក និងជាអ្នកដឹកនាំ និងត្រួតពិនិត្យប្រតិបត្តិការអង្កេត ។ អ្នកត្រូវមានផ្តល់អត្តសញ្ញាណប័ណ្ណដែលជាភស្តុតាងនៃអាជ្ញាធរដែលមានចាត់ចែងការងារនេះ ។ ជានិច្ចកាល អ្នកគួរកាន់តាមជាមួយអ្នកនូវអត្តសញ្ញាណប័ណ្ណនេះ និងទុកសំរាប់បង្ហាញ ជាពិសេសដល់អ្នកឆ្លើយ ដើម្បីបញ្ជាក់អំពីអតសញ្ញាណ-កម្ម និងអាជ្ញាធររបស់អ្នក ។

### 2. 2 ភារកិច្ចសំភាសន៍ និងការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យ

អ្នកត្រួតពិនិត្យជាអ្នកទទួលខុសត្រូវ ដើម្បីបំពេញកិច្ចប្រតិបត្តិការអោយបានជោគជ័យ និងទាន់ពេលវេលាក្នុងតំបន់របស់គេ ជាភូមិទាំងមូលជាផ្នែកនៃភូមិធំ ។ គោលការណ៏ខាងក្រោមនេះសំរាប់អោយអ្នកត្រួតពិនិត្យទទួលខុសត្រូវនិងដោះស្រាយនូវអប្រសិទ្ធិភាព និងទង្វើខុសឆ្គងរបស់អ្នកចុះសំភាសន៍ដែលអ្នកត្រួតពិនិត្យ ។ ដើម្បីធ្វើអោយមានប្រសិទ្ធិភាពការងារ អ្នកត្រូវដឹកនាំនិងមានសមត្ថភាពបង្ហាប បញ្ហាការងារ ដើម្បីអោយទទួលបានសំរេចដល់គោលដៅនៃការអង្កេត ។ អ្នកត្រូវត្រៀមជាស្រេច ដើម្បីជួយដល់ពួកគេក្នុងការបំពេញភារកិច្ច ។ ការបង្ហាប បញ្ហាអាស្រ័យទៅលើអ្នក ក្នុងការដោះស្រាយបណ្តាបញ្ហារបស់ពួកគេពីមួយថ្ងៃទៅមួយថ្ងៃ ។ ត្រូវអនុ-វត្តិភារកិច្ចអោយមានប្រសិទ្ធិភាព ជាអ្នកត្រួតពិនិត្យម្នាក់ ព្រោះអ្នកត្រួតពិនិត្យម្នាក់នឹងត្រូវបានចាត់ចែងដល់អ្នកចុះសំភាសន៍ពី ៤នាក់ទៅ ៥នាក់ ។

ភារកិច្ចសំភាសន៍ និងការទទួលខុសត្រូវរបស់អ្នកត្រូវបានរៀបរាប់ដូចខាងក្រោម ។ បន្ថែមពីលើនេះ អ្នកត្រូវបានការទុកចិត្តក្នុងការបំពេញភារកិច្ច ដែលបានចាត់តាំងដោយអ្នកសំរបសំរួលតាមតំបន់ និងនាយកអង្កេតក្នុងទំនាក់ទំនងការងារអង្កេត ។

ក- ចូលរួមវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនចំណេះដឹងខាងទស្សនៈ អត្ថន័យនិងទំរង់បែបបទ សំរាប់ ដំណើរការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា និងកំណត់អោយបានច្បាស់លាស់នូវភារកិច្ច និង ការទទួលខុសត្រូវ ចំពោះអ្នកចុះសំភាសន៍របស់អ្នក

ខ- សំរបសំរួលជាមួយប្រធានភូមិ ដើម្បីយុទ្ធនាការក្នុងភូមិគំរូ

គ- ត្រួតពិនិត្យអោយបានជិតស្និទដល់ការងាររបស់អ្នកចុះសំភាសន៍ នៅពេលចុះបញ្ជីគ្រួសារ និងការងារចុះសំភាសន៍

ឃ- ត្រូវស្គាល់គ្រួសារគំរូដែលឆ្លើយសំណួរក្នុងទំរង់ 2 SESC ( បញ្ជីសំណួរគ្រួសារ);

ង- ត្រូវបញ្ជាក់អោយបានច្បាស់លាស់ចំពោះទំហំតំបន់របស់អ្នកចុះសំភាសន៍របស់អ្នក

ច- ត្រូវជួយដោះស្រាយបញ្ហាដែលជួបប្រទះដោយអ្នកចុះសំភាសន៍របស់អ្នក

ឆ- ត្រូវពិនិត្យពិច័យអោយបានគ្រប់ជ្រុងជ្រោយនិងអក្សរអោយបានច្បាស់ត្រឹមត្រូវដល់បញ្ជីសំណួរសំរេចដែលប្រគល់ដោយអ្នកចុះសំភាសន៍របស់លអ្នក និង

ជ- ត្រូវប្រគល់បញ្ជីសំណួរសំរេច និងសំភារៈទៅអោយអ្នកសំរបសំរួលតាមតំបន់ នាយកអង្កេតតាមរយៈពេលកំណត់ ។

## 2. 3 សេចក្តីណែនាំសំរាប់អ្នកត្រួតពិនិត្យ

### 2. 3. 1 ការចុះបញ្ជី

1. អ្នកត្រួតពិនិត្យត្រូវចាត់ចែងប្រគល់ភូមិគំរូមួយទៅអោយអ្នកចុះសំភាសន៍ម្នាក់ ដើម្បីចុះបញ្ជី ។ ភូមិគំរូទាំង ឡាយណាដែលមាន 350គ្រួសារតិចជាង ត្រូវធ្វើការចុះបញ្ជីអោយបានគ្រប់ចំនួន ។ ប៉ុន្តែបើចំនួនគ្រួសារលើស ច្រើនជាង 350 ភូមិនោះត្រូវចែកចេញជាផ្នែកដោយអ្នកត្រួតពិនិត្យ

មុននឹងអ្នកចុះសំភាសន៏ធ្វើការចុះបញ្ជី ។ សូមមើល ជំពូក 3 សំរាប់សេចក្តីណែនាំរបៀបចែកជាផ្នែក ។

2. ត្រូវដឹងអោយប្រាកដថា អ្នកចុះសំភាសន៏ធ្វើតាមសេចក្តីណែនាំដែលមាននៅក្នុងអត្ថបទណែនាំសំរាប់អ្នកចុះសំភាសន៏ ។

3. ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យនៅក្នុងតារាងចុះបញ្ជី ( ទំរង់ 1 SESC ) ។ ធ្វើអោយប្រាកដ និងទុកចិត្តថា លេខរៀងអាគារ លំនៅដ្ឋាននិងគ្រួសារ តាមលេខលំដាប់រៀងគ្នា ។ ក៏ត្រួតពិនិត្យអោយត្រឹមត្រូវ ផងដែរ នូវចំនួនសរុបសមាជិកគ្រួសារ ។

4. បន្ទាប់ពីផ្ទៀងផ្ទាត់ការងារចុះបញ្ជីដោយអ្នកចុះសំភាសន៏រួចមក ត្រូវបំពេញក្នុងបន្ទាត់ដែលមានស្រាប់ អោយបានសមស្របក្នុងពតិមានសំភាសន៏ ។

5. បំពេញលេខសំគាល់គំរូសំរាប់គ្រួសារនីមួយៗ ។ ត្រូវចងចាំថា គ្រួសារនីមួយៗមានលេខសំគាល់គំរូ តែមួយគត់ មានន័យថាគ្មាន 2 គ្រួសារ ឬច្រើនគ្រួសារ ត្រូវបានកំណត់លេខសំគាល់គំរូដូចគ្នាឡើយ ។ លេខទាំងនេះត្រូវដាក់តាមលំដាប់រៀងគ្នា ។

6. ពិនិត្យផ្ទៀងផ្ទាត់ផែនទីលំអិតដែលរៀបចំដោយអ្នកចុះសំភាសន៏ ហើយបញ្ជាក់អោយបានច្បាស់លាស់ថា ការចុះសញ្ញាចំណុចសំគាល់ត្រូវបានធ្វើដោយអ្នកចុះសំភាសន៏ ។ ប្រមូលផែនទីព្រមគ្នា ជាមួយនិងទំរង់ចុះបញ្ជី ។

### 2. 3. 2 ការណែនាំសំរាប់គ្រួសារគំរូ

1. អ្នកត្រួតពិនិត្យមានភារកិច្ចកំណត់លេខសំគាល់គំរូដល់គ្រួសារក្នុងភូមិផ្នែកគំរូ និងជ្រើសរើស គ្រួសារគំរូ ។ សូមធ្វើតាមសេចក្តីណែនាំ អំពីការជ្រើសរើសគ្រួសារគំរូក្នុង ជំពូក 4 ។

2. គូសរង្វង់ជុំវិញលេខសំគាល់គំរូរបស់គ្រួសារគំរូក្នុងទំរង់ចុះបញ្ជី ហើយប្រគល់ទំរង់ចុះបញ្ជីនោះទៅ អោយអ្នកចុះសំភាសន៏ ។

3. ណែនាំអ្នកចុះសំភាសន៏អោយគ្រប់គ្រង និងរៀបចំទំរង់ 2 SESC ( បញ្ជីសំណួរគ្រួសារ) សំរាប់ គ្រួសារណាដែលបានគូសរង្វង់ជុំវិញលេខសំគាល់គំរូតាមគ្រួសារ ។

4. តាមភូមិគំរូនីមួយៗ ត្រូវជ្រើសរើសដោយចៃដន្យនូវគ្រួសារគំរូមួយ ដើម្បីធ្វើការចុះសំភាសន៏ឡើងវិញដល់គ្រួសារនោះ ដោយប្រើបញ្ជីសំណួរដែលបានបំពេញស្រាប់ដោយអ្នកចុះសំភាសន៏ ។ បើអ្នករកឃើញនូវកំហុសណាមួយ ត្រូវកែតំរូវកំហុសដោយប្រើប៊ិចពណ៌ក្រហម ហើយយកវាទៅអោយអ្នកចុះសំភាសន៏ ដើម្បីធ្វើការកត់សំគាល់ភ្លាមៗ ។ រួចសរសេរក្នុងផ្នែកកំណត់សំគាល់នៃកំណត់ត្រាសំភាសន៏ថា （ចុះសំភាសន៏ឡើងវិញ） ។

5. ត្រួតពិនិត្យបញ្ជីសំណួរនីមួយៗ ដែលបានប្រគល់ដោយអ្នកចុះសំភាសន៏ ។ សូមចងចាំថា សេចក្តីណែនាំដែលមានក្នុងអត្ថបទណែនាំសំរាប់អ្នកចុះសំភាសន៏ ត្រូវបានប្រតិបត្តិតាមដោយត្រឹមត្រូវ ។ បើអ្នករកឃើញនូវកំហុសណាមួយ អ្នកត្រូវប្រគល់បញ្ជីសំណួរទៅអោយអ្នកចុះសំភាសន៏ ដើម្បីចាប់អារម្មណ៏ និងយកចិត្តទុកដាក់ ហើយកែតំរូវកំហុសនោះឡើងវិញ ។

6. បន្ទាប់ពីបានពិនិត្យលើបញ្ជីសំណួររួចមក ត្រូវសរសេរឈ្មោះរបស់អ្នក ចុះហត្ថលេខា និងចុះថ្ងៃខែ ឆ្នាំ ត្រួតពិនិត្យក្នុងកំណត់ត្រាសំភាសន៏ ។

# ជំពូក 3

## របៀបចែកជាផ្នែកក្នុងភូមិធំ PSU

ជំពូកនេះពិពណ៌នាទំរង់បែបបទអំពីរបៀបចែកជាផ្នែកក្នុងភូមិធំ ឬ ភូមិទាំងឡាយណាដែលមានចំនួនគ្រួសារប៉ាន់ស្មានលើសពី 350 ។

**ការពិពណ៌នានៃទំរង់បែបបទ** វាជាការទទួលខុសត្រូវរបស់អ្នក ក្នុងការបែងចែកផ្នែកក្នុងភូមិធំ PSU ភូមិដែលមានទំហំគ្រួសារ ច្រើនជាង 350 ជាពីរផ្នែក រឺច្រើនផ្នែក ។ ការបែងចែកនេះត្រូវធ្វើតាមទំរង់បែបបទដូចបានរៀបរាប់ ខាងក្រោម :

1. បន្ទាប់ពីទាក់ទងជាមួយប្រធានភូមិរួចមក ត្រូវពន្យល់ពីបំណងនៃការអង្កេត និងធ្វើយ៉ាងណាអោយគេរួមសហការណ៍ជាមួយយើង មុនដំបូង
ត្រូវធ្វើផែនទីប៉ាន់ស្មាននៃភូមិដោយបង្ហាញពីសញ្ញាចំណុចសំគាល់ជាក់ស្តែងផ្សេងៗ
ដែលអាចប្រើប្រាស់នៅពេលក្រោយ ដើម្បីជួយក្នុងការកំណត់ ទីតាំងគ្រួសារសំខាន់ៗ
ដែលត្រូវបានជ្រើសរើសសំរាប់ធ្វើការសំភាសន៏ ។ សញ្ញាសំគាល់រួមមាន ច្រកផ្លូវតូចៗ និងផ្លូវលំ ទន្លេ ស្ទឹង ឬ អូរ ផ្លូវដែក រួមទាំងទីតាំងសាលារៀន វត្ត ព្រះវិហារ សញ្ញាសំគាល់អាគារ និងសញ្ញាសំគាល់ដ៏ទៃទៀត ។

2. ដោយប្រើប្រាស់ផែនទីប៉ាន់ស្មាន បែងចែកវាជាផ្នែកតាមរបៀបដូចតទៅ

( ក ) ប្រមាណចំនួន លំនៅដ្ឋានស្មើៗគ្នា ( បើមានចំនួនច្រើនជាង 350 គ្រួសារ ) នៅក្នុងផ្នែកនីមួយៗ និង

( ខ ) កំណត់សំគាល់សញ្ញាជាក់ស្តែងអោយបានច្បាស់លាស់ដោយគូសព្រាងនូវព្រំប្រទល់នៃផ្នែកនីមួយៗ ។ សូមកត់សំគាល់នៅចំណុចនេះ ក្នុងការប្រតិបត្តិផែនទីគ្រោង គ្មានគំរោងទីតាំងនៃគ្រួសារឡើយ ដូច្នេះការកំណត់ទំហំផ្នែក បើគិតជាលំនៅដ្ឋានអាចផ្អែកទៅលើតែចំនួនលំនៅដ្ឋានប៉ាន់ស្មានតែ ប៉ុណ្ណោះ ។ សូមកត់សំគាល់ថា ការសន្មតលំនៅដ្ឋានមួយមានលក្ខណៈប្លែកគ្នាពីគ្រួសារមួយ មាន- ន័យថា លំនៅដ្ឋានមួយអាចមានច្រើនលើសពីមួយគ្រួសារ ។ ក្នុងករណីណាក៏ដោយការរាប់ចំនួន លំនៅដ្ឋានមិនទាន់បានត្រឹមត្រូវ រឺមានការខ្វះខាតនៅឡើយ សំរាប់គោលបំណងនៃការបែងចែក ផែនទីជាផ្នែក ។

3. ក្រោយពីផ្នែកត្រូវបានរៀបចំនៅលើផែនទីប៉ាន់ស្មានរួចហើយ ត្រូវចុះលេខតាមផ្នែក ហើយជ្រើសរើសផ្នែកណាមួយដោយចៃដន្យ ។ ត្រូវធ្វើតាមសេចក្តីណែនាំក្នុងការជ្រើសរើសផ្នែកគំរូដូចខាងក្រោមនេះ :

ក- រៀបចំសន្លឹកក្រដាសដែលមានទំហំដូចគ្នា

ខ- សរសេរលេខរបស់ផ្នែក មួយលេខចុះក្នុងមួយសន្លឹក

គ- មូរសន្លឹកក្រដាសមួយរមូរ

ឃ- ដាក់សន្លឹកក្រដាសរមូរក្នុងប្រអប់មួយ

ង- ក្រឡុកប្រអប់ហើយបន្ទាប់មកលូកចាប់សន្លឹកមូរមួយ

ច- កត់ចំណាំលេខដែលមានសរសេរនៅលើសន្លឹករមូរស្រាប់ ។ លេខនេះជាផ្នែកគំរូរបស់អ្នកដែលអ្នកសំភាសន៍របស់អ្នកត្រូវចុះយុទ្ធនាការអង្កេត ។

4. រក្សាកំណត់ត្រានូវចំនួនប៉ាន់ស្មានគ្រួសារមុន ( ក្នុងភូមិគំរូ PSU ទាំងមូល) និងចំនួនជាក់ស្តែង (ក្នុងតែផ្នែកដែលត្រូវបានជ្រើសរើស) ។ នេះជាការងារសំខាន់នៅពេលដែលចំនួនលេខទាំងពីរត្រូវបានប្រើប្រាស់សំរាប់ដំណាក់កាលវិភាគ ដើម្បីធ្វើការប៉ាន់ស្មានអង្កេត ។

## ជំពូក 4

## របៀបជ្រើសរើសគ្រួសារគំរូ

### 4. 1 ការពិពណ៌នាទូទៅនៃទំរង់បែបបទជ្រើសរើស

វាជាការទទួលខុសត្រូវរបស់អ្នក ដើម្បីសំគាល់នូវគ្រួសារគំរូដែលនឹងឆ្លើយនូវសំណួរក្នុងទំរង់ 2 នៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SESC Form No.2) បញ្ជីសំណួរលំអិតអំពីលក្ខណៈប្រជាសាស្ត្រ និងសេដ្ឋកិច្ចនៃសមាជិកគ្រួសារ និង គ្រួសារ និងលំនៅដ្ឋានជាពិសេស ។ នៅពេលដែលចុះបញ្ជីគ្រួសារក្នុងភូមិគំរូ PSU ត្រូវបានបញ្ចប់អ្នកត្រូវកំណត់តាមលំដាប់លំដោយ ដល់គ្រួសារនីមួយៗក្នុងបញ្ជីនូវលេខសំគាល់គំរូ ដែលត្រូវកត់បញ្ចូលក្នុងបង្គោលមានដាក់ឈ្មោះ លេខសំគាល់ គំរូ (បង្គោល10) ។ លេខសំគាល់គំរូមានលេខបួនខាងដែលចាប់ផ្តើមពី 0001 សំរាប់គ្រួសារទីមួយក្នុងបញ្ជី **0002** សំរាប់គ្រួសារបន្ទាប់ ។ និងធ្វើរបៀបដូចគ្នាជាបន្តបន្ទាប់រហូតដល់គ្រប់គ្រួសារទាំងអស់ដែលត្រូវបានកំណត់លេខ ។ អ្នកត្រូវធ្វើអោយច្បាស់ថា លេខត្រូវបានកំណត់តាមលំដាប់លំដោយ ហើយគ្មានលេខណាមួយត្រូវភ្លេចខុស ឡើយ ។ ម្យ៉ាងទៀត វាក៏ត្រូវបញ្ជាក់អោយច្បាស់ដែរថា គ្រួសារត្រូវបានកំណត់លេខសំគាល់គំរូតែមួយ្ស មាន ន័យថា គ្មានពីរគ្រួសារីច្រើនគ្រួសារ ត្រូវបានកំណត់លេខសំគាល់គំរូដូចគ្នាឡើយ ។

នៅពេលដែលការកំណត់លេខសំគាល់គំរូត្រូវបានធ្វើរួចហើយ អ្នកត្រូវត្រៀមជាស្រេច ដើម្បីបន្តការជ្រើសរើសគ្រួសារគំរូ ។ ដំណាក់កាលបន្តបន្ទាប់នឹងណែនាំអ្នកក្នុងការជ្រើសរើសគំរូអោយបានល្អប្រសើរ

1. ការកំណត់ចន្លោះគន្លាតគំរូ ។

2. ការជ្រើសរើសគ្រួសារគំរូពីបញ្ជីគ្រួសារក្នុងទំរង់ 1 SESC ដោយប្រើការកំណត់ចាប់ផ្តើមដំបូង ដោយចៃដន្យសំរាប់ភូមិគំរូ /PSU នីមួយៗ ។

### 4. 2 សេចក្តីណែនាំលំអិត

#### 1. ការកំណត់ចន្លោះគន្លាតគំរូ ( F )

ប្រើចំនួនគ្រួសារជាក់ស្តែង N* ដែលត្រូវបានកំណត់ពីការប្រតិបត្តិចុះបញ្ជី ហើយគណនាចន្លោះគន្លាតគំរូ ដែលស្មើ N* ចែកនឹង 10 រឺ 20 ដែលជាករណីអាចយកបាន នោះគឺ **F = N*/10** ក្នុងនោះ N* : ចំនួនគ្រួសារជាក់ស្តែងដែលបានចុះបញ្ជីក្នុងភូមិ /PSU

ត្រូវយកលេខគត់នៅមុខក្បៀស បើ F គ្មានលេខគត់ ។ សូមកត់សំគាល់ថា ជាចំនួនត្រូវប្រើចំនួនគ្រួសារជាក់ស្តែងជំនួសអោយចំនួនគ្រួសារប៉ាន់ស្មានមុន ដើម្បីធ្វើអោយប្រាកដថា មាន 10 រឺ 20 គ្រួសារនឹងត្រូវបានជ្រើសរើស ។ ឧទាហរណ៍ :ភូមិជនបទ 07 , គោកទំនាប់ ស្រុក 02 ក្នុងខែត្របន្ទាយមានជ័យ ។ ចំនួនគ្រួសារ ប៉ាន់ស្មាននៅក្នុងភូមិនេះមាន 136 ។ ឧបមាថា ការប្រតិបត្តិចុះបញ្ជីបានបង្ហាញចំនួនជាក់ស្តែងរហូតដល់ 162 គ្រួសារ ។ ដូច្នេះ N* = 162 ។ ដើម្បីរកចន្លោះគន្លាតគំរូ F ត្រូវស្មើនឹង 162 ចែកនឹង 10 ( សំរាប់ បន្ទាយ មានជ័យ 10 គ្រួសារគំរូនឹងត្រូវបានជ្រើសរើសពីភូមិនីមួយៗ ) ,រឺ 16.2 ។ បើលទ្ធផលរបស់ F គ្មានលេខ គត់ នោះត្រូវយកចំនួននៅមុខក្បៀស ។ ដូច្នេះចន្លោះគន្លាតគំរូចុងក្រោយគឺ ស្មើនឹង 16 ។

| |
|---|
| F = 16 |

**2.** វិធីជ្រើសរើសគ្រួសារគំរូពីបញ្ជីគ្រួសារក្នុងទំរង់ 1 SESC ដោយប្រើការកំណត់ចាប់ផ្តើមដំបូងដោយចៃដន្យ ។

**ករណីទី 1 ៈចំនួនគ្រួសារជាក់ស្តែងប្រហាក់ប្រហែលទៅនឹងចំនួនគ្រួសារប៉ាន់ស្មានមុន ក្នុងភូមិគំរូ /PSU ( N=N*)**

ក- កំណត់លេខចាប់ផ្តើមដំបូងដោយចៃដន្យក្នុងភូមិ /PSU ត្រូវយោងទៅតាមសេចក្តីបន្ថែម A ។ សូមកត់សំគាល់ថា ការចាប់ផ្តើមដំបូងដោយចៃដន្យសំរាប់ភូមិនីមួយៗ ត្រូវបានបង្កើតឡើងតាមរយៈការប្រើប្រាស់កម្មវិធីកុំព្យូទ័រ ។

ខ- កំណត់គ្រួសារគំរូទីមួយដោយប្រើប្រាស់ការចាប់ផ្តើមដំបូងដោយចៃដន្យដែលមានបញ្ជាក់ក្នុងសេចក្តីបន្ថែម A ។ ដូច្នេះ គ្រួសារគំរូទីមួយ ជាគ្រួសារដែលមានលេខសំគាល់គំរូរបស់វា ( បង្គោល 10 នៃទំរង់ 1 SESC តារាងចុះបញ្ជី ) ស្មើនឹងការចាប់ផ្តើមដំបូងដោយចៃដន្យ ។ ការពន្យល់សំរាប់ឧទាហណើខាងលើ គឺភូមិជនបទ 07 គោកទំនាប់ ស្រុក 02 ក្នុងខែត្រ បន្ទាយមានជ័យ ។ ផ្អែកតាមសេចក្តីបន្ថែម A ការចាប់ផ្តើមដំបូងដោយចៃដន្យសំរាប់ភូមិនេះត្រូវស្មើនឹង 9 ហើយចន្លោះគន្លាតគំរូស្មើនឹង 16 (មើលក្នុងឧទាហរណ៍នៅដំណាក់កាល 1) ។ ដូច្នេះ គ្រួសារគំរូទីមួយ ជាគ្រួសារដែលមានលេខសំគាល់គំរូរបស់វាស្មើនឹង 9 ។

| |
|---|
| R = 9 = លេខសំគាល់គំរូ (SRU) របស់គ្រួសារគំរូទី 1 |

គ- កំណត់គ្រួសារគំរូបន្ទាប់ ដោយបូកចន្លោះគន្លាតគំរូ F ទៅនឹងលេខសំគាល់គំរូរបស់គ្រួសារដែលបានជ្រើសរើសមុន ។ ផលបូកនឹងបង្ហាញនូវលេខសំគាល់គំរូរបស់គ្រួសារគំរូបន្ទាប់ ។

ការពន្យល់សំរាប់ឧទាហរណ៍ខាងលើ អ្នកបានដឹងថា លេខសំគាល់គំរូ ( SRN ) = 9 ( លេខសំគាល់គំរូរបស់គ្រួសារគំរូទី 1) និង F = 16 ។ ដើម្បីកំណត់គ្រួសារគំរូបន្ទាប់ប៉ុ គឺគ្រាន់តែបូកបន្ថែមចំនួនចន្លោះ គំន្លាតគំរូ F = 16 ទៅនឹងលេខសំគាល់គំរូនៃគ្រួសារមុនដែលបានជ្រើសរើសហើយ SRN = 9 ។ ដូច្នេះ 9 + 16 = 25 ។ នេះមានន័យថា គ្រួសារដែលមានលេខសំគាល់គំរូរបស់វា ស្មើនឹង 25 គឺជាគ្រួសារគំរូបន្ទាប់ ។ ដើម្បីបន្តការណែនាំខាងក្រោមនេះ ជាលេខគំរូរបស់ 10 គ្រួសារគំរូក្នុងភូមិជនបទនៃគោកទំនាប់ 07, ស្រុក 02 ខែត្របន្ទាយមានជ័យ ។

9 --------------------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 1

9 + 16 = 25 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 2

25 + 16 = 41 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 3

41 + 16 = 57 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 4

57 + 16 = 73 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 5

73 + 16 = 89 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 6

89 + 16 = 105 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 7

105 + 16 = 121 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 8

121 + 16 = 137 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 9

137 + 16 = 153 ---- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 10

ឃ- ធ្វើដូចគ្នាដដែល១រហូតដល់គ្រប់ចំនួនគ្រួសារគំរូដែលត្រូវជ្រើសរើស ។

ង- បើផលបូករបស់លេខសំគាល់គំរូមុនជាមួយនឹងចន្លោះគន្លាតគំរូច្រើនជាងចំនួនសរុបគ្រួសារដែលបានចុះបញ្ជីក្នុងភូមិ /PSU, នោះត្រូវដកចេញពីផលបូកនូវចំនួនសរុបនៃគ្រួសារ ។

លេខសំគាល់គំរូរបស់គ្រួសារគំរូ ត្រូវបានផ្តល់អោយខុសៗគ្នា ។ ធ្វើតៗគ្នាដូចខាងលើរហូតដល់អស់ចំនួនគ្រួសារគំរូដែលចង់បាន។ ឧទាហរណ៍ :បើភូមិ 10 ( អូរស្វាយ ), ស្រុក 02 ខែត្របន្ទាយមានជ័យ ។ ផ្អែកលើសេចក្តីបន្ថែម A, ចំនួនគ្រួសារប៉ាន់ស្មានគឺ 89 ហើយការចាប់ផ្តើមដំបូងដោយចៃដន្យតាមកុំព្យូទ័រ, R = 9 ។ មាន 10 គ្រួសារគំរូ ត្រូវបានជ្រើសរើសក្នុងភូមិនេះ ដូច្នេះ F = 89/10 = 8.9 ។ បន្ទាប់មកយើងប្រើប្រាស់ពតិមាន R = 9 និង F = 9, នោះចំនួនសំគាល់គំរូរបស់គ្រួសារគំរូមានបង្ហាញ ដូចខាងក្រោម:

9 ---------------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 1

9 + 9 = 18 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 2

18 + 9 = 27 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 3

27 + 9 = 36 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 4

36 + 9 = 45 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 5

45 + 9 = 54 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 6

54 + 9 = 63 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 7

63 + 9 = 72 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 8

72 + 9 = 81 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 9

81 + 9 = 90 ------- លេខសំគាល់គំរូរបស់គ្រួសារគំរូទី 10

សូមកត់សំគាល់ថា លេខសំគាល់គំរូ ( SRN ) ចុងក្រោយរឺគ្រួសារគំរូទី 10 មានចំនួនច្រើនជាងរឺលើសចំនួនគ្រួសារប៉ាន់ស្មានក្នុងភូមិដែលមានតែ 89 ។ ក្នុងករណីនេះ អ្នកត្រូវយក 89 ដកពី 90 ដើម្បីរកលេខសំគាល់គំរូ ( SRN ) របស់គ្រួសារគំរូទី 10 នោះគឺ 90 - 89 = 1 ។ ដូច្នេះ លេខសំគាល់គំរូ របស់គ្រួសារគំរូទី 10 គឺ 1 ។

ច- ត្រូវគូសរង្វង់ជុំវិញលេខសំគាល់គំរូ ( បង្គោល 10 ) របស់គ្រួសារដែលត្រូវបានជ្រើសរើសក្នុងទំរង់ 1 SESC ( តារាងចុះបញ្ជី ធ ។

**ករណី 2 : ចំនួនគ្រួសារជាក់ស្តែងខុសគ្នាពីចំនួនគ្រួសារប៉ាន់ស្មានមុនក្នុងភូមិគំរូ ( $N \neq N^*$ ):**

ក- កំណត់ការចាប់ផ្តើមដំបូងដោយចៃដន្យថ្មី ដោយប្រើតាមរូបមន្តដូចខាងក្រោម :

$$\text{លេខចាប់ផ្តើមដំបូងដោយចៃដន្យថ្មី } ( R^* ) = \frac{( R ) \times ( N^* )}{N}$$

ក្នុងនោះ R* = លេខចាប់ផ្តើមដំបូងដោយចៃដន្យថ្មី R = លេខចាប់ផ្តើមដំបូងដោយចៃដន្យតាមកម្មវិធីកុំព្យូទ័រ N* = ចំនួនគ្រួសារជាក់ស្តែង N = ចំនួនគ្រួសារប៉ាន់ស្មាន

ឧទាហរណ៍ ភូមិជនបទ 07, គោកទំនាប់ ស្រុក 02 ក្នុងខេត្របន្ទាយមានជ័យ ។ ចំនួនគ្រួសារមានស្មានក្នុងភូមិនេះគឺ 136 ។ ឧបមាថា ការប្រតិបត្តិចុះបញ្ជីបានបង្ហាញអោយចំនួនជាក់ស្តែង រហូតដល់ 162 គ្រួសារ ។ ដូច្នេះ N* = 162 ។ ការចាប់ផ្តើមដំបូងដោយចៃដន្យR សំរាប់ភូមិនេះគឺ 9 ។ ដូច្នេះការចាប់ផ្តើមដំបូងដោយចៃដន្យថ្មី R* ស្មើនឹង :

$R^* = (9 \times 162 ) / 136 = 10.72 \approx 11$

សូមកត់សំគាល់ថា លេខចាប់ផ្តើមដំបូងដោយចៃដន្យថ្មី R* = 11 ត្រូវបានប្រើប្រាស់ជំនួសអោយ 9 ដែលជាលេខចាប់ផ្តើមដំបូងដោយចៃដន្យមុន ក្នុងការកំណត់គ្រួសារគំរូ ។

ខ- ជំហាន ខ រហូតដល់ ច ដូចគ្នានឹងករណី 1 ។

# ជំពូក ១
## សេចក្តីណែនាំ

ជំពូកនេះណែនាំអំពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ក្នុងឆ្នាំ ១៩៩៦ ហើយនឹងពន្យល់អំពីគោលបំណងរបស់វា។ ការអង្កេតនេះក៏ពិភាក្សាអំពីទ្រង់ទ្រាយសំខាន់នៃការអង្កេត ដោយមានដែនកំនត់ទំហំប្លង់គំរូ និងទំហំ នៃគំរូនោះ។

### 1.1 ទស្សនះទូទៅនៃការអង្កេត

ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា(SESC) ឆ្នាំ ១៩៩៦ ធ្វើការអង្កេតទៅលើគ្រួសារជា ច្រើននៅក្នុងប្រទេសកម្ពុជាដែលធ្វើឡើងដោយវិទ្យាស្ថានស្ថិតិជាតិ (NIS) នៃក្រសួងផែនការដែលត្រូវផ្តល់ជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សហប្រតិបត្តិការជាមួយ UNICEF, UNDP/CARERE និង ILO ការអង្កេតនេះជាអនុក្រម ទីពីរ ហើយ SESC ទីមួយត្រូវធ្វើចាប់ពីដើមខែ តុលា ឆ្នាំ ១៩៩៣ ដល់ ខែ កញ្ញា ឆ្នាំ ១៩៩៤ ត្រូវផ្តល់មូលនិធិដោយ UNDP និង ADB ។ ការអង្កេតរបស់ SESCក្នុងឆ្នាំ ១៩៩៦ ធ្វើចាប់ពីខែឧសភាដល់មិថុនា ហើយលើកទីពីរ ចាប់ពីខែវិច្ឆិការដល់ធ្នូ។ ការអង្កេតនេះនឹងចុះក្នុងបញ្ជី កត់ត្រាពីលក្ខណះរបស់មនុស្ស ម្នាក់ៗនៅ ក្នុងផ្ទះសំបែង ជាគំរូ។ ការអង្កេតនេះនិងប្រមូលទិន្នន័យតាមរយះចរិកលក្ខណះប្រជារាស្ត្រ សង្គម និង សេដ្ឋកិច្ចនៃចំនួន ប្រជាជននិងផ្ទះសំបែង។ ពតិមានដែលប្រមូលបាននឹងមានសារះសំខានលចំពោះការរៀបចំគំរោង និងកម្មវិធីដែល សមហេតុផលសំរាប់ប្រទេស។

### 1.2 គោលបំណងរបស់ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ក្នុងឆ្នាំ ១៩៩៦

#### គោលបំណងទូទៅ

គោលបំណងសំខាន់បេស់SESCដើម្បីពតិមានដែលត្រូវការចំបាច់សំរាប់កម្មវិធីស្ថាបនានិងបុនទីសម្បទា។

ទិន្នន័យដែលមាននិង មានតួនាទី ដ៏សំខាន់ក្នុងការរៀបចំផែនការសេដ្ឋកិច្ចសង្គមកិច្ច ការវិភាគច្រើនផ្នែក និងការប៉ាន់ស្មានសំរាប់គណនេយ្យជាតិ។

#### គោលបំណងជាក់លាក់

ការអង្កេតនេះមានគោលបំណងដើម្បី :

1. ប្រមូលទិន្នន័យតាមរយះអត្រាប្រជាជននិងសង្គមដូចជា អាយុ ភេទ ស្ថានភាពអាពាហ៏ ការចេះ អាននិងសរសេរ ការអប់រំ អន្តោប្រវេសន៏ និង ពិការភាព ។
2. ទាញយកពតិមានពីសម្មភាពការងារ និង សេដ្ឋកិច្ច ផ្ទះសំបែង ។
3. អាចបានពតិមានទាក់ទងនឹងចំណីអាហារ សុខភាពរបស់កូននិងម្តាយ ។
4. មានទិន្នន័យចំពោះការងារកុមារ
5. អាចទទួលពតិមានចំពោះសេវាកម្មជាមូលដ្ឋាន ការកាន់កាប់ដី ឥណទាន លក្ខណះផ្សេង១ទៀត ។
6. ប្រមូលទិន្នន័យតាមផ្ទះ ។

## 1.3 ភាពទុកចិត្តទៅលើពតិមាន

ពតិមានដែលបានមកពីការអង្កេតនេះគឺគួរអោយទុកចិត្តបាន ហើយនឹងត្រូវប្រើសំរាប់តែការវិភាគតាម ស្ថិតិតែប៉ណ្ណោះ ។ សំរាប់ពតិមានដែលបានចែកចាយ នឹងមិនត្រូវប្រើដើម្បីប្រឆាំងពន្ធដា ការអង្កេត រឺក៏រឿង ស្រប ច្បប់ផ្សេង១ទៀត ។

## 1.4 ដែនកំនត់និងទំហំនៃការអង្កេត

ដែនកំនត់របស់ការអង្កេតនេះមានទំហំទូលំទូលាយល្មមដើម្បីប្រមូលទិន្នន័យ អោយបានសមស្រមទៅ តាមគោលបំណងនៃការអង្កេតត្រូវបានរៀបចំពីដើម ។ គំរូថ្នាក់ជាតិចេញពីផ្ទះចំនួន ៩000 សំរាប់ ២ វគ្គដែល អាចចាត់ទុកថាមានលក្ខណះ គ្រប់គ្រាន់សំរាប់ផ្តល់នូវការបានប៉ាន់ស្មានដែលគួរអោយទុកចិត្តនៅកំរិតមួយ ។

ការអង្កេតនេះនឹងធ្វើឡើងទាំងក្នុងទីក្រុងនិងជនបទក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយក៏ការ អង្កេតនេះត្រូវមានកំរិតដែរពីព្រោះតែបញ្ហាសន្តិសុខនៅក្នុងតំបន់មួយចំនួនក្នុងប្រទេស ។ ដូច្នេះការអង្កេតនេះត្រូវ ធ្វើឡើងតែ ២១ ខេត្តក្នុងចំណោមខេត្តទាំង ២៤ប៉ុណ្ណោះ ។ ខេត្តព្រះវិហានិងឧត្តមានជ័យ មិនត្រូវ បានរាប់បញ្ចូល នោះទេ ។ លើសពីនេះទៅទៀត មានស្រុក ឃុំ រឺ

ភូមិមួយចំនួនមិនត្រូវបានចុះ ធ្វើការអង្កេតទេ ដូចហេតុបាន លើកពីខាងលើ។ ចំនួនភូមិដែលមិនបានដាក់បញ្ចូលនៅក្នុងខេត្តបង្ហាញក្នុងតារាងទី១។

សំរាប់កាអង្កេតនេះរួមមានខេត្ត : បន្ទាយមាជ័យ បាត់ដំបង កំពង់ធំ ពោធិសាត់ រតនគីរី សៀមរាប ស្វាយរៀង ភ្នំពេញ ហើយនិងទីក្រុងផ្សេងៗទៀត រួមបញ្ចូលទាំងទីរួមខេត្ត បន្ទាយមាជ័យ បាត់ដំបង កំពង់ធំ ពោធិសាត់ រតនគីរី សៀមរាប ស្វាយរៀងស ហើយនៅតាមជនបទផ្សេងទៀតនឹងបែងចែកទៅជា១០កម្មសិទ្ធិ រី វិស័យ។ នៅក្នុងតំបន់ជនបទផ្សេងទៀតចាត់ជាពីរថ្នាក់ ជាមួយខេត្តកោះកុង មណ្ឌលគីរី ស្ទឹងត្រែងជាថ្នាក់រង ទីមួយហើយភូមិដែលសល់ដូចជានៅខេត្តកំពង់ចាម កំពង់ស្ពឺ កំពត ក្រចេះ ព្រៃវែង និង តាកែវជាថ្នាក់រងទី២។

**តារាង 1. តារាងនៃភូមិដែលមិនបានដាក់ចូលក្នុងទំហំនៃការអង្កេតនេះ**

| ខេត្ត | ចំនួនភូមិដែលមិនដាក់បញ្ចូលក្នុងទំហំនៃការអង្កេត | | |
|---|---|---|---|
| | ទីក្រុង | ជនបទ | សរុប |
| 1. បន្ទាយមានជ័យ | 18 | 105 | 123 |
| 2. បាត់ដំបង | - | 100 | 100 |
| 3. កំពង់ចាម | - | 131 | 131 |
| 4. កំពង់ឆ្នាំង | - | 92 | 92 |
| 5. កំពង់ស្ពឺ | - | 429 | 429 |
| 6. កំពង់ធំ | - | 99 | 99 |
| 7. កំពត | - | 58 | 58 |
| 8. កណ្ដាល | - | 7 | 7 |
| 9. កោះកុង | - | 21 | 21 |
| 10. ក្រចេះ | 3 | 26 | 29 |
| 11. ព្រះវិហារ * | 27 | 170 | 197 |
| 12. ពោសាធិ | 4 | 118 | 122 |
| 13. សៀមរាប | - | 90 | 90 |
| 14. ស្ទឹងត្រែង | - | 3 | 3 |

| | | | |
|---|---|---|---|
| 15. ស្វាយរៀង | - | 27 | 27 |
| 16. តាកែវ | - | 29 | 29 |
| 17. ឧត្តមានជ័យ * | 21 | 67 | 88 |
| សរុប | 73 | 1572 | 1645 |

សញ្ញា * សំគាល់ថាខេត្តមិនត្រូវបានដាក់បបញ្ចូលក្នុងទំហំនៃការអង្កេតពីគំរោងទាំងស្រុង ។

ការអង្កេត នេះត្រូវធ្វើឡើងលើផ្ទះឯកជនទាំងអស់បញ្ចូលទាំងផ្ទះមនុស្សម្នាក់នៅក្នុងគំរូគំរងនោះ ។ ចំពោះអ្នកដែលរស់ នៅ ក្នុងផ្ទះស្ថាប័នផ្សេងមិនបានដាក់បញ្ចូលក្នុងការអង្កេតនេះទេ ។

ទំហំនៃការអង្កេតនេះផ្តលពតិមានដូចខាងក្រោមៈ

### 1.4.1 **ចរិកលក្ខណៈរបស់ប្រជាពលរដ្ឋនៅក្នុងផ្ទះ**

a) ទំនាក់ទំនងមេគ្រួសារ

b) អាយុ

c) ភេទ

d) ស្ថានភាពអាពាហ៏ពិពាហ៏

e) ពិការភាព

f) សាលារៀនក្នុងពេលបច្ចុប្បន្ន

g) បានការខ្ពស់បំផុត

h) អក្ខរភាព

i) ការអន្តោប្រវេសន៏

### 1.4.2 លក្ខណៈសេដ្ឋកិច្ចនៃគ្រួសារក្នុងរយះពេល៥ឆ្នាំ និងលើសពី៥ឆ្នាំ

a) សកម្មភាពសមញ្ញនៅក្នុងរយះពេល១២ខែមុន

b) សកម្មភាពថ្មីកាលពីសប្តាហ៏មុន (រួមបញ្ចូលទាំងចំនួនម៉ោងធ្វើការផងដែរ)

c) មនុស្សដែលស្វែងរកការងារបន្ថែម

d) ប្រភេទ និង ឋានះនៃការងារ ហើយនិងប្រភេទឧស្សាហកម្មក្នុងការងារដំបូង

e) ប្រភេទ និង ឋានះនៃការងារ ហើយនិងប្រភេទឧស្សាហកម្មក្នុងការងារបន្ទាប់

f) ប្រាក់ចំណូលបានមកពីការងារដំបូងនិងការងារបន្ទាប់ ហើយនិងវិក័យប័ត្រជាប្រាក់សុទ្ធ

g) ហេតុផលសំរាប់ការមិនអាចធ្វើការបាន

### 1.4.3 ការងាររបស់កុមារ

a) ការសិក្សានៅសាលាក្នុងសប្តាហ៏មុន

b) មូលហេតុបណ្តាលអោយបោះបង់ការសិក្សា

c) ហេតុផលសំខាន់ក្នុងការមានការងារធ្វើ

d) អាយុក្មេងដែលបានចាប់ផ្តើមធ្វើការងារ

e) ទីកន្លែងធ្វើការ

f) សមាមាត្រចំណូលរបស់កុមារដែលត្រូវផ្តល់អោយក្រុមគ្រួសារ

g) ជំងឺ របួស និងបញ្ហាសុខភាពរបស់កុមារដែលកំពុងធ្វើការងារ

h) ការជ្រើសរើសកុមារអោយទៅធ្វើការងារនៅកន្លែងផ្សេងទៀត

### 1.4.4 សុខភាព និង ចំណីអាហាររបស់កុមារនិងម្តាយ

a) កាចាក់វ៉ាក់សាំង ការពារតេតាណូសពេលមានផ្ទៃពោះ

b) ការបំបៅដោះកូន

c) ប្រព័ន្ធភាពស៊ាំរបស់កុមារ

d) ការការពារជំងឺរាគរូស

e) ការផ្តល់វិតាមីន A

f) ការវាស់វែងទំងន់ កំពស់ និងដៃ

g) ចំនួននិងប្រភពនៃការចាក់ថ្នាំដែលបានទទួល

h) អំបិលអ៊ីយ៉ូត

i) ប្រតិបត្តិការទាក់ទងនិងសុខភាពផ្សេងៗទៀត

**1.4.5** ផ្ទះសំបែង

a) ប្រភេទអាគារនិងអាយុកាលរបស់វា

b) ប្រភេទសំភារៈដែលសាងសង់ដំបូល ជញ្ជាំងខាងក្រៅនិងកំរាលឥដ្ឋ

c) ចំនួនបន្ទប់នៅក្នុងផ្ទះ និងការរៀកំរាលឥដ្ឋសរុប

d) ស្ថានភាពរបស់ផ្ទះនីមួយៗ

e) សំរាប់ជួល

f) ប្រភពសំខាន់ៗនៃការប្រើប្រាស់ទឹក ការបោកអ៊ុតដោយម៉ាស៊ីនឹការបោកអ៊ុតដោយដៃ

g) ការប្រើប្រាស់បង្គន់

h) ប្រភេទនៃការប្រើប្រាស់ភ្លើង

i) ប្រភេទឥន្ទនះប្រើប្រាស់សំរាប់ចំអិនអាហារ

j) សំភារះ គ្រឿងសង្ហារឹមដែលមាននៅក្នុងផ្ទះ

k) អាចទទួលបានសេវាកម្មដូចជា សាលា គ្លីនិក មន្ទីពេទ្យ និងផ្លូវផ្ទល់

l) ការកាន់កាប់ដី (ទំហំដី)

m) សកម្មភាពសេដ្ឋកិច្ចនៅខាងក្រៅផ្ទះ

n) ការចំណាយតាមផ្ទះ

o) លក្ខណះឥណទានរបស់សមាជិកគ្រួសារ

p) គ្រោះថ្នាក់ចរាចរណ៍

### 1.5 គំរូនៃគំរោង

SESC ប្រើប្រាស់គំរូប្រូបាបបីលីតេចំនួនពីរដំណាក់កាលនៅក្នុងតំបន់ដែលត្រូវវិភាគដូចជា : បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ ពោធិសាត់ រតនះគីរី សៀមរាប ស្វាយរៀង ភ្នំពេញ តំបន់ទីប្រជុំជន និង ជនបទ ផ្សេង ៧ទៀត ។

សំរាប់វគ្គនៃការអង្កេតនេះ ការជ្រើសរើសគំរូចំនួន ៣៩០ រឺ ក៏សរុបទាំអស់ ៧៨០ គំរូសំរាប់២វគ្គនឹង ត្រូវ បានជ្រើសរើសដោយប្រើគំរូលីនេអ៊ែដោយចៃដន្យ និង សមាមាត្រប្រូបាបបីលីតេដើម្បីកំណត់ទំហំនៃការអង្កេត ។ សមាជិកនៅក្នុងផ្ទះក្នុងភូមិនឹងត្រូវប្រើជាការវាស់វែងពីទំហំនៃការអង្កេត ។ ពតិមាននេះពឹងផ្អែលទៅលើកាវិភាគ តាមរយះ databaseធ្វើឡើងដោយ ក្រសួងផែនការ វិទ្យាស្ថានស្ថិតិជាតិ ហើយនិងមានប្រភពជាច្រើន ទៀត ពី ភូមិសាស្រ្ត នៃ Geographic Department, ឯកសារភូមិដែលធ្វើឡើងក្នុងឆ្នាំ ១៩៩៣ ដោយ United Nations Transitional Authority in Cambodia (UNTAC), ចំនួនស្ថិតិរបស់ខេត្តបាតដំបងដោយ United Nations High Commissioner for Refugees (UNHCR), ហើយនឹងការស្ទង់មើលចំនួនបន្ថែមទៀត ត្រូវផ្តល់ដោយក្រសួងមហាផ្ទៃ ហើយនិងសាលាក្រុងភ្នំពេញ ។ ការដាក់បញ្ចូលគ្នារវាងប្រភពទាំងពីរនេះ ចៃចាយ គំរូគំរោងនេះដល់ ការអង្កេតសេដ្ឋកិច្ច - សង្គមកិច្ចនៃកម្ពុជា (SESC) ក្នុងឆ្នាំ 1996 ។ ផ្ទះសម្បែងចែកជាគំរូទី២ (SSUs). ពី PSU (ផ្នែកដំបូងនៃគំរូ), ផ្ទះសំបែង 10 រឺ 20 នឹងត្រូវជ្រើសរើសជាគំរូដោយចៃដន្យ ហើយការជ្រើសរើសគំរូនេះនឹងត្រូវពន្យល់នៅផ្នែកបន្ទាប់ទៀត ។

### 1.6. ការជ្រើសរើសគំរូ

#### 1.6.1 ការជ្រើសរើសគំរូលើកទីមួយ

ការជ្រើសរើសគំរូរលើកដំបូងទាក់ទងនឹងគំរូតាមភូមិតាមថ្នាក់នីមួយៗ ។ ក្នុងជាន់ថ្នាក់នីមួយៗ ភូមិទាំង នោះត្រូវបានរៀបចំដោយមានដាក់លេខកូដទីតាំងភូមិសាស្រ្ត ហើយនិងលេខផ្ទះសម្បែង ។ សំរាប់រាល់ភូមិ ដោយផ្អែកទៅលើការកត់ត្រាគំរូនៃគំរោងត្រូវបានប្រមូល ។

ភូមិគំរូទាំងឡាយត្រូវជ្រើសរើសដោយប្រើប្រព័ន្ធគំរូលីនេអ៊ែដោយចៃដន្យនិងដោយប្រើសមាមាត្រប្រូបាបដើម្បីកំណត់ទំហំគំរូនោះ (pps). ចំនួនផ្ទះសំបែងនៅក្នុងភូមិត្រូវប្រើរង្វាស់នៃទំហំគំរូ។ ការជ្រើសរើសគំរូត្រូវធ្វើឡើង តាមរយះការប្រើប្រាស់កម្មវិធីកុំព្យូទ័រ។

### 1.6.2 ការជ្រើសរើសគំរូរលើកទី២

សំរាប់ PSU ប្រតិបត្តិនៃការចុះបញ្ជីនឹងលើកលែងភូមិធំៗ។ ភូមិធំៗត្រូវបែងចែកជាចំនែកតូចៗសិនដោយបញ្ចូលផ្ទះសម្បែងប្រហែល ៣០០ រឺតិចជាងផ្អែទៅលើការប៉ាន់ស្មានលើផ្ទះសំបែងក្នុងពេលបច្ចុប្បន្នដោយ អ្នកដឹកនាំក្នុងឃុំ រឺ ភូមិ។ ការបញ្ចូលនេះត្រូវជ្រើសរើសដោយចៃដន្យដើម្បីចុះបញ្ជី។ ការធ្វើបែបនេះនឹង តំរូវអោយការអនុវត្តការសាកសួរអោយបានពេញលេញនៃ PSU ដើម្បីបំពេញបញ្ជីផ្ទះសម្បែងអោយបានសព្វគ្រប់។ និតិវិធីនេះ នឹងទាក់ទងទៅនឹងការគូសផែនទីបញ្ជាក់ពីទីតាំងភូមិសាស្ត្រសំរាប់ PSU នៃផ្ទះសំបែងនីមួយៗ។ ម្យ៉ាងវិញទៀតការសួរនេះនឹងធ្វើឡើងគ្រប់ភូមិទាំងអស់តាមរយះការធ្វើដំណើរ ដើម្បីអោយដឹងពីទីតាំងប្រាកដនៃ ផ្ទះ សំបែងទាំងនោះ។

បន្ទាប់ពីការចុះបញ្ជីនេះរួចរាល់ហើយ ទំហំគំរូរថេរនៃផ្ទះសម្បែងចំនួន១០នឹងត្រូវជ្រើសរើសក្នុង PSU សំរាប់កម្មវិធី strata: ដូចជា បន្ទាយមានជ័យ ភ្នំពេញ ពោធិ៍សាត់ សៀមរាប ទីប្រជុំជន និង តំបន់ជនបទផ្សេងទៀត។ ប៉ុន្តែផ្ទះចំនួន ២០ ទៀតនឹងត្រូវជ្រើសរើសពី PSU សំរាប់ខេត្ត បាត់ដំបង កំពង់ធំ រតនៈគីរី និង ស្វាយរៀង។ ការជ្រើសរើសនេះនឹងធ្វើឡើងដោយប្រើប្រព័ន្ធ circular systematic គំរូដោយចៃដន្យ។ ចន្លោះនៃគំរូនឹងស្មើនិងការប៉ាន់ស្មានផ្ទះសំបែងបច្ចុប្បន្ននៅក្នុង PSU ត្រូវបានចែកនឹង 10 និង 20 ជាករណីប្រហាក់ប្រហែល។

### 2.5 ទំហំនៃគំរូ

យុទ្ធសាស្ត្រក្នុងការជ្រើសរើសគំរូរត្រូវការជ្រើសរើសគំរូផ្ទះសរុបចំនួន ៩០០០ ពីភូមិគំរូចំនួន ៧៨០ សំរាប់ ២ វគ្គ។ ចំនួនភូមិ (PSUs) ផ្ទះសម្បែង (SSUs) ត្រូវដាក់ជាគំរូសំរាប់ថ្នាក់នីមួយៗហើយត្រូវបង្ហាញនៅក្នុងតារាងទី២។

**តារាងទី២ : ការបែងចែកភូមិគំរូនិងផ្ទះសម្បែងតាមថ្នាក់**

**តាមវគ្គនៃការអង្កេតក្នុងឆ្នាំ ១៩៩៦**

| ថ្នាក់នៃគំរូអង្កេត | វគ្គទី ១ | | វគ្គទី ២ | | សរុប | |
|---|---|---|---|---|---|---|
| | ភូមិ | គ្រួសារ | ភូមិ | គ្រួសារ | ភូមិ | គ្រួសារ |
| កម្មវិធី STRATA | 390 | 4500 | 390 | 4500 | 780 | 9000 |
| បន្ទាយមានជ័យ | 30 | 300 | 30 | 300 | 60 | 600 |
| បាត់ដំបង | 20 | 400 | 20 | 400 | 40 | 800 |
| កំពង់ធំ | 20 | 400 | 20 | 400 | 40 | 800 |
| ភ្នំពេញ | 60 | 600 | 60 | 600 | 120 | 1200 |
| ពោធិសាត់ | 30 | 300 | 30 | 300 | 60 | 600 |
| រតនគិរី | 15 | 300 | 15 | 300 | 30 | 600 |
| សៀមរាប | 30 | 300 | 30 | 300 | 60 | 600 |
| ស្វាយរៀង | 20 | 400 | 20 | 400 | 40 | 800 |
| ទីប្រជុំជនផ្សេងទៀត | 50 | 500 | 50 | 500 | 100 | 1000 |
| ជនបទផ្សេងទៀត | 100 | 1000 | 100 | 1000 | 200 | 2000 |
| កោះកុង , មណ្ឌលគិរី , ស្ទឹងត្រែង | 15 | 150 | 15 | 150 | 30 | 300 |
| ជនបទផ្សេងទៀត | 85 | 850 | 85 | 850 | 170 | 1700 |

# ជំពូកទី២
# តួនាទីរបស់អ្នកប្រមូលទិន្នន័យ

គុណភាពនៃការប្រមូលទិន្នន័យ ពឹងផ្អែកយ៉ាងខ្លាំងទៅលើមនុស្សដែលត្រូវប្រមូលទិន្នន័យ។ ដូច្នេះអ្នក ដែលទទួលការងារជាអ្នកប្រមូលទិន្នន័យតំរូវអោយមានការតាំងចិត្តយ៉ាងមុតមាំដើម្បីធានាថាពតិមានទាំងអស់ ដែលបានប្រមូលមកនោះពិតជាត្រឹមត្រូវនិងពេញលេញដោយគោរពទៅតាមការណែនាំដែលបានពន្យល់នៅក្នុង ក្បួនត្រូវបានពិភាក្សាក្នុងវគ្គបណ្តុះបណ្តាលដើម្បីធ្វើជាអ្នកប្រមូលទិន្នន័យ។

ក្នុងនាមជាអ្នកប្រមូលទិន្នន័យមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើអង្កេត។ហើយការងាររបស់អ្នកទាំងនោះតំរូវអោយមានការប៉ិនប្រសប់ក្នុងការទំនាក់ទំនងជាមួយមនុស្ស ការយកចិត្តទុកដាក់លើសេចក្តីអិត និងការ ទទួលខុសត្រូវខ្ពស់ ដើម្បីរក្សានូវទំនុកចិត្តគ្រប់ពតិមានអំពីបុគ្គលិក និង ផ្ទះសំបែងដែលអ្នកទាំងនោះទទួលបានក្នុង ពេលសាកសួរ រឺ អង្កេតនេះ។ ជំពូកនេះផ្តល់សេចក្តីលំអិតអំពីតួនាទីរបស់ SESC ហើយនិងភារៈកិច្ច និង ការទទួលខុសត្រូវច្បាស់លាស់ ជាអ្នកប្រមូលទិន្នន័យរបស់ SESC ។

## 2.1 ការជ្រើសរើសទុកមុនរបស់អ្នកប្រមូលទិន្នន័យ

ក្នុងនាមជាអ្នកប្រមូលទិន្នន័យ អ្នកទាំងនោះនឹងត្រូវទទួលបានការបណ្តុះបណ្តាលហើយអ្នកទាំងនោះ ត្រូវ បំពេញការងារដែលត្រូវបានគេកំនត់អោយ។ អ្នកទាំងនោះនឹងត្រូវបានចេញជាប័នសំគាល់ខ្លួនដើម្បីបង្ហាញថាអ្នក ទាំងនោះមានសិទ្ធិចុះធ្វើការអង្កេត។ នៅពេលដែលអ្នកទាំងនោះធ្វើការ អ្នកគួរតែពាក់ប័នសំគាល់ខ្លួនជានិច្ច ហើយអ្នក ទាំងនោះត្រូវបង្ហាញប័ននៅ ពេលសំភាសន៏អ្នកស្រុកភូមិ។

## 2.2 ភារៈកិច្ចនិងការទទួលខុសត្រូវរបស់អ្នកប្រមូលទិន្នន័យ

ក្នុងនាមជាអ្នកប្រមូលទិន្នន័យ អ្នកទាំងនោះត្រូវរំពឹងគិតថា ត្រូវប្រឹងប្រែងធ្វើការងារអោយអស់ពីសមត្ថភាព។ អ្នកទាំងនោះត្រូវ ប្រមូលពតិមាន អោយបានត្រឹមត្រូវហើយអនុវត្តន៏តាមការណែនាំដែលបាន

ពិភាក្សានៅក្នុងក្បួនគំរូ អ្នកទាំងនោះគួរតែបង្ហាញ ការប្រមូលទិន្នន័យដែលទាក់ទងទៅនឹងកិច្ចការសំខាន់ដូចខាង ក្រោម :

1. ការសួរសំណួរបានត្រឹមត្រូវដូចបានពិភាក្សានៅក្នុងគំរូនេះ
2. កត់ត្រាចំលើយអោយបានត្រឹមត្រូវ
3. ការពិនិត្យរៀងរាល់ចំលើយដើម្បីអោយដឹងថាចំលើយទាំងនោះមានហេតុផលសមរម្យ

អ្នកប្រមូលទិន្នន័យត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកិច្ចការនីមួយៗ ដើម្បីអោយការ ស្ទង់មតិទទួល បានជោគជ័យ ។

ភារៈកិច្ចជាមូលដ្ឋានរបស់អ្នកប្រមូលទិន្នន័យដូចខាងក្រោមៈ

1. រៀបចំគូសផែនទីសំរាប់តំបន់ប្រមូលទិន្នន័យ (EA)
2. ចុះបញ្ជីផ្ទះសំបែងដែលបានរកឃើញនៅក្នុង EA ដោយប្រើប្រាស់ទំរង់ SESC ទំរង់ 1 ហើយបញ្ជូនទំរង់បែបបទដែលបំពេញរួចស្រេចទៅកាន់អ្នកគ្រប់គ្រងទិន្នន័យ
3. គូសផែនទីនៅលើ EA នៃទីតាំងផ្ទះ អាគារដែលបានចុះក្នុងបញ្ជី
4. ប្រមូលទិន្នន័យអោយបានត្រឹមត្រូវចំពោះផ្ទះសំបែងដែលមាននៅក្នុង EA ដោយប្រើសំនុំបែបបទ SESC ទំរង់ 2 ហើយបញ្ជូន ទំរង់បែបបទដែលបំពេញរួចស្រេចទៅកាន់អ្នកគ្រប់គ្រងទិន្នន័យ
5. ចូលរួមការប្រជុំរៀមចំដោយអ្នកគ្រប់គ្រងដើម្បីអនុវត្តន៏ភារៈកិច្ចនេះអោយបានពេញលេញអ្នកប្រមូល ទិន្នន័យគួរតែបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម

1. ចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនិងការប្រមូលទិន្នន័យដើម្បីស្វែងយល់ពីគំនិត និយមន័យ និងការណែ នាំទាំងឡាយដែលដឹកនាំដោយ SESC
2. ប្រើក្បួនរាប់ម្តងមួយៗសំរាប់គំរូ ជាការណែនាំសំខាន់មួយនៅពេលដែលមានចំងល់លើគំនិតរឺការណែ នាំផ្សេងៗ
3. រៀបចំគំរោងធ្វើដំណើរទុកជាមុនដើម្បីកាត់បន្ថយការបាត់បង់ពេលវេលាមិនចាំបាច់ ហើយនិងការហៅ ត្រឡប់មកវិញ

4. បំពេញទំរង់បែបបទ SESC ទំរង់ អោយបានពេញលេញនិងត្រឹមត្រូវ

5. ត្រួតពិនិត្យសមត្ថភាពការងារ ហេតុផល ភាពរឹងប៉ឹង។ល។ ប្រសិនបើមិនមាន ករណីពតិមាន ដែលបាន មិនច្បាស់ មិនត្រឹមត្រូវរឺខ្វះខាតនៅក្នុងតារាងសំណួរសូមទៅកាន់ផ្ទះសម្ភែងដើម្បីយកពតិមាន ឡើងវិញ

6. បំពេញកិច្ចការប្រមូលទិន្នន័យ

7. រក្សាពតិមានដែលប្រមូលបានដោយមានទំនុកចិត្តបំផុត មិនត្រូវអោយអ្នកដ៏ទៃដឹងក្រៅពីអ្នកគ្រប់គ្រង និងត្រូវរក្សាសិទ្ធិដោយ NIS

8. រៀបចំប្រតិបត្តិបគល់ឯកសាររបាយការណ៏សំនុំបែបបទនៃការសំភាសន៏ដល់អ្នកគ្រប់គ្រងទៅតាម ពេល កំណត់

## 2.3 កាទំនាក់នងជាមួយអ្នកគ្រប់គ្រង

ចំពោះគុណតំលៃតួនាទីជាអ្នកប្រមូលពតិមាន ត្រូតែយល់អោយបានច្បាស់អំពីទំនាក់ទំនងជាមួយអ្នក គ្រប់គ្រង។ ជាទូទៅ អ្នកគ្រប់គ្រងត្រូវបានតែងតាំងដើម្បីត្រួតពិនិត្យអ្នកប្រមូលពតិមានក្នុងអំឡុងពេលចុះប្រមូលពតិមាន។ ភារៈកិច្ចនិងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងជាមួយអ្នកប្រមូលពតិមានដូចតទៅ :

1. អ្នកគ្រប់គ្រងទទួលខុសត្រូវក្នុងការធានា ថាអ្នកប្រមូលពតិមានទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គេ ហើយចុះបញ្ជីនឹងប្រមូលពតិមានដោយពេញចិត្ត។ ហើយក៏ជាអ្នករៀបចំគំរោង នៅក្នុង តំបន់នៃការគ្រប់គ្រងនោះ លើសពីនេះទៅទៀតគឺត្រួតពិនិត្យថាតើអ្វីៗគ្រប់យ៉ាងត្រូវបាន ធ្វើពេញ លេញនិងមានប្រសិទ្ធិភាពរឺទេ។

2. អ្នកគ្រប់គ្រងត្រូវពិនិត្យមើលអោយច្បាស់ថាតើដំណើការនៃការប្រមូលពតិមានបានត្រឹមត្រូវរឺទេ ហើយប្រមូលទិន្នន័យក្នុងការងារតាមវិធីដែលមានស្តង់ដាដូច NIS កំនត់ដែររឺទេ។ អ្នកមូល ទិន្នន័យត្រូវបង្ហាញនិងប្រគល់ការងារអោយអ្នកគ្រប់គ្រងហើយត្រូវសរសេររបាយការណ៏ពីការរីចំរើននៃការងារនោះផងដែរ ។អ្នកគ្រប់គ្រងត្រូវជួយកែកំហុសអ្នកមូលទិន្នន័យដែលកើតមានឡើងក្នុងការងារដើម្បីអោយពួកគេ ជៀសវាងពីកំហុសដដែលៗ។

3. អ្នកគ្រប់គ្រងនឹងចុះទៅតាមតំបន់ប្រមូលពតិមាន រឺ ទិន្នន័យដោយផ្ទាល់ដើម្បីអោយដឹងថាតើអ្នកប្រមូលទិន្នន័យបានចុះធ្វើការក្នុងតំបន់គោលដៅរឺទេ ហើយក៏នឹងចុះទៅសំភាសន៏តាមផ្ទះសម្បែង ខ្លះៗ ដើម្បីអោយដឹងថាតើទិន្នន័យដែលបានមកត្រឹមត្រូវរឺអត់។

4. អ្នកគ្រប់គ្រងនឹងផ្តល់ឯកាសារចាំបាច់ដល់អ្នកប្រមូលទិន្នន័យដូចជាតារាងសំណួរ ឯកសារសំរាប់របាយ ការណ៏និងផែនទី។ល។ បន្ទាប់ពីបានបញ្ចប់ការប្រមូលទិន្នន័យ អ្នកប្រមូល ទិន្នន័យត្រូវ ប្រគល់ឯក សារដែលមិនប្រើ រឺ សេសសល់ដល់អ្នកគ្រប់គ្រងវិញ បើមិនដូច្នោះ ទេអ្នកប្រមូល ទិន្នន័យនឹងមិន ត្រូវទទួលប្រាក់បៀវត្សន៏នៅពេលចប់ការងារឡើយ។

5. អ្នកគ្រប់គ្រងមានទំនាក់ទំនងរវាងអ្នកប្រមូលទិន្នន័យនិងមន្ត្រីជាន់ខ្ពស់របស់ NIS ហើយក៏ផ្តល់ពតិ មាន ការនែនាះពីមន្ត្រី NIS ដល់អ្នកប្រមូលទិន្នន័យ។ អ្នកប្រមូលទិន្នន័យ ត្រូវតែ ផ្តល់ពតិមាន អំពី បញ្ហា និងការលំបាកដែលពួកគេបានជួបប្រទះ ហើយត្រូវរកវិធីដើម្បីដោះស្រាយ បញ្ហា ក្នុងពេល ចាំបាច់។

## 2.4 ការផ្គត់ផ្គង់សំភារះ

បន្ទាប់ពីការបណ្តុះបណ្តាលមុននឹងចាប់ផ្តើមចុះប្រតិបត្តិការងារ អ្នកគ្រប់គ្រងនឹងផ្តល់សំភារះមួយចំនួនដើ ម្បីជួយសំរួលដល់ការងារដូចជា ពាក្យបែបបទក្នុងការស្ទង់មតិ ពាក្យសុំផ្ទៃករដ្ឋបាល និងការសំភារះ ផ្សេងៗ ទៀត។ នៅពេលដែលអ្នកប្រមូលទិន្នន័យបានទទួលការផ្គត់ផ្គង់ទាំងអស់នេះហើយ ត្រូវត្រួតពិនិត្យ អ្វីដែលបានទទួលនោះអោយបានត្រឹមត្រូវ។

ខាងក្រោមនេះគឺជាពាក្យសុំ បែបបទផ្សេងៗ និង ការផ្គត់ផ្គង់សំភារះដែល SESC ប្រគល់អោយ អ្នកប្រមូលទិន្នន័យ ហើយពួកគេនឹងដឹងពីរបៀបក្នុងការប្រើប្រាស់ នឹង បំពេញនៅក្នុងជំពូកទាំងឡាយ។

1. SESC ទំរង់ 1 - តារាងចុះបញ្ជី
2. SESC ទំរង់ 2 - កំរងសំនួរសំរាប់សួរនៅតាមផ្ទះសំបែង
3. SESC ទំរង់ 3 - ប័នសំរាប់ការណាត់ជួប
4. ទំរង់គំរូ នៃការរាយឈ្មោះ

5. បន័សំគាល់ខ្លួន

6. ឧបករណ៏សំរាប់ធ្វើការចុះបញ្ជីឈ្មោះមានដូចជា ខ្មៅដៃ ជ័រលប់ ដៃកខ្វងខ្មៅដៃ ក្រដាស់ប្រដាប់កិប គ្រាប់កិប អំបិល អំបិលអ៊ីយ៉ូតជាច្រើនកញ្ចប់ វិតាមីន A ប័នសំរាប់ចាក់វ៉ាក់សាំង MUAC tapes, ខោហើយនិងក្រណាត់ ។

7. វិភាគទំហំការងារ

8. គិតទុកមុននូវការងារដែលត្រូវធ្វើ នៅពេលដែលអ្នកប្រមូលទិន្នន័យបញ្ចប់ការងារ ត្រូវប្រគល់គ្រប់សំភារៈដែលនៅសល់ដល់អ្នកគ្រប់គ្រងវិញ ។

# ជំពូកទី៣

## ច្បាប់ទូទៅសំរាប់ការសំភាសន៍

សំរាប់ SESC 1996, ក្រុមអ្នកប្រមូលទិន្នន័យមួយក្រុមដែលមានពីរនាក់ចុះសំភាសន៏តាមផ្ទះសំបែង ។ ហើយត្រូវបំរុងទុកចំពោះការកាត់បន្ថយនូវការចុះលេខដូចដែលអ្នកចុះបញ្ជីទទួលបន្ទុក ។ ប៉ុន្តែអ្នកប្រមូលទិន្នន័យ ម្នាក់នៅក្នុងក្រុមគ្រប់គ្រងកំរងសំនួរផ្នែកដំបូង ហើយម្នាក់ទៀតអាចរៀបចំការវិភាគ ការងារ និងគិតទុក មុននូវការងារដែលត្រូវធ្វើ ។ បើទាំងឪពុកម្តាយរឺក៏ពីរនាក់ អ្នកណាក៏ដោយនៅក្នុងផ្ទះដែលអាច ឆ្លើយ តប នឹងសំនួរបានអ្នកប្រមូលទិន្នន័យអាចបំបែកកំរងសំនួរជាពីផ្នែកហើយក៏ចាប់ផ្តើមសួរសំនួរដែលបំបែកនោះ ។កំរងសំនួរទាំងឡាយត្រូវបង្កើតឡើងដោយមានស្តង់ដាត្រឹមត្រូវដូច្នេះវាមានលក្ខណះងាយស្រួលក្នុងការបំបែកសំសំនួរជា

ពីរផ្នែក ។អ្នកសំភាសន៍ត្រូវកិបសំណួរអោយបានត្រឹមត្រូវច្បាស់លាស់បន្ទាប់ពីការសំភាសន៍ដើម្បីកុំអោយប្របូកច្របល់និងសំណួរដ៏ទៃទៀត ។

### 3.1 ច្បាប់ក្នុងការសំភាសន៍

#### តើត្រូវសំភាសន៍នណា?

សំភាសន៍សមាជិកក្នុងគ្រួសារណាក៏បានដែរអោយអាចឆ្លើយសំណួរបាននិងផ្តល់ពតិមានបានត្រឹមត្រូវចំពោះគ្រួសាររបស់គេ។ មេគ្រួសារឺក៏ប្តីប្រពន្ធនឹងជាបុគ្គលដែលសសមបំផុតក្នុងការឆ្លើយសំនួរទាំងនោះ ប៉ុន្តែសំណួរទាក់ទងទៅ និងសុខភាពម្តាយគឺជាអ្នកដែលសសមបំផុតក្នុងការឆ្លើយសំនួរ ។

#### របៀបសួរសំនួរ

គោលបំណងសំខាន់របស់ប្រតិបត្តិការណ៏ប្រមូលពតិមានគឺអាចទទួលបាននូវពតិមានត្រឹមត្រូវនិងពេញលេញ ។ ក្នុងនាមជាអ្នកប្រមូលមូលពតិមាន ត្រូវតែមានចេះប្រើពាក្យពេជន៏សុភាពរាបសារគ្រប់ពេលវេលា ប៉ុន្តែព្រមជា មួយគ្នានោះដែរ ត្រូវបង្ហាញថាពួកគេមានអំនាចគ្រប់គ្រាន់ក្នុងការទុកចិត្ត ជឿជាក់ពីអ្នក ផ្តល់ចំលើយ។ ការ ចាប់ អារម្មណ៏ដ៏ល្អរបស់អ្នកប្រមូលទិន្នន័យចំពោះអ្នកដែលត្រូវសំភាសន៏គឺជាវិធីមួយ ដែលអាចឈានទៅរកភាមជោគ ជ័យក្នុងការសំភាសន៏ ។ សូមធ្វើតាមសេចក្តីណែនាំអំពីវិធីសំភាសន៏ខាងក្រោម :

1. **រៀបចំខ្លួនអោយបានសមរម្យ**

ត្រូវស្លៀកពាក់អោយបានស្អាត សមរម្យដើម្បីទាក់ទាញការចាប់អារម្មណ៏ពីអ្នកដែលត្រូវសំភាសន៏ ។ មនុស្សមួយចំនួនវាយតំលៃអ្នកដ៏ទៃតាមរយះការស្លៀកពាក់ហើយមិនចង់និយាយជាមួយអ្នកដែលស្លៀពាក់កខ្វក់នោះទេ ។

2. **ចេះពគួរសម**

មនុស្សទាំងឡាយនឹងមានប្រតិកម្មខុស១គ្នា

ទោះជាយ៉ាងណាក៏ដោយត្រូវតែមានភាពគួរសម និងរួសរាយរាក់ទាក់ជានិច្ច ។

ត្រូវព្យាយាមញញឹមជានិច្ច

ត្រូវរៀបចំប្រភេទសំណួរអោយបានល្អ

មិនត្រូវបង្កជំលួសជាមួយអ្នកផ្តល់ចំលើយនៅឡើយហើយត្រូវតាំងចិត្តអោយបានស្ងប់ក្នុងករណីអ្នកឆ្លើយខឹង ។

3. **ណែនាំខ្លួននិងការស្ទង់មតិដល់អ្នកឆ្លើយមុនពេលសំភាសន៍**

ការណែនាំខ្លួនមុនពេលសំភាសន៏មានសារៈសំខាន់ណាស់ ហើយអ្នកប្រមូលទិន្នន័យអាចនិយាយ ដូចខាងក្រោម :

" អារុណសួរស្តី រឺ ទិវាសួរស្តី។ ពួកយើងជា........អ្នកប្រមូលទិន្នន័យមកពីវិទ្យាស្ថានជាតិស្ថិតិនៃ ក្រសួងផែនការ។ នេះគឺជាប័នសំគាល់ខ្លួនរបស់ពួកយើង។ ក្នុងពេលបច្ចុប្បន្ននេះពួកយើង កំពុងធ្វើការអង្កេតអំពីសេដ្ឋកិច្ចសង្គមឆ្នាំ១៩៩៦នៅក្នុងប្រទេសដែលបានជំនួយពីធនាគារអភិវឌ្ឍន៏អាស៊ីសហការជាមួយអង្គកា ***UNICEF, NDP/CARERE AND ILO.*** ពួកយើងមានសេចក្តី រីករាយបំផុតក្នុងការឆ្លើយរាល់សំណួរទាំងក្នុងការអង្កេតនេះ ហើយសូមអ្នកទាំងអស់គ្នា ជួយឆ្លើ សំណួរទាំងដោយមានទំនុកចិត្តនិងត្រឹមត្រូវផង។"

4. **ពន្យល់ពីគោលបំណងរបស់ការអង្កេត**

ការពន្យល់ពីគោលបំណងរបស់ការអង្កេតនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើនសហប្រតិបត្តិការណ៏ពអ្នកដែលត្រូវសំភាសន៏។

5. **អាននិងធ្វើតាមសេចក្តីណែនាំយ៉ាងប្រុងប្រយ័ត្ន**

ការណែនាំត្រូវបានសរសេរនៅផ្នែកខាងនៃតារាងសំណួរ រឺ ក្នុងវង់ក្រចកខាងក្នុងគូទ្បោន។ ដូច្នេះ អ្នកប្រមូលទិន្នន័យត្រូវយល់សំនួរទាំងអស់អោយបានច្បាស់។

6. **សួរសំណួរទាំងអស់នៅក្នុងតារាងសំណួរ**

មិនត្រូវស្មានចំលើយនោះទេ។ សួរសំណួរទាំងនោះទោះបីជាអ្នកគិតថាអ្នកដឹងចំលើយរួចស្រេច ក៏ដោយ។ អ្វីដែលអ្នកគិតឃើញមិនប្រាកដថាជាចំលើយត្រឹមត្រូវនោះទេ។ ចូរអានសំណួរនី មួយៗក្នុងតារាងសំណួរអោយបានច្បាស់។

7. **ស្ទង់មើលនៅពេលដែលចំលើយមិនពេញចិត្តឆ្លើយ**

មិនត្រូវកតចំលើយណាដែលមិនច្បាស់នោះទេ។

ប្រសិនបើចំលើយរបស់អ្នកឆ្លើយមិនច្បាសរឺ ឆ្លើយដោយមិនពេញចិត្ត គួរតែសួរស្ទង់ពតិមានបន្ថែមទៀត។ ការស្ទង់រកចំលើយអាចធ្វើដូច ខាងក្រោម :

a) *សួរសំណួរម្តងទៀត:* ការសួរសំណួរច្រើនដងជូនកាលអាចធ្វើអោយអ្នកផ្តល់ចំលើយផ្តល់ពតិ មានដែលពួកគេចងចាំ

b) *ពន្យល់ពីអត្ថន័យប្រសិនបើចាំបាច់* : មានពាក្យបច្ចេកទេសខ្លះ ពិបាកយល់ដូច្នេះត្រូវពន្យល់ជាភា សាសំរាយងាយយល់ ។

c) *សួរដើម្បីស្មានប្រសិនបើសមស្រប* : បើអ្នកផ្តល់ចំលើយមិនអាចចងចាំបានទេ ដូចជាថ្ងៃកំណើត អាយុរបស់ឪពុកម្តាយ ចូរព្យាយាមសួរដើម្បីស្មានជួយដល់អ្នកឆ្លើយងាយស្រួលគុណគូលេខ ។

d) *ផ្អាកដើម្បីទុកពេលអោយអ្នកឆ្លើយគិតសំណួរ* : មិនត្រូវប្រញាប់ចង់បានចំលើយពេកទេ ត្រូវទុក ពេលអោយអ្នកឆ្លើយគិតសំណួរជាមុនសិន ។

8. **អគុណដល់អ្នកដែលបានចូលរួមសហការឆ្លើសំណួរ**

ត្រូវធ្វើយ៉ាងណាដើម្បីអោយអ្នកឆ្លើយសំណួរមានអារម្មណ៏ល្អបន្ទាប់ពីការសម្ភាសន៍ ។ ចូរបង្ហាញពីសេចក្តីរីករាយចំពោះអ្នកឆ្លើយ ឧទាហរណ៏ ត្រូវនិយាយថា : " អគុណយ៉ាងក្រៃលែងដែល បានចំណាយពេលវេលាដ៏មានដំលៃចូលរួមឆ្លើយសំណួររបស់ក្រុមយើង"

9. **បន្ទាប់ពីការសំភាសន៏និមួយៗសូមពិនិត្យមើលឡើងវិញគ្រប់ទំព័រទាំអស់នៃសំណួរក្រែងមាន**

**ការកត់ត្រារំលងឬភ្លេចឬមិនស៊ីគ្នានៃចំឡើយ ។**

***របៀបសួរសំណួរ***

**ក្នុងការសួរសំណួរ ត្រូវត្រួតពិនិត្យនូវច្បាប់ដូចខាងក្រោម :**

1. សូមសួរសំណួរតាមពាក្យសរសេរនៅក្នុងបញ្ជីសំណួរ

2. សូមសួរសំណួរតាមលំដាប់លំដោយដូចមានសរសេរនៅក្នុងសំណួរ លើកលែងតែ មានបញ្ហាផ្សេងទៀត ។ សូមកុំរំលងផ្នែកណាមួយ បង្គោលណាមួយ ឬមុខសំណួរណាមួយនៅក្នុងបញ្ជីសំណួរ លើកលែងក្នុងករណីដែលមានការណែនាំពិសេស ។

សូមពិត្យផ្ទៀងផ្ទាត់ទគប់ទំព័រទាំអស់នៃបញ្ជីសំណួរដែលបានកត់ត្រាហើយ ។ លេខលំដាប់ត្រូវបាន ចុះ នៅផ្នែកខាងស្តាំនឹងខាងលើទំព័រ ។

2. សូមកុំសួរសំណួរជុំវិញឱ្យសោះ

ពោលគឺសំណួរដែលមានស្ទើរជាចំឡើយដូចជាអ្នកសំភាសន៏នឹកស្មាន ។

ការសួរសំណួរបែបនេះធ្វើឱ្យគំនិត្យអ្នកឆ្លើយផ្តោតទៅលើជំនឿថាចំឡើយដែលបានស្ទើរនោះ គឺ

ជាចំ ឡើយដែលត្រឹមត្រូវសំរាប់សំណួរនោះ ។ ឧទាហរណ៏នៃសំណួរជំរុញ: "តើអ្នកជាមេគ្រួសាររឺ?"

តែសំណួរដ៏ប្រត្រូវគឈតឺ" តើនណាជាមេគ្រួសារនេះ? "

4. សូមកាត់ប្រសាសន៏បេស់អ្នកឆ្លើយឱ្យសោះប្រសិនបើគ្មានការចាំបាច់

5. សូមបញ្ជាក់ការកត់ត្រាចំឡើយសិនមិននឹងសួរសំណួរបន្ទាប់ទៀត

## 3.2 របៀបកត់ត្រាចំឡើយទុនៅក្នុងបញ្ជីសំណួរ CSES

1. សូមប្រើខ្មៅដៃសំរាប់កត់ត្រាចំឡើយក្នុងបញ្ជីសំណួរ CSES ។ សូមកុំប្រើខ្មៅដៃពណ៌ផ្សេងៗ ឬក៏ប៊ិប ពីព្រោះពេលដែលមានកំហុសក្នុងការកត់ត្រាចំឡើយ កំណត់ត្រានោះមិនអាច នឹងលុបបានដោយ ងាយៗ ទេ ។

2. សូមប្រើជ័រលុប ដើម្បីលុបឱ្យអស់នៅកំនត់ត្រាណាដែលខុស ។ មិនត្រូវសរសេរ ត្រួតលើគ្នាទៅ នឹង កំនត់ត្រាមិនឡើយ ។

3. ក្នុងពេលសំភាសត្រូវតែបំពេញសំណួរ ហើយត្រូវតែសរសេរ ចំលើយនៅលើក្រដាស់ផ្សេងៗគ្នា ដើម្បីងាយស្រួលដល់ការចំលងចំលើយទៅនិងសំនួរនៅពេលក្រោយ ។

4. ចំលើយភាគច្រើនដែលបានទទួលគឺត្រូវដាក់លេខកូដ ។ ចូរគូសរង្វង់លើចំលើយសំរាប់ចំលើយ ដែលគេផ្តល់អោយ ។

5. សូមសរសេររឿងរ៉ាវផ្សេងទៀតទៅក្នុងបញ្ជី ហើយសរសេរចំលើយអោយបានច្បាស់លាស់ សរ សេរអោយខ្លីប៉ុន្តែអោយបានច្បាស់លាស់ ។

6. ចូរសរសេរសញ្ញា (*)ទៅក្នុងតារាងសំណួរណាដែលមានការសង្ស័យរឺមិនច្បាស់ចំពោះអ្នកត្រួតពិនិត្យកែសំរួលឡើងវិញ នឹងត្រូវសរសេរកំណត់សំគាល់របស់ចំលើយនៅខាងក្រោមនៃទំព័រផង ។

7. សូមប្រើជ័រលុប ដើម្បីលុបឱ្យអស់នៅកំនត់ត្រាណាដែលខុស ។ មិនត្រូវសរសេរត្រួតលើគ្នាទៅ នឹងកំនត់ត្រាមិនឡើយ

8. សូមបំពេញផ្នែកបញ្ជាក់នៃទំរង់ CSES បន្ទាប់ពីការសំភាសន៏បានបញ្ចប់ ។ សូម សរសេរថ្ងៃខែ ឆ្នាំនៅពេលដែលបញ្ជីសំណួរត្រូវបានបំពេញ ឬការសំភាសន៏ត្រូវបានបញ្ចប់ ។

9. អ្នកត្រួតពិនិត្យត្រូវចុះហត្ថលេខានៅផ្នែកបញ្ជាក់បន្ទាប់ពីបានត្រួតពិនិត្យជាក់ស្តែងនៅទំរង់ CSES ដែលបានបំពេញរួចរាល់ហើយ ។ ការត្រួតពិនិត្យឡើងវិញទៅសលីទំរង់ អាចធ្វើទៅតាមមូលដ្ឋានឬនៅ ការិយាល័យនៅពេលដែលទំរង់ត្រូវបានប្រគល់ជូនរួចរាល់ហើយ ។

**3.3 របៀបត្រួតពិនិត្យតារាងសំណួរដែលបានបំពេញរួច**

បន្ទាប់ពីសំភាសរួច ត្រូវត្រួតពិនិត្យឡើងវិញនូវបញ្ជីតារាងសំណួរភ្លាម ។ ធ្វើបែបនេះមានន័យថាត្រូវពិ និត្យលើបញ្ជីឡើងវិញថាតើ សំណួរទាំងនោះអាចយកជាការបាន ពេញលេញគ្រប់គ្រាន់ និងមានហេតុផលស មរ ម្យរឺទេ។ ទោះជាបន្ទាប់ពីការពិនិត្យនេះនៅមានចំលើយខ្លះដែលមាការសង្ស័យក៏ដោយក៏ត្រូវទទួលយកចំលើយដែរប៉ុន្តែសូមសរសេរឹកត់សំគាល់នៅខាងក្រោមផងដើម្បីអោយអ្នកគ្រប់គ្រងងាយស្រួលក្នុងការពិនិត្យឡើងវិញ ។

# ជំពូកទី៤

## វិធីចុះបញ្ជីនិងការប្រមូលទិន្នន័យ

ជំពូកនេះរៀបរាប់អំពីទំរង់របស់ SESC ត្រូវបានប្រើក្នុងពេលដែលចុះប្រមូលទិន្នន័យហើយនឹង សេចក្តី សង្ខេបអំពីវិធីនៃការធ្វើការងារនេះ។ ប្រធានបទខ្លះៗក្នុងចំនោមប្រធានបទនេះត្រូវបានពិភាក្សាយ៉ាងលំអិតនៅក្នុងជំពូកដែលបានទទួលបានជោគជ័យ។

**4.1 ទំរង់ SESC**

តារាងខាងក្រោមជាទំរង់ដែលអ្នកសំភាសន៍ននឹងប្រើក្នុងការប្រមូលទិន្នន័យ។

តារាងខាងក្រោមគឺជាទំរង់ដែលបង្ហាញពីការប្រើប្រាស់ក្នុងពេលចុះលេខ និងទំរង់គំរូត្រូវបាន បង្ហាញក្នុង សេចក្តីបន្ថែម B ទៅ D និងបង្ហាញនូវទំរង់ពិត ដែលរួមបញ្ចូលនៅក្នុងការហ្វឹកហ្វឺនរបស់អ្នក។

**SESC** ទំរង់ **1** នេះគឺជាបញ្ជីដែលអ្នកនឹងចុះក្នុងបញ្ជីដែលមានអាគារ ផ្ទះ units ការចុះបញ្ជី ហើយនឹងផ្ទះសំបែងនៅក្នុងកន្លែងប្រមូលទិន្នន័យ (EA)។ អ្នកនឹងកត់ត្រាពត៌មានដទៃទៀតដែល ជាប់ ទាក់ទង ទៅនឹងសមាជិកនៅក្នុងផ្ទះ។

**SESC** ទំរង់ **2**

កំរងសំនួរសំរាប់គ្រួសារនេះជាកំរងកំរងសំនួរមូលដ្ឋាននៃ SESC ដែលអ្នកនឹង ប្រើសំរាប់សំរាប់សំភាស ន៏និងកតត្រាពត៌មានស្តីអំពីគ្រួសារ ។កំរងសំនួរនេះមានពតិមានដូចជាទីតាំងភូមិសាស្រ្ត លក្ខណៈសង្គមនិងសេដ្ឋ

កិច្ចរបស់ប្រជាជន គ្រួសារ និង ផ្ទះសំបែង

**SESC** ទំរង់ **3**

លិខិតណាតលជួបចូលប្រើទំរង់នេះសំរាប់ណាត់ជួបមេគ្រួសារ (ឬ ប្តីប្រពន្ធ) ក្នុងករណី ដែលមិនអាច សំ ភាសន៏នរណាម្នាក់ក្នុងពេលទៅសំភាសន៏លើកទីមួយ។ ហើយចូលបង្ហាញពីទំរង់នៃការបរិច្ឆេទ ម៉ោងដែលត្រូវ ទៅសំភាសន៏នៅពេលបន្ទាប់ ។

### 4.2 វិធីនៃការចុះបញ្ជី និងការសំភាសន៍

ការប្រមូលទិន្នន័យសំរាប់ SESC មានសកម្មភាពសំខាន់ៗដូចខាងក្រោម :

1. ការគូរផែនទី - ការគូរផែនទីនៅកន្លែងដែលត្រូចុះទៅសំភាសន៏ EA (ផ្នែកនៃភូមិ ទាំងមូល)ដោយមានព្រំដែនកំណត់នៅក្នុង EA ។

2. ការត្រួតត្រា - ការទៅសំភាសន៍នៅក្នុង EA ដើម្បីរកទិន្នន័យ (មេគ្រួសារ) ត្រូវបានចុះក្នុងបញ្ជីដើម្បីធានាថាការចុះទៅសំភាសន៏ក្នុងតំបន់មានលក្ខណៈពេញលេញ ។

3. ការចុះបញ្ជី - ការចុះបញ្ជីនៃមេគ្រួសារដោយប្រើ SESC ទំរង់ 1.

4. ការរៀបរាប់ - ការបង្ហាញអំពីអាគារនឹងផ្ទះដែលបានចុះក្នុងបញ្ជីនៃផែនទី EA ដោយប្រើនិមិត្តសញ្ញាច្បាស់លាស់ ។

ចូរកំនត់អាយុរបស់សមាជិកគ្រួសារនីមួយៗដោយសួរទៅអ្នកឆ្លើយថា "តើអាយុនៃថ្ងៃក ំនើត ចុងក្រោយរបស់គាត់នៅថ្ងៃខែឆ្នាំ?"ចូរសួរអំពីអាយយរបស់មនុស្សទោះជាថ្ងៃខែឆ្នាំកំនើតត្រូវបានផ្តល់អោរួចក៏ដោយ ។ មិនត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំនើត ។ មិនត្រូវគណនាពីរគិតអាយុរបស់មនុស្សតាមរយះថ្ងៃខែឆ្នាំកំនើតដែលបានរាយការណ៏នេះឡើយ ។ចូរបញ្ចូលទិន្នន័យក្នុងកូឡោន ៨ នូវអាយុរបស់សមាជិកនីមួយៗដែលមានឆ្នាំពេញលេញជាថ្ងៃកំណើតចុងក្រោយ ។ចំពោះទារកមានអាយុក្រោម ១ ឆ្នាំ ចូរដាក់លេខ 00 ។ បើអ្នកឆ្លើយ ស្ទានរបស់មនុស្សនៃរង្វាស់គុណ 5 និង 10 ដូចឧទាហរណ៏ ក្នុងន្លោះ “70” រឺ "85" ចូរព្យាយាម

បញ្ជាក់អោយច្បាស់តាមតែធ្វើទៅបានចំពោះការស្មានដែលជិតបំផុត។ បើអាយុដែលរាយការណ៍គឺ 98 រឺ លើសពីនេះ ចូរដាក់ "98" នៅក្នុងកូឡាននេះ។ ចូរដាក់ "DK" បើអាយុមិនអាចត្រូវបានស្មានទុក រឺ ក៏មិនអាចដឹងបាន។

**ភេទ (កូឡោន 9)**

សួរសំណួរ " តើ ______ បុរស ឬនារី ?". សូមសរសេរលេខ "1" សំរាប់បុរស ហើយ "2" សំរាប់ស្រី.

**ពិការភាព (កូឡោន 10 - 11)**

ដើម្បីបញ្ជាក់ថាសមាជិកគ្រួសារដែលអាចមានពិការភាពសន្ធរមួយត្រូវបានសួរនៅក្នុងកូឡោន 10 សំ រាប់សមាជិកគ្រួសារ ចូរសួរថា : "តើមានបញ្ហាសំខាន់អ្វីខ្លះជារាងកាយ ចិត្តគំនិត ដែលកំនត់ អោនការចូលរួមក្នុងការងាររបស់ពួកគេ សាលា រឺក៏កាពន្លកនៅក្នុងសង្គម?" ប្រសិនជាឆ្លើយ មាន, សូមដាក់លេខ "1" ក្នុង កូឡោន 10 ហើយសួរសំណួរក្នុងកូឡោន 11 "តើពួកគេពិការបែបណា?" ប្រសិនជាចំលើយនៅកូឡោនទី 10 គឺ ទេ, សូមសរសេរលេខ "2" ហើយកន្លែងនោះត្រូវដាក់ (-)ក្នុងកូឡោន 11, បន្ទាប់មកទៅកូឡោន 12

សំរាប់ SESC ប្រភេទជាក់លាក់នៃពិការភាពហើយនិងលេដកូដក្នុងចំលើយ របស់គេ ត្រូវរក ឃើញនៅខាងក្រោមនៃតារាងសំនួរដូចតទៅ :

**1** ការកាត់អវ័យវះមួយរឺច្រើន

**2** មិនអាចប្រើអវះយវះមួយរឺច្រើន

**3** ភាពខ្វាក់

**4** ភាពថ្លង់

**5** ភាពនិយាយមិនរួច

**6** ការរំខានក្នុងការគិត អារម្មណ៏និងការប្រព្រឹត្ត

**7** បញ្ហាទាក់ទងនិងគ្រឿងស្រវឹង

8 ការខូចរូបរាង្គជាអចិន្ត្រៃ

9 ការសិក្សាអំពីពិការភាពរឺពិការផ្នែកបញ្ញា

10 ពិការច្រើនផ្នែក

**រយះពេលក្នុងការស្នាក់នៅនៅក្នុងភូមិ (កូឡោន 12 & កូឡោន 13)**

ចូរដាក់កូឡោនទាំងនេះក្នុងកូលោនពេលវេលា (ចំនួនឆ្នាំ /ខែ) មនុស្សដែលស្នាក់នៅយូរ ក្នុងភូមិ ដោយ សួរ សំណួរថា : "តើអ្នកស្នាក់នៅក្នុងភូមិយូរប៉ុនណា?" សំរាប់មនុស្សដែលបានកំពុងស្នាក់នៅក្នុង ភូមិ រយះ ពេល ១ឆ្នាំរឺច្រើន១ឆ្នាំ ចូរដាក់លេខឆ្នាំ ខែ ពិតប្រាកដពេញលេញនៅក្នុងកូឡោន 12 និង 13 ។ ឧទាហរណ៏ បើមនុស្សដែលបាននៅក្នុងភូមិអស់រយះពេល៣ឆ្នាំ២ខែ ចូរដាក់លេខ "3" នៅក្នុងកូឡោន 12 ហើយលេខ "2" ក្នុងកូឡោន 13 ។

សំរាប់មនុស្សដែលរស់នៅក្នុងភូមិតិចជាង១១ខែ ចូរដាក់សញ្ញា "-" នៅក្នុងកូឡោន 12 ហើយដាក់លេខខែ ពេញលេញនៅក្នុងកូឡោន 13 ។ ទោះជាយ៉ាងណាក៏ដោយ បើច្រើនជាង១១ឆ្នាំ ចូរដាកលេខកូដ "1" ក្នុងកូឡោន 12 ហើយដាក់សញ្ញា (-) ក្នុងកូឡោន 13 ។

បើមនុស្សដែលបានរស់នៅតិចជាង២៨ថ្ងៃចូរដាក់សញ្ញា "-" នៅក្នុងកូឡេន 12 ហើយដាក់លេខកូដ "00" នៅក្នុកូឡោន 13 ។ ទោះយ៉ាងណាក៏ដោយបើច្រើនជាង 28 ថ្ងៃ ចូរដាក់សញ្ញា (-) ក្នុងគូឡោន 12 ហើយដាក់ លេខកូដ "1" ក្នុងកូឡោន 13 ។

បើមនុស្សនៅក្នុងភូមិតាំងពីកើតចូរដាក់លេខកូដ "88" ទាំងក្នុកូឡោន 12 និង13 ហើយបន្តទៅកូឡោន18 ។

**ទីកន្លែង នៃទីលំនៅពីមុន (កូឡោន 14)**

សំនួរនេះសួរពី " ***តើរស់នៅក្នុងសង្កាត់ និង ខេត្ត/ស្រុកណា ___ ទីលំនៅពីមុន?*** " និងត្រូវសួរចំពោះបុគ្គលណាដែលមិនត្រូវបានស្នាក់នូវបន្តនៅក្នុងភូមិ ។ (ដូច្នេះ, មិនបាច់សួរសំណួរនេះ ហើយសរសេរចំលើយ "-" ដាក់ក្នុងកូឡោន ១២-១៣ គឺ ៨៨) ។

ចំពោះកូឡោន ១៤ ត្រង់សង្កាត់ និង ខេត្ត/ស្រុក ឬប្រទេស (បើសិននៅក្រៅប្រទេសកម្ពុជា) កន្លែងដែលបុគ្គលនោះរស់នៅមុនពេលផ្លាស់ទីលំនៅមកនៅទីលំនៅបច្ចុប្បន្ននេះ។

ក្នុងករណីនេះអ្នកដែលបានផ្លាស់ប្តូរសំនៅដ្ឋានក្នុងសង្កាត់តែមួយ ដែលបានរស់នៅនោះត្រូវសរសេរ "same" ក្នុងកូឡោា ១៤។

ប្រសិនបើអ្នកត្រួតពិនិត្យមិនស្គាល់ពីទីលំនៅពីមុនរបស់សមាជិកគ្រួសារនោះទេ ត្រូវសួរសំណួរ នេះទៅកាន់អ្នកឆ្លើយ នៅពេលដែលគាត់មានវត្តមានក្នុងពេលធ្វើសំភាសន៏។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគាត់មិនអាចរៀបរាប់នោះ ត្រូវសរសេរ "DK" ក្នុងកូឡោននេះ។

## ការចែកផ្នែក២នៃទីលំនៅពីមុន (កូឡោន 16)

កូឡោននេះនិងមិនត្រូវបានសួរចំពោះបុគ្គលណាដែលមានដើមកំណើតនៅក្នុងភូមិនេះ ហើយនៅ បន្តការរស់នៅក្នុងភូមិ តទៅទៀត។

សួរចំពោះអ្នកឆ្លើយថា “តើ កន្លែងនោះ វាជាទីក្រុង ឬ ជនបទ?” ។ សរសេរលេខកូដ ១ ក្នុងកូឡោនប្រសិនបើបុគ្គលនោះមានទីលំនៅពីមុននៅទីក្រុង ឬ ទីរួមខេត្ត (ខ័ណ្ឌ) ឬ លេខកូដ ២ សំរាប់ការរស់នៅជនបទ ជាយក្រុង ឬស្រុក។ ប្រសិនបើអ្នកឆ្លើយមិនដឹង/មិនច្បាស់ ពីការប្តូរលំនៅដ្ឋាន ប៉ុន្មានពីមុននោះ សូមសួរសំណួរនេះទៅកាន់អ្នកឆ្លើយក្នុងពេលសំភាសន៏។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើនៅតែមិនច្បាស់ សូមសរសេរលេខកូដ "៩" ក្នុងកូឡោន ១៦ សំរាប់ "មិនស្គាល់"។

## មូលហេតុ នៃការ ផ្លាស់ទីលំនៅ (កូឡោន 17)

សំរាប់អ្នកដែលរស់នៅក្នុងភូមិដែលមានទីលំនៅពីមុនផ្សេងពីលំនៅដ្ឋានបច្ចុប្បន្ន ហើយដើម្បី រកនូវមូលហេតុដែលធ្វើអោយអ្នកផ្លាស់ទីលំនៅមកលំនៅដ្ឋានបច្ចុប្បន្ន សូមសួរសំណួរនេះ "តើអ្វីដែលជា មូលហេតុធ្វើអោយអ្នកផ្លាស់ប្តូរលំនៅដ្ឋាន?" ហើយសូមសរសេរនូវលេខកូដដែលត្រឹមត្រូវដែលបង្ហាញ នៅខាងក្រោមសំណួរនេះ។

ប្រសិនបើអ្នកប្តូរទីលំនៅមានទូវមូលហេតុច្រើនក្នុងការផ្លាស់ប្តូរទីលំនៅនោះ សូមកត់ត្រាតែមូលហេតុសំខាន់មួយបានហើយ ។

លេខកូដនៃមូលហេតុសំខាន់ៗ សំរាប់ការផ្លាស់ប្តូរទីលំនៅដ្ឋាន មានបង្ហាញដូចខាងក្រោម :

1 **អសន្តិសុខ ចំពោះ ការរស់នៅ/គ្រោះធម្មជាតិ :** ដើម្បីជៀសពីភាពអសន្តិសុខ និងស្ថានភាពផ្សេងៗ ឬគ្រោះធម្មជាតិ ដូចជា ព្យុះសង្ឃរា ទឹកជំនន់ ។ល ។

2 **ការរស់នៅជុំគ្រួសារ/គ្រួសាររស់នៅចលាត៌ :** ចំពោះបុគ្គលឬគ្រួសារទាំមូលពួកគេបានរស់នៅ ជាមួយគ្នា ឬរស់នៅជាមួយញាតិមត្តិរបស់គេនៅកន្លែងផ្សេង ។

3 **សេចក្តីសង្ឃឹមចំពោះការងារ / ការស្វែងរកការងារធ្វើ** – ការស្មានទុកជា មុនចំពោះ ឱកាស ការងារដ៏ប្រសើរនៅក្នុង / ការស្វែងរកការងារ រឺការរំពឹង គិតទុកកន្លែងនៅសព្វថ្ងៃអាច ផ្តល់ការងារដែលមានប្រាក់ចំនូលខ្ពស់ / និងគ្រាន់បើ ។

4 **ហេតុផលចំពោះការអប់រំ** – ដើម្បីអាចទទួលបានទូវការសិក្សាសមស្រប ។

5 **ការផ្ទេរកន្លែងធ្វើការ** – ការផ្លាស់ប្តូរកន្លែងធ្វើការ ថាតើត្រូវបានលើកលែដោយមាន ការផ្លាស់ ប្តូរមុខដំណែង / ប្រាក់ខែរឺក៏អត់ ។

6 **ហេតុផលក្នុងការរៀបការ** – ការផ្លាស់ប្តូរលំនៅដ្ឋានរបស់មនុស្សដែលទើមរៀបការថ្មីៗទៅកាន់ផ្ទះថ្មី ។

7 **ចូលមករស់នៅក្នុងភូមិវិញ**

8 **ត្រឡប់មវិញបន្ទាប់ពីការផ្លាស់កន្លែង** – ទៅកាន់ភូមិ / ប្រទេសបន្ទាប់ពីការ ចាកចេញដោយសារតែសន្តិភាព ហើយនិងស្ថានភាពនឹងនហើយនិងហេតុផលនយោបាយ (ប្រសិនបើចំាបាច់) ។

9 **ផ្សេងៗទៀត** - ហេតុផលដែលអាចកើតមានឡើងផ្សេងទៀតមិនបានលើកឡើងខាងលើ ។

## ***សំរាប់មនុស្សដែលមានអាយុ ៥ឆ្នាំនិងលើសពី៥ឆ្នាំ (បង្គោល 18 - 69)***

**ការធ្វើអន្តោប្រវេសន៏ដើម្បីការងារ (បង្គោល 18 - 25)**

សំណួរទាំងនេះគួតែត្រូវបានសួរសំមនុស្សដែលមានអាយុ២៥ឆ្នាំហើយនិងលើសពី៥ឆ្នាំតែប៉ុណ្ណោះ ។ដើម្បីបញ្ជាក់ថាសមាជិកគ្រួសារដែលបានផ្លាស់លំនៅដ្ឋានដើម្បីការងារត្រូវបានសួរនៅក្នុងបង្គាល 18 ។សំរាប់សមាជិកគ្រួសារមានអាយុ៥ឆ្នាំរឺលើសពីនេះ ចូរសួរថា "តើកាលពី១២ខែមុនតើអ្នកមាន ផ្លាស់លំនៅ ដ្ឋានដើម្បីរកការងារធ្វើបណ្តោះអាសន្នដែររឺទេ?" បើចំលើយថាមានចូរដាក់លេខកូដ "1" ក្នុងកូឡោន 18 ហើយសួរសំណួរក្នុងកូឡោន 19 – 25 ។ បើចំលើយថាមិនមានទេចូរដាក់លេខកូដ "2" ហើយដាក់សញ្ញា (-)នៅក្នុងកូឡោន 19 – 25 ហើយបន្តទៅកូឡោន 26 ។ ចូរបញ្ជាកអោយច្បាស់ក្នុងកូឡោន 19 នូវឈ្មោះរបស់ប្រទេស រឺខេត្តដែលពួកគេបានទៅធ្វើការដោយសួរសំណួរថា : “ការផ្លាសលំនៅដ្ឋានចុងក្រោយ តើអ្នកបានធ្វើការងារនៅកន្លែងណា” ។ ហើយកុងកូឡោន 21 ឈ្មោះរបស់ខេត្ត រឺ ប្រទេសដែល មនុស្ស មកមុនពេលផ្លាស់មកខេត្តប្រទេសដែលអ្នកនោះមកមុនពេលផ្លាស់មកកន្លែងធ្វើការចាប់ផ្តើមពីកូឡោន19 ដោយសួរ ថា : “តើអ្នក ផ្លាស់មក ពីណា” ។

បើអ្នកឆ្លើនមិនដឹងទីកន្លែងសមាជិគ្រួសារមកពីណាទេ ចូរសួរមនុស្សដែលពាក់ព័ន្ធបើសិនជាគាត់មានវត្ត មាននៅ ពេលសំភាសន៍ ។ទោះជាយ៉ាងណាក៏ដោយបើមិនមានចូរសរសេរ "DK" នោក្នុងកូឡោន 19 (20) ។ នៅក្នុង កូលោន 23 សួថា : “តើអ្នកធ្វើការនៅកន្លែងនោះរយះពេលប៉ុន្មាន?” បញ្ជាក ់អោយ បានច្បាស់ពីចំនួនដែលមនុស្សបានធ្វើការនៅកន្លែងនោះ ចូរដាក់ 00 បើសិនជាមនុស្ស ដែលធ្វើការ នៅ កន្លែងនោះតិចជាងន១ខែ ។ ខាងក្រោមនេះគឺជារយះពេលកំនត់ :

1 តិចជាង 2 ខែ → សូមសរសេរលេខ “1”

2 តិចជាង 3 ខែ → សូមសរសេរលេខ “2”

3 តិចជាង 4 ខែ → សូមសរសេរលេខ “3”

4 តិចជាង 5 ខែ → សូមសរសេរលេខ “4”

5 តិចជាង 6 ខែ → សូមសរសេរលេខ “5”

6 តិចជាង 7 ខែ → សូមសរសេរលេខ “6”

7 តិចជាង 8 ខែ → សូមសរសេរលេខ “7”

8 តិចជាង 9 ខែ → សូមសរសេរលេខ “8”

9 តិចជាង 10 ខែ → សូមសរសេរលេខ “9”

10 តិចជាង 11 ខែ → សូមសរសេរលេខ “10”

11 តិចជាង 12 ខែ → សូមសរសេរលេខ “11”

ក្នុងកូឡោន 24, សួរសំណួរ “តើអ្នធ្វើអ្វីនៅក្នុងកន្លែងនោះ?” ។ចូរសរសេរពីការងាររបស់មនុស្សក្នុងកន្លែងដែលសមាជិកផ្លាស់ទៅ ។ចូរព្យាយាមបញ្ជាក់អោយបានច្បាស់តាមតែអាចធ្វើទៅបាន ។ឧទាហរណ៍បើការងារជាអ្នកបើកបរ ចូរបញ្ជាក់ថា អ្នកថាក់សីក្លូ អ្នកបើករថយន្ត ។ល។ ចូរមើលនៅក្នុងសេចក្តីបន្ថែម F សំរាប់បញ្ជីគំរូរបស់ការងារ ។

**ការសិក្សានៅសាលាសព្វថ្ងៃ (កូឡោន 26)**

ចូរសួថា : "តើសព្វថ្ងៃនេះមានសិក្សានៅសាលា សាកលវិទ្យាល័យ វគ្គបណ្តុះបណ្តាលនៅស្ថាបនណាដែរ រឺទេ?" ចូរដាក់លេខកូដ "1" បើមាន ហើយដាក់លេដ "2" បើមិនមាន ។

**កាទទួលបានសញ្ញាបត្រខ្ពស់បំផុត (កូឡោន 27)**

សញ្ញាបត្រដែលទទួលបានខ្ពស់បំផុតសំដៅទៅលើថ្នាក់ខ្ពស់បំផុតដែលបានបញ្ចប់នៅសាលា សាកលវិទ្យាល័យ ។ ចូរសួរសំនួរនៅក្នុងកូឡោន 27 ថា : "តើអ្នកបានបញ្ចប់ការ សិក្សាថ្នាក់ ខ្ពស់បំផុត ក៏រិតណាដែរ ?" សំរាបមនុស្សដែលមានអាយុ៥ឆ្នាំនិង លើសពី៥ឆ្នាំ ។ប្រសិនបើចំលើយដែលផ្តល់អោយ មានលក្ខណះទូលំទូលាយពេកមិនអាចកំនត់ថ្នាក់បាន សូមសួរសំបន្ថែមដើម្បីបញ្ជាក់បន្ថែម ។ បើចំ លើយ ថាបឋមសិក្សា អនុវិទ្យាល័យគឺមិនទាន់គ្រប់គ្រាន់ទេ ។ វាមានសារះសំខាន់ណាស់ក្នុងការដឹងថ្នាក់ឆ្នាំសិក្សានៅបឋមសិក្សារឺនៅអនុវិទ្យាល័យណាមួយដែលពួកគេបានបញ្ចប់ហើយនិងជាប់ ។ ចូរសរសេរបន្ថែមក្នុងកូឡោន27នូវលេខកូដក្នុងចំលើយដែលទទួលបានការអប់រំខ្ពស់បំផុត ។ឧទាហរណ៏ដាក់លេខកូដ "03" បើមនុស្សនោះរៀនចប់តែថ្នាក់ទី៣ ហើយ "05" សំរាប់ថ្នាកទី៥និង "16" សំរាប់អ្នកដែល ទទួល បានបរិញ្ញាបត្រ ។ ប្រសិនបើមនុស្សមិនបានបំពេញថ្នាក់ទាល់តែសោះ ចូរដាក់លេខកូដ "00" បើមនុស្សមិន បានសិក្សាពេញលេញទេចូរដាក់លេខលេខ "88" ចូរបញ្ចូលលេខកូដទៅក្នុងកូឡោនខាងក្រោម :

**00** - មិនបានចូលសិក្សា **09** - ថ្នាក់ទី 9

**88** - អត់មានថ្នាក់សិក្សាពេញលេញ
**01** - ថ្នាក់ទី 1
**02** - ថ្នាក់ទី 2
**03** - ថ្នាក់ទី 3
**04** - ថ្នាក់ទី 4
**05** - ថ្នាក់ទី 5
**06** - ថ្នាក់ទី 6
**07** - ថ្នាក់ទី 7
**08** - ថ្នាក់ទី 8
**10** - ថ្នាក់ទី 10
**11** - ថ្នាក់ទី 11
**12** - សញ្ញាបត្រឌីម្លូម
**13** - ការបណ្តុះបណ្តាលវិជ្ជាជីវះមិនទាន់បានសញ្ញាបត្រ
**14** - ការបណ្តុះបណ្តាលវិជ្ជាជីវះបានសញ្ញាបត្រ
**15** - និស្សិតមហាវិទ្យាល័យមិនទាន់បានសញ្ញាបត្រ
**16** - និស្សិតទទួលបានបរិញ្ញាបត្រ
**17** - និស្សិតដេយឧត្តមសិក្សា
**99** - មិនត្រូវបានរាយការណ៍ / មិនដឹង

## ការចេះអាននិងចេះសរសេរ (កូឡោន 28)

ការចេះអាននិងចេះសរសេរគឺជាសមតភាពដែលអាចអាននិងសរសេរបានក្នុងភាសារឺក៏ភាសាតាមតំបន់ ។មនុស្សដែលអាចអានប៉ុន្តែមិនអាចសរសេរភាសាសមញ្ញត្រូវបានចាត់ទុកថាមិនអាចអាននិងសរសេរ ។
ហើយចំពោះមនុស្សមិនចេះអានឈ្មោះរបស់ពួកផ្ទាល់ក៏ត្រូវចាត់ទុកថាមិនចេះអាននិងសរសេរដែរ ។ មនុស្សដែលចេះអាននិងសរសេរប៉ុន្តែក្នុងពោលចុះសំភាសន៏ពួកគេមិនអាចសរសេរនិងអានបានយូរ ត្រូវចាត់ទុកថាខ្សោយក្រសែភ្នែក ។មនុស្សដែលអាចអាននិងសរសេរតាមរយះអក្សរសំរាប់មនុស្សខ្វាក់បានត្រូវចាត់ទុកថាចេះអាននិងសរសេរ ។

សួរសំណួរក្នុងកូឡោន 28 "តើ អាចអាន និង សរសេរជាភាសារណាមួយ ឬ ជាគ្រាមភាសារបានឬទេ?" សំរាប់អ្នកដែលមានអាយុ ៥ ឆ្នាំ ឬ លើ ៥ ឆ្នា។ សូមដាក់លេខកូដ "1" សំរាប់ មាន, ហើយលេខកូដ "2" សំរាប់ ទេ.

## សកម្មភាពធម្មតាក្នុងរយះពេល ១២ ខែ មុន (កូឡោន ២៩-៣០)

សកម្មភាពការងារទូទៅបានផ្ដល់នូវគំរូសំរាប់ការប្រមូលទិន្នន័យ ដែលអាចប្រើប្រាស់លើគំរូ ដែល ទាក់ទងនិងសកម្មភាពនៃប្រទេស។ នេះគឺជាការទាក់ទងមួយយ៉ាងពិសេស ចំពោះប្រទេសដែលធ្វើកសិកម្ម និង សកម្មភាពដទៃទៀតទៅតាមរដូវនីមួយៗ គំរូនៃសកម្មភាពទាំងនេះពេញមួយឆ្នាំ សមាមាត និង អត្រាប្រជាជន ដែលមានការខុសពី សកម្មភាពបច្ចុប្បន្នដែលផ្ដល់នៅក្នុងចន្លោះ ឆ្នាំនោះ។

**សកម្មភាពសំខាន់ៗក្នុងរយៈពេល ១២ ខែ ក្រោយ (កូឡោន 29)**

សំណួរនេះ បានធ្វើអោយអ្នកធ្វើការជ្រើសរើសអ្នកដែលមានជីវភាពសមរម្យ ឬ ល្អបំផុតសំរាប់ ១២ ខែក្រោយ។ អ្នកដែលបានធ្វើសំភាសន៍នៅ បង្គោល១ នៅផ្នែកទី៣ ដែលបង្ហាញពីសកម្មភាពជីវភាព ដែលមាននៅកូដ ៤ ដល់ ៩ គឺជីវភាពមិនធម្មតា។ ចំពោះអ្នកដែលសរសេរលេខកូដ ១០ អាច ឬ មិនអាច មានជីវភាធម្មតា ហើយនិងបានជ្រើសរើស នូវក្នុងសំណួរបន្ទាប់ (កូឡោន ៣០)។

សួរសំណួរនេះទៅកាន់អ្នកឆ្លើយ ***"តើមាន សកម្មភាពសំខាន់ៗអ្វីខ្លះក្នុងរយៈពេល ១២ ខែមុន?*** *"សរសេរក្នុងកូឡោន ២៩ នៅលេខកូដដែលត្រឹមត្រូវដែលមានបង្ហាញនូវខាងក្រោមសំណួរ។ ប្រសិនបើគាត់មានចំលើយច្រើន សូមកត់ត្រាតែចំនុចសំខាន់មួយដែលគាត់បានធ្វើក្នុងរយៈពេល ១២ ខែមុន។ ប្រសិនបើចំលើយគាត់មានទាក់ទងនិងបង្គោល ១ ដល់ បង្គោល ៩ ចូលសរសេរលេខកូដក្នុង កូឡោន ២៩ ហើយ បន្តទៅកូឡោន៣១។*

លេខកូដនៃសកម្មភាពសំខាន់ៗសំរាប់រយៈពេល ១២ ខែមុន មានដូចខាងទេកាម :

1 ធ្វើការសំរាប់រកនូវការចំណាយក្នុងផ្ទះ, រកចំណូលសំរាប់គ្រួសារ (រួមទាំងសកម្មភាពកសិកម្ម ដូចជា ការដាំបន្លែសំរាប់បរិភោគខ្លួនឯងផ្ទាល់, បរបាញ់, នេសាទត្រី និងការងារជួយដល់ សកម្មភាពសេដ្ឋកិច្ចក្នុងក្រុមគ្រួសារ ដោយមិនទទួលប្រាក់ឈ្នួល) → *(នៅចំនុចនេះ រួមបញ្ចូលទាំងអ្នកដែលមានអាយុ ៥ឆ្នាំឡើងទៅ និងមានកំលាំងកំហែងសំរាប់ការងារ ទាំងនេះ (ទាំងនេះគឺជាការ រកកំរៃ, សំរាប់ការចំណាយ, រកចំណូល, រកប្រាក់ និងចែករំលែគ្នា) ការជួយគ្នាទៅវិញទៅមក*

*ជាលក្ខណៈគ្រួសារ ហើយទទួលបាន ឬមិនទទួល នូវប្រាក់កំរៃនោះ ដែលមាន* ការដាំបន្លែសំរាប់បរិភោគខ្លួនឯងផ្ទាល់, បរបាញ់, នេសាទត្រី។ ដូចនេះរួមបញ្ចូលទាំងអ្នកដែលមានការងារធ្វើ និងអ្នកដែលមិនមានការធ្វើផងដែរ។

2 ការងារដែលមានលក្ខណៈជាកូនជាង → *(ផ្នែកនេះ រួមបញ្ចូលទាះកុមារដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ ដែលធ្វើការតាមការបញ្ជារធ្វើ និងរៀនធ្វើការងារទាំនោះទៅតាមជំនាញ។ អ្នកទាំងនោះពុំមាននូវប្រាក់ខែជាក់លាក់នោះទេ គឺទទួលបានជាប្រាក់បន្តិចបន្តួចតែប៉ុន្នោះ)*

3 ការងារជាជាងសំណង ( **រួមទាំងការជួសជុល ផ្ទះ/ជង្រុកស្រូវ ផងដែរ** ) → ការងារនេះគឺជាការកសាង ជួសជុល នូវផលិតផល របស់របរ ដែលជាកម្មសិទ្ធ។

4 **ការថែរក្សាផ្ទះផ្ទាល់ខ្លួន** → *(សេវាកម្មបំរុងនៅក្នុងគ្រួរសាដោយមិនបាច់បង់ប្រាក់។ ឧទាហរណ៏ ការថែទាំក្មេង១ ការចំអិន ការបោកគួកសំលៀកបំពាក់ រឺការលៀងចាននៅក្នុងផ្ទះ ។)*

5 **ការធ្វើការអោយនណាម្នាក់ដោយមិនបាច់បង់ប្រាក់**→ *(សេវាបំរុង សំរាប់គ្រួសារ ដោយមិន បាច់បង់ ប្រាក់ដូចជាការថែទាំកុមារអោយសាច់ញាតិ ការចំ អិនបោកគួកនិងលៀងចាន សំរាប់សមាជីកគ្រួសារ)*

6 **សិស្សសាលា** → *(មនុស្សដែលចូលសិក្សានៅស្ថាបនក្នុងរយះពេល១២ខែមុន)*

7 **សេវាកម្មពីសហគមន៏ដែលមិនបាច់បង់ប្រាក** / **សេវាកម្មស្ម័គ្រចិត្ត** → *(ផ្នែកនេះ បញ្ចូលមនុស្ស ដែលបានធ្វើការនៅអង្គការក្រៅរដ្ឋាភិបាលហើយនិងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគម៏ដោយមិនបង់កំរៃ)*

8 **ការចូលនិវត្តន៏**→ *(រួមបញ្ចូលទាំងមនុស្សដែលចាស់ខ្លាំងធ្វើ ការដូចជាអ្នក ទោស ដែលមិនមែនជា ការងារយកកំរៃក្នុងអំឡុងពេល១២ខែមុន)*

9 **ពិការភាព** → *(មនុស្សដែលមិនអាចធ្វើការបានព្រោះពិការភាព)*

10 **អត់មានការងារធ្វើ→** (រួមបញ្ចូលទាំអ្នកដែលមិនធ្វើការងារពីព្រោះតែពួក គេមិន ត្រូវបាន គេ ជួលធ្វើ ការ រឺ ក៏ខ្ចិច្រអូសអស់រយះពេលជាច្រើនឆ្នាំ)

**ភាពរកការងារធ្វើក្នុងរយះពេល១២ខែមុន (កូឡោន 30)**

ចូរសួរអ្នកឆ្លើយនៅក្នុងផ្ទះនីមួយៗនៅក្នុងរយះពេល៥ឆ្នាំរឺច្រើនជាងដែលមិនធ្វើការងាររយះពេល១២ខែមុន (លេខកូដ 10 ក្នុងបង្គោល 29) "ទោះបីជាមិនបានធ្វើការ ក៏ដោយតើគាត់អាច ស្វែងរក ការ ងារដែររឺទេ?" ចូរដាក់លេខកូដ "1" បើអាចហើយដាក់លេខកូដ "2" បើមិនអាច។ ក្នុងសំនួរនេះតើមនុស្សអាច ត្រូវបាន ចាត់ទុកថាដែលចង់ធ្វើការតែមិនមានការងារធ្វើក្នុងរយះពេល១២ខែ (ប្រសិនបើចំលើយថា “បាទ”)

**ចំនួនថ្ងៃពិតប្រាកដដែលធ្វើការកាលពីខែមុន (កូឡោន 31)**

សួរសំណួរ“តើអ្នកធ្វើការរយះពេលប៉ុន្មានកាលពីខែមុន?”ចូរបង្គោលនេះនូវចំនួនថ្ងៃធ្វើការសរុបដែលមនុស្សបានធ្វើកាលពីខែមុន ដោយមិនគិតអំពីចំនួនម៉ោងដែលមនុស្សធ្វើការក្នុង១ថ្ងៃនោះទេ។ ចំពោះមនុស្សដែលមិនបានធ្វើការទាល់តែសោះរយះពេល១ថ្ងៃក្នុងអំឡុងពេលថ្ងៃ។

**សកម្មភាពថ្មីៗកាលពីសប្តាហ៍មុន (កូឡោន 32 - 34)**

**សកម្មភាពទាំងអស់កាលពីសប្តាហ៍មុន (កូឡោន 32)**

" ***ការងារទាំងអស់ដែលត្រូវធ្វើ*** "

គោលបំណងនៃការអង្កេតទាំងនេះគឺមានគោលបំណងអោយ អ្នកកត់ត្រានូវកន្លែងធ្វើការនិងសកម្មភាពធ្វើការ ទាំងនោះ យ៉ាងហោចណាស់ក៏មួយម៉ោងដែលមាន តាមតារាងការងារក្នុងសប្តាហ៍។

ការងារមាន ដូចជា សកម្មភាពសេដ្ឋកិច្ចផ្សេងៗដែលអ្នកធ្វើសំរាប់ការចាយវាយជាសាច់ប្រាក់ នៅក្នុងគ្រឹះស្ថាន, ករិយាល័យ, កសិដ្ឋាន, ឬ សំរាប់ចំណូល ចំពោះក្រុមគ្រួសារ ឬ សហគ្រាសហ៏។ សួរសំណួរដើម្បីធ្វើការស្ទង់មើល ដើម្បីរកនូវចំលើយត្រឹកត្រូវ

សំរាប់ការងារនោះ ឬ បុគ្គលិក ឬ ការងារដែលគ្មានប្រាក់ចំណូល សំរាប់ក្រុមគ្រួសារ កសិដ្ឋាន ឬសហគ្រាស ក្នុងរយៈពេលមួយសប្តាហ៍មុន។

សួរអ្នកឆ្លើយនូវសំណួរនេះ " ***តើ មានធ្វើការគ្រប់សកម្មភាព រួមទាំងការងារ មួយម៉ោង១ កាលពីសប្តាហ៍មុន សំរាប់ការចំណាយ ឬ ការកើនឡើងនូវចំនួនគ្រួសារ ឬដើម្បីជួយ កសិដ្ឋានខ្លួនឯង ឬទេ?*** " សរសេរលេខកូដ "១" សំរាប់ចំលើយ បាទ ហើយបន្តទៅកូឡោន ៣៥។ ផ្ទុយមកវិញសរសេរលេខកូដ "២" សំរាប់ចំលើយថា ទេ។

## សកម្មភាពសេដ្ឋកិច្ចផ្សេងទៀតកាលពីសប្តាហ៍មុន (កូឡោន 33)

នេះគឺជាសំណួរស្ទង់មតិដើម្បីធ្វើការសំរាច់ចិត្តចំពោះអ្នកដែលធ្វើការផលិត និង អ្នកប្រតិបត្ត ផលិតផលតំបូង សំរាប់ការលក់ឬការប្រើប្រាស់។ ចំណាំថា "ការងារ" រួមបញ្ចូលគ្រប់ប្រភេទ យ៉ាងទៀងទាត់នៃផលិតផលគ្មានទីផ្សា ឈ្មោះ : ជាផលិតផលតំបូង សំរាប់ការប្រើប្រាស់ (ដូចការកើនឡើងនៃការធ្វើសួនច្បារ ឬ ការចិញ្ចឹមបក្សី ឬ បសុសត្វ) ការប្រតិបត្តការចំពោះ ការប្រើប្រាស់នោះ (ដែលមានដូចជា អាំងបន្លែសំរាប់ការប្រើប្រាស់) និងផលិតផលដែលគេប្រើ ដូចជា អចលនវត្ថុវិញមាន (ដូចជា អាគារ ផ្ទះ ឬអង្ករ ស្រូវ) ហើយរបស់ដែលមិនរាប់បញ្ចូល វិញមានដូចជា សេវាដែលមិនបានបង់ ដូចជា ការចំអិនម្ហូម និង ការមើលថែក្មេង។

នៅក្នុងកូឡោននេះ សួរអ្នកឆ្លើយអំពីពតិមានជុំវិញផ្ទះសំបែង "***កំឡុងពេលសប្តាហចមុន , តើ អ្នកមានធ្វើការ ដូចខាងក្រោមនេះឬទេ : ការដាំដុះ កសិផល ឬដំណាំបន្លែ, ការចិញ្ចឹមសត្វ ឬ មាន់ ទារ, ការសំអាត, ការភ្ជួររាស់ដី, ការរកឧស, ការបរបាញ់, ចាប់ត្រី, ត្បាញ, ធ្វើកញ្ចែង ឬមួក?*** " បើសិនជា បាទ សរសេរលេខកូដ "១" ហើយបន្តទៅកូឡោន ៣៥ បើចំលើយផ្ទុយសរសេរលេខកូដ "២" សំរាប់ចំលើយ ទេ។

## សំរាប់ ការងារ/បុគ្គលិក ពេលមួយសប្តាហ៍មុន (កូឡោន 34)

សំណួរនេះ ***"តើអ្នកមានការងារធ្វើ ឬជាបុគ្គលិកការងារ កាលពីសប្តាហ៍មុនឬ?"*** បើសិនកូដ នៅក្នុងកូឡោន ៣២ និង ៣៣ គឺ "២" (ទេ) អ្នកខ្លះប្រហែលជាមិនមានធ្វើការនៅក្នុងរយៈពេល សប្តាហ៍មិនទេ ប៉ុន្តែប្រហែលជាមានការងារឬជាបុគ្គលិកបណ្តោះអាសន្ន ដែលមិនបានកត់ត្រា ដូចក្នុងករណីខាងក្រោម :

√ ជាបណ្តោះអាសន្ន មានជំម្ងឺ/របួស ក្នុងពេលបំពេញការងារ ឬទេ

√ ក្នុងឱកាសវិសមកាល

√ ក្នុងឱកាសសំរាកណាមួយ

√ ជាបណ្តោះអាសន មិនធ្វើការ ចំហោះ ការទទួលខុសត្រូវ បុគ្គល/គ្រួសារ

√ ក្នុងឱកាសពេលច្បាប់កាសិក្សា (ក្រៅកន្លែងធ្វើការ)

√ អ្នកដែលមានការងារធ្វើបន្ទាប់ពីធ្វើការសំភាសន៍រយៈពេល ២ សប្តាហ៍

អ្នកទាំងនេះគឺត្រូវស្ថិននៅពិចារណាជាបុគ្គលិក ដែលពួកគេមិនបានធ្វើការក្នុងឱកាសខាងលើ។ ដូច្នេះចូរសរសេរលេខកូដនៅក្នុងកូឡោន គឺលេខ "1" (មាន).

ប្រសិនបើអ្នកឆ្លើយប្រាប់ថា ចំនួនសមាជិកគ្រួសារអត់មានការងារ/បុគ្គលិក ចូលសរសេរលេខ កូដ "២" ហើយបន្តទៅកូឡោន ៦៨។

## សំរាប់អ្នកដែលមានអាយុចាប់ពី ៥ ឆ្នាំឡើង និងអ្នកមានការងារធ្វើ ឬ ជាបុគ្គលិក មុនមួយសប្តាហ៍កន្លងមក (កូឡោន ៣៥-៦៧)

កូឡោន ៣៥ រហូតដល់ ៦៧ គឺត្រូវបំពេញសំរាប់អ្នកទាំងនោះដែលបានធ្វើការ ឬ មានកាងារធ្វើ/ជាបុគ្គលិក ក្នុងរយៈពេលមួយសប្តាហ៍មុន។ សំរាប់អ្នកដែលមិនបានធ្វើ ("២" ក្នុងកូឡោន ៣២ និង ៣៣) និង គ្មានការងារ/មិនមែនជាបុគ្គលិក ក្នុងពេលសប្តាហ៍មុន ("2" ក្នុងកូឡោន 34) គូរបន្ទាត់ឈរមួយពី កូឡោន 35 ទៅ 67 ហើយរំលងទៅកូឡោន 68.

**ការងារតំបូង ( កូឡោន ៣៥)**

ប្រសិនបើកត់ត្រាពតិមាននៅក្នុងកូឡោន ៣២, ៣៣ ឬ ៣៤ ដែលមានតំលៃស្មើ "១" (បុគ្គលិក) នោះ កូឡោន ៣៥ ត្រូវតែមានពតិមានលំអិតពីអ្នកដែលមានអាជីពតំបូង។ ដូច្នេះសូមសួរនូវ សំណួរនេះ "តើអ្នកមានអាជីពតំបូងក្នុងពេលមួយសប្តាហ៍មុនឬ?"

អាជីពគឺយោងទៅតាមប្រភេទនៃការងារ ការលក់ដូរ ឬ ជាគ្រូបង្រៀន ដែលអ្នកទទួលប្រតិបត្តិ ក្នុងកំឡុងពេលមួយសប្តាហ៍មុន ដូចជា កសិករ គ្រូពេទ្យ គ្រូបឋមសិក្សា ជាងឈើ សំអាងការ ជាងអ៊ុតសក់ ។ល។ ក៏ប៉ុន្តែប្រសិនបើគាត់មិនធ្វើការងារនៅកន្លែង តែគាត់ធ្វើការនៅផ្ទះ ឬកន្លែង ផ្សេងទៀតនោះ អាជីពក៏យោងទៅតាមប្រភេទនៃការងារនោះនៅពេលដែលគាត់បានធ្វើរបាយការណ៍ សំរាប់ការងារមួយនោះ ឬ ប្រសិនបើគាត់មានការរងចាំសំរាប់ការងារថ្មីដែលនិងត្រូវ ចាប់ផ្តើមធ្វើនៅ សប្តាហ៍ទី ២ បន្ទាប់ពីថ្ងៃធ្វើសំភាសន៍នោះ។

ក្នុងករណីនេះចំពោះអ្នកដែលមានការងារ ឬអាជីពចាប់ពី ២ ឡើងទៅ តំបូងត្រូវពិនិត្យលើម៉ោងការងារទិមួយ និង ការងារទី២ របស់គាត់ (ដែលនិងត្រូវសួរនៅក្នុងកូឡោន ៥០) ជាមួយម៉ោងផ្សេងៗទៀតដែលត្រូវបានបែងចែក។ ម្យ៉ាងទៀតបើសិនជាសកម្មភាពការងារនោះ មានម៉ោងធ្វើការស្មើៗគ្នា ត្រូវពិនិត្យលើប្រាក់ចំណូលពីការងារនោះ ចាប់ពីខ្ពស់មកទាប តាមលំដាប់។

**លេខកូដសំរាប់កាងារ ( កូឡោន ៣៦)**

កូឡោនទី ៣៦ គឺ សំរាប់ការិយាល័យប្រើ។ មិនសរសេរអ្វីនៅក្នុងកូឡោននេះទេ។

**ប្រភេទនៃសកម្មភាពសេដ្ឋកិច្ច រឺ ឧស្សហកម្ម (កូឡោន 37)**

ការងារដែលបានរាយការណ៍ក្នុងកូឡោន 37 គួរតែត្រុវដាក់ជា ថ្នាក់ទៅតាម ប្រភេទសេដ្ឋកិច្ច និង ឧស្សាហកម្ម។ ចូរសួរថា : "តើអ្នកធ្វើការនៅក្នុងឧស្សា ហកម្មណាកាលសប្តាំមុន?" នៅក្នុង ផ្នែកនេះអ្នកគួរតែ

ប្រឹងប្រែងអោយអស់ពីសមត្ថភាពធ្វើអោយអ្នកផ្តល់ចំលើយឆ្លើយពីស្ថានភាពការងាររឺប្រភេទការងារដូចជា កសិដ្ឋាន ការនេសាទ រោងចក្រផលិតប្លាស់ស្ទិច សាលា ។ល។ចូរសរសេរ ចំលើយនៅក្នុងកូឡោន 37 ប្រភេទ ជំនួញសំរាប់ការងារដំបូងរបស់ពួកគេ។ មិនត្រូវយកចំលើយ ឈ្មោះក្រុមហ៊ុន ដូជា JMK Technologies, Phnom Penh Supply Co. ។ល។ ព្រោះពួកគេ មិនចំបាច់រៀប រាប់ក្នុងការរៀបរាប់អំពីសកម្មភាព សេដ្ឋកិច្ចរឺឧស្សាហកម្ម។ ចូរព្យាយមធ្វើអោយអ្នកឆ្លើយផ្តល់ពត៌មានអំពីផលិតផលរឺក៏ប្រភេទសេវាកម្មដែលក្រុមហ៊ុនត្រូវជាប់ទាក់ទងឧទាហរណ៏ការលក់កំព្យូទ័រ។ លើសពីនេះទៅទៀត បើការងារត្រូវស្វែងរកនៅក្នុងក្រុមហ៊ុនដែល ទាក់ទង់ទៅ និង សកម្មភាពច្រើនប្រភេទ រាយការណ៏ប្រភេទសកម្មភាពជាក់លាក់ របស់ក្រុមហ៊ុនដែល មនុស្ស កំពុងធ្វើការ។

បើការងារនៅការិយាល័យ រដ្ឋាភិបាល រឺ ស្ថាបន ការិយាល័យ សាលារដ្ឋ។ ល។ ប្រហែល ជា ត្រូវទទួល ស្គាល់ជា EDC ។ បើការងារជានាយកប្រតិបត្តិសាខាក្នុងជួររដ្ឋាភិបាលក្នុងស្រុក ចូរបង្ហាញថាតើវាជា លក្ខខេត្ត ស្រុក និងឃុំ។

**លេខកូដសំរាប់ប្រភេទសកម្មភាពសេដ្ឋកិច្ច រឺឧស្សាកម្ម (កូឡោន 38)**

កូឡោន 38 សំរាប់តែការប្រើប្រាស់ក្នុងការិយាល័យ ។កុំសរសេរអ្វីទាំងអស់នៅក្នុងផ្នែកនេះ។

**លក្ខណះនៃភាពមានការងារធ្វើ (កូឡោន 39)**

ចូរសួរពីលក្ខណះនៃភាពមានការងារធ្វើនៅក្នុងការងារដំបូងរបស់គេ "តើការងាររបស់អ្នកមានលក្ខណះដ្អយ៉ាងដូចម្តេច?" ចូរដាក់លេខកូដចំពោះលក្ខណះនៃការងារ :

1 ជាអចិន្ត្រៃ

2 រយះពេលខ្លី

3 តាមរដូវ/ តាមវិមកាល

4 ធ្វើការជូននិយោជក់មួយថ្ងៃ១/ មួយសប្តាហ៏១

5 ផ្សេង១

**ស្ថានភាពនៃបុគ្គលិក ( កូឡោន. 40)**

ប្រភេទរបស់បុគ្គលិក យោងទៅតាមស្ថានភាពនៃសកម្មភាពសេដ្ឋកិច្ចដែលគោរពតាមបុគ្គលិក ដែលគាត់អាចជា បុគ្គលិក, ម្ចាស់គណនី, បុគ្គលិកធម្មតា, បុគ្គលិកដែលជាគ្រួសារ ឬ ជាសមាជិកសហប្រតិបត្តការណ៍ កាលពីសប្តាហ៍មុន ។

សួរសំណួរនេះទៅកាន់អ្នកឆ្លើយថា "តើអ្នកជាបុគ្គលិកប្រភេទណាមួយ?" សូមសរសេរលេខកូដ សំរាប់បញ្ជាក់ពីស្ថានភាពដូចខាងក្រោម :

1 **និយោជិក —** ជាអ្នកប្រតិបត្តនូវសហគ្រាសសេដ្ឋកិច្ចរបស់គាត់ផ្ទាល់ ហើយស្ថិតនៅឯករាជ្យភាព ជាអ្នកជំនាញ ឬពាណិជ្ជកម្ម និងជួល បុគ្គលិកជាច្រើន រួមទាំងបងប្អូនក្រុមគ្រួសារផងដែរ ។

ការជួយបន្តិចបន្តួច ពីក្រុមគ្រួសារ និងអ្នកផ្ទះ ចំពោះការបើកសេដ្ឋកិច្ចជាលក្ខគ្រួសារនេះ និងការចំណាយពេល សំរាប់សកម្មភាពទាំងនេះ ដែលមិនបានជួលបុគ្គលិកនោះ ។ ហេតុនេះ កសិដ្ឋានមួយត្រូវផ្តល់នូវអ្នកជួយជាច្រើន ដើម្បីតំណើការបានល្អ ។

អ្នកគ្រប់គ្រងកន្លែងលក់ ត្រូវគ្រប់គ្រងទាំងអស់ដែលមានដូចជា ការចំណាយមិនទាន់ទទួលជាមួយ បងប្អូន ញាតិសណ្តានរបស់គាត់ ឬបុគ្គលិកដែលជាជាងឈើក្នុងការសាងសង់អាគារសំរាប់ទុកឥវ៉ាន់ (ដែលរត្ធូវផ្គត់ផ្គង់ សំរាប់ការងារនោះ) មិនមែកសំរាប់បុគ្គលិកទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកត្រួតពិនិត្យមាននូវ ដៃគូរប្រកួតប្រជែងធំៗសំរាប់ការសាងសង់ ដើម្បីបំពេញតំរូវការដែលត្រូវការនោះ អ្នកត្រួតពិនទិត្យក៏ជា បុគ្គលិកដែរ ។

2 **ម្ចាស់ភាគហ៊ុនផ្ទាល់ –** ជាអ្នកត្រួតពិនិត្យនូវសកម្មភាពសេដ្ឋកិច្ចសហគ្រាសរបស់គាត់ផ្ទាល់ ដែលស្ថិតនៅ ឯករាជ្យ ក្នុងអាជីពឬ ពាណិជ្ជកម្មនេះ ហើយគឺមិនមាននូវការជួលបុគ្គលិកឡើយ ។

3 **បុគ្គលិកការងារ–** ជាអ្នកដែលធ្វើការសំរាប់សាធារណៈ ឬ ឯកជន និងទទួលបាននូវកំរៃ ជាប្រាក់ខែ, ទទួលប្រាក់ជាភាគរយ, ប្រាក់ទឹកតែ, ចំណែកមួយនៃអត្រាប្រាក់ ឬទទួលបានជាប្រាក់លើកទឹកចិត្ត ។

នៅក្នុងបង្គោលនេះមានរួមបញ្ចូលប្រភេទផ្សេងៗដូចខាងក្រោម :

a. អ្នកដែលធ្វើការតាមផ្ទះក្នុងស្រុកមានដូចជា ចុងភៅ, អ្នកថែសួន, អ្នកបើកឡាន, ។ល។
b. អ្នកធ្វើការសំរាប់គ្រឹស្ថាន/សហគ្រាស ឯកជន ដូចជា :
    - ការងារដែលធ្វើទៅលើគំរោង
    - ធ្វើជាអ្នកបើកបរសាធារណៈ
    - ធ្វើការនៅផែស្ងួត
    - ទទួលខុសត្រូវលើការបញ្ជូនទំនិញតាម ផ្លូវរថភ្លើង ឬតាមផែ
    - ទទួលខុសត្រូវលើការបង់ប្រាក់
c. ធ្វើការសំរាប់ក្រុមសាសនា, អ្នកផ្សាយសាសនា, សហគម និងអង្គការមិនរកប្រាក់ចំណូល
d. អ្នកធ្វើការសំរាប់រដ្ឋាភិបាល
e. ធ្វើការនៅស្ថានទូតខ្មែរ,
f. ខ្មែរធ្វើការនៅអង្គការអន្តរជាតិ ដូចជា សហរដ្ឋអាមេរិច្ឋ និង អង្គាសុខភាពពិភពលោក ។ល។
g. អ្នកធ្វើការដែលមានទំនាកទំនងខ្សោយ និងត្រូវធ្វើការតាមម៉ោងជាក់លាក់ណាមួយ ។

4 **អ្នកធ្វើការដែលមិនទទួលប្រាក់ចំណូល–** ជាធម្មតាគឺជាអ្នកមិនត្រូវបានឱ្យប្រាក់ខែតាមសហគ្រាស សេដ្ឋកិច្ចទេ គឺតាមការចំណាយនិងការរស់នៅក្នុងផ្ទះវិញ ហើយប្រាក់ដែលឱ្យនោះមានលក្ខណៈដូចជា ការលើកទឹកចិត្ត ដែលមិនរាប់ដូចជាការទូតាត់ឡើយ ។

5 **ផ្សេងទៀត–** បទពិសោធន៍ការងារនិង សកម្មភាពទាំងនោះមិនត្រូវបានបង្ហាញឬមិនគ្រប់គ្រាន់ក្នុងការ ពិពណ៌នា និង អ្នកគ្មានការងារធ្វើមិនធ្លាប់មានការងារពីមុន (ឧទាហរណ៍ អ្នកប្រកួតប្រថែងថ្មី, អ្នករៀនធ្វើការ)

សំរាប់អ្នកដែលធ្លាប់មានការងារធ្វើច្រើនកាលពីសប្តាហ៍មុន, ហើយអ្នកមានគេស្គាល់ច្រើន សំរាប់ធ្វើការសំរាច់ចិត្តក្នុងឱកាសលើកទីមួយ/លើកទីពីរ ។

**រង្វាន់ (កូឡោន 41-47)**

ក្នុងសំណួរនេះចង់ដឹងពីរង្វាន់ដែលបុគ្គលិកទទួលបាន (លេខកូដ ៣ ក្នុង កូឡោន ៤០) សំរាប់ការងារតំបូង។ ឧទាហរណ៏ ដូចជាការអនុញ្ញាតិអោយផ្ទះស្នាក់នៅសំរាប់បុគ្គលិក ឬកន្លែងស្នាក់នៅ សំលៀកបំពាក់ និង ការអនុញ្ញាតិផ្សេងៗ។ ក្នុងការសួរនូវសំណួរទាំងនេះ ក្នុងកូឡោន ៤១-៤៧ ប្រាប់ទៅកាន់អ្នកឆ្លើយថា អ្នកនិងត្រូវបានរង្វាន់ពីការងាររបស់អ្នក (បញ្ជាក់ថាការផ្ដល់អោយនេះគឺបានពី កន្លែងធ្វើការរបស់អ្នក)

**ប្រាក់ខែប្រចាំខែ (កូឡោន 41)**

សួរនូវសំណួរ ***"តើអ្នកទទួលបានប្រាក់ខែប៉ុន្មានសំរាប់ការងារនេះ?*** ". សំរាប់ចំណូលប្រចាំថ្ងៃ សួររកប្រាក់ប្រចាំថ្ងៃនិងចំនួនថ្ងៃដែលបានធ្វើការក្នុងខែមុន បន្ទប់មកគណនាប្រាក់ប្រចាំថ្ងៃទៅតាមចំណួនថ្ងៃដែលបានធ្វើការ។

**ប្រាក់បន្ថែមកាលពីឆ្នាំមុន (កូឡោន 42)**

សួរសំណួរថា "តើអ្នកទទួលបានប្រាក់បន្ថែមប៉ុន្មាន កាលពីឆ្នាំមុន?" ប្រសិនបើបុគ្គលិកនេះមិន បានទទួលប្រាក់បន្ថែម សរសេរលេខ ០។

**រង្វាន់សំរាប់អាហារ (កូឡោន 43)**

សួរសំណួរថា ***"តើមានរង្វាន់ប្រភេទចំណីអាហារ ឬរបស់ដែលអាចញ៉ាំបានអ្វីខ្លះ ដែលអ្នកបានទទួលកាលពីខែមុន?"***

**រង្វាន់សំរាប់ផ្ទះសំបែង (កូឡោន 44)**

សួរសំណួរថា "តើអ្នកទទួបានរង្វាន់ប្រភេទអ្វីកាលពីខែមុនសំរាប់ផ្ទះនេះរឺទេ?"

**ប្រភេទនៃលាភការី រង្វាន់សំរាប់សំលៀកបំពាក់ (កូឡោន 45)**

សួរសំណួរថា "តើអ្នកបានទទួលបានភាគលាភប៉ុន្មានពីសំលៀកបំពាក់កាលពីខែមុន?"

**លាភការសំរាប់សេវាកម្មផ្នែកវិសាស្ត្រ (កូឡោន 46)**

សួរសំណួរថា “តើអ្នកទទួលបានលាភកាប៉ុន្មានចំពោះផ្នែកវិជ្ជសាស្រ្តកាលពីខែមុន?”

**ប្រភេទលាភកាផ្សេងទៀត (កូឡោន 47)**

សួរសំណួរថា “តើអ្នកទទួលបានលាពការផ្សេងទៀតប៉ុន្មានដែរកាលពីខែមុន?” បន្ទាប់មកបន្តទៅកូឡោន 49 ។

**ប្រាក់ចំនូលបានមកពីការរកស៊ី (កូឡោន 48)**

សំនួរនេះត្រូវបានសួរសំរាប់មនុស្សដែលជានិយោជក់ រឺក៏អ្នកដែលរកស៊ីដោយខ្លួន (លេខកូដ 1 ឬ លេខកូដ 2 ក្នុងកូឡោន 40)

**ប្រាក់បន្ថែម/ ប្រាក់កំម៉ាសុងដែលបានទទួល (កូឡោន 49)**

សំរាប់ប្រភេទអ្នកធ្វើការ ចូរសួរថា “តើអ្នកទទួលបានប្រាក់បន្ថែមប៉ុន្មានកាលពីខែមុន?”

**ការងារលើកទីកពីរ (កូឡោន 50-64)**

សំណួរនេះត្រូវបានសួរមនុស្សដែលមានការងារទាំងអស់ ។ ការងារលើកទិ២ ដូចបានអោយនិយ មន័យរួចហើយ គឺសំដៅទៅលើសកម្មភាពសេដ្ឋកិច្ចដោយមានម៉ោងនៃការងារខ្ពស់បំផុតដែលស៊ូប្តូរ ។ ទោះជាយ៉ាងណាក៏ដោយបើសកម្មភាពសេដ្ឋកិច្ចមានសមភាពការងារ ដែលអាចអោយគេទទួលបានប្រាក់ កំរៃច្រើនជាងមុនគឺជាការងារទី២ ។ វិធីក្នុងការសួរសំនួរដែលទាក់ទងនឹងអ្នកដែលមានការងារទី២ គឺដូច ជាការងារទី២ ។ ក្នុងការសួរសំនួរទាក់ទងនឹងការងារទី២ចូររំលឹកអ្នកផ្តល់ចំលើយថាសំណួរទាំងនោះកំពុងត្រូវបានសួរដែលទាក់ទងនិងមនុស្សដែលមានការងារទី២ ។

**ចំនួនម៉ោងដែលធ្វើការកាលពីសប្តាហ៏មុន (កូឡោន 65)**

ចូរសួរថា : “តើអ្នកធ្វើការងារប៉ុន្មានម៉ោងកាលពីសប្តាហ៏មុន” កូឡោននេះគួរតែជាចំនួនម៉ោងដែលមនុស្សធ្វើការដើម្បីរកស៊ីកាលពីសប្តាហ៏មុន ។

បើសិនមនុស្សមិនធ្វើការងារកាលពសប្តាហ៏មុនទោះជាគាត់មានការងារកាលពីសប្តហ៏មុន ការបញ្ចូល

នៅក្នុងគួរតែដាក់លេខ "00" ។

**សំរាប់មនុស្សដែលកំពុងធ្វើស្វែងរកការងារបន្ថែមកាលពីសប្តាហ៏មុន** (កូឡោន **66-67)**

**ការទទួលយកការងារបន្ថែមបាន (កូឡោន 66)**

ចូរសួរអ្នកឆ្លើយថា : "តើមានការងារបន្ថែមទៀតដែរទេកាលពីសប្តាហ៍មុន"ចូរដាក់លេខកូដ "1" បើមាន ហើយបើមិនមានចូរដាក់លេខកូដ "2" សំរាប់ចំលើយឆ្លើយថាមិនមាន ហើយនិងបន្ត ទៅកូឡោន 70 ។

**ការស្វះស្វែងរកការងារបន្ថែមកាលពីសប្តាហ៍មុន (កូឡោន 67)**

បើមនុស្សមានការងារបន្ថែម (លេខកូដ 1 ក្នុងកូឡោន 66) ចូរសួរអ្នកឆ្លើយនូវសំនួរ "តើអ្នកស្វះស្វែងរកការងារបន្ថែមកាលពីសប្តាហ៍មុនដែររឺទេ?" ចូរដាក់លេខកូដ "1" បើឆ្លើយថាមាន ហើយដាក់លេខកូដ "2" បើចំលើយថាមិនមាន បន្ទាប់មកទៀតបន្តទៅកូឡោន 70 បើលលេខកូដ 1 រឺ 2 ។

**សំរាប់មនុស្សដែលមិនត្រូវបានគេជួលអោយធ្វើការហើយដោយគ្មានការងារធ្វើកាលពីសប្តាហ៍កន្លងមក (កូឡោន 68 and 69)**

**ការស្វះស្វែងរកការងារ (កូឡោន 68)**

សួរសំណួរថា: "តើអ្នកស្វះស្វែងរកការងារធ្វើដែររឺទេ?" ចំពោះមនុស្សដែលមាន អាយុ៥ឆ្នាំនិង លើសពី៥ឆ្នាំដែលមិនបានធ្វើការទាល់តែសោះក្នុងសប្តាហ៍កន្លងមក (ដាក់លេខកូដ "2" នៅក្នុងកូ ឡោន32 និង 33) ហើយមិនមានការងារធ្វើកាលពីសប្តាហ៍កន្លងមក (ដាក់លេខកូដ "2" នៅក្នុងកូ ឡោន34) ។ ចូរដាក់លេខកូដ "1" បើមនុស្សស្វះស្វែងរកការងារហើយបន្តទៅកូឡោន 70 ។ក្រៅពី នេះដាក់លេខកូដ "2" ។ សំរាប់មនុស្សដែលបានមានពេលធ្វើការ គាត់ត្រូវមានពេលធ្វើការក្នុង
សប្តាហ៍កន្លងមក ។គាត់មិនត្រូវមានហេតុផលអ្វីដែលបដិសេធនឹងការងារនោះឡើយក្នុងករណីដែលគេផ្តល់ឱកាសការងារក្នុងសប្តាហ៍កន្លងមកលើកលេងតែមានជំងឺបន្តិចបន្តួចប៉ុណ្ណោះ ។
មនុស្សដែលត្រូវនិយាថាបានរកការងារធ្វើបើគាត់មានទិសដៅជាក់លាក់ក្នុងការរកការងារធ្វើ ។ លើស
ពីនេះទៅទៀតគាត់ប្រាកដជាព្យាយាមការពារសុវត្ថិភាពការងាររបស់គាត់ក្នុងពេលដែលកំពុងធ្វើ

ការងារនោះ។ មនុស្សដែលអាចធ្វើការងារបានប៉ុន្តែមិនរកការងារធ្វើគួតែមានចំលើយលេខកូដ "2" នៅ ក្នុងបង្គោល។

**ហេតុផលមិនស្វះស្វែងរកការងារធ្វើ រឺមិនអាចធ្វើការងារបាន (កូឡោន 69)**

សំណួរនេះស្ទង់ដើម្បីធ្វើការរកនូវមូលហេតុចំបងថាហេតុអ្វីបានជាអ្នកមិនជាប់ និង/ឬ មិនធ្វើការ ស្វែងរកការងារធ្វើ។ សួរនូវសំណួរនេះប្រសិនបើចំលើយនៅកូឡោន ៦៨ ឆ្លើយថា លេខ ២។

ប្រើលេខកូដដែលមាននៅខាងក្រោមនៃសំណួរនឹងធ្វើការកត់ត្រានូវហេតុផលដែលអាចទទួលយកបាន សំរាប់ការស្វែងរក ឬមិនរកការងារធ្វើនេះ។ ប្រសិនបើហេតុផលមានផ្សេងពីការផ្តល់អោយ នូវលេខកូដដូចខាងក្រោមនេះ សូមកត់ត្រានូវហេតុផលជាក់លាក់ដែលបាននិយាយ។

1 **ការជឿរជាក់ថាមិនអាចធ្វើការងារបាន-** ប្រសិនបើអ្នកមិនព្រមធ្វើការរកការងារនោះ ព្រោះតែអ្នកជឿរថា ការងារនេះអ្នកមិនអាចធ្វើបានតាមជំនាញរបស់អ្នក ដូចនេះការងារនេះត្រូវបានបោះចោល ឬទទួលបរាជ័យ។

2 **ការរងចាំលទ្ធិផលនៃការ ដាក់ពាក្យសុំធ្វើការ/ការហើយសំភាសន៏ម្តងទៀត-** ប្រសិនបើអ្នកមិនព្រម ធ្វើការស្វែងរក ការងារកាលពីសប្តាហ៏មុនព្រោះតែអ្នកសង្ឃឹមថានឹងទទួលបានការងាររួចហើយក្នុង ការសន្មត់ទុកមុននៅកន្លែងដែលអ្នកបានដាក់ពាក្យសុំការងារធ្វើនេះ អ្នកក៏អាចទទួលនូវការបរាជ័យដែរ ចំពោះការងារនេះ ហើយអ្នកនៅតែរងចាំការឆ្លើយតបនោះ។ ម្យ៉ាងទៀត នៅក្នុងបង្គោលនេះដែរ បានរួមបញ្ចូលនូវចំនុចទាំងនេះ។ ហើយគាត់នៅតែមិនរកការងារថ្មីធ្វើដោយសារតែការរងចាំ ការហៅពី កន្លែងដែលគាត់ស្នើរសុំមុន។

3 **រងចាំចំពោះការចាប់ផ្តើមការងារថ្មី —** ប្រសិនបើអ្នកមិនធ្វើការរកការងារថ្មីកាលពីសប្តាហ៏មុនព្រោះតែ អ្នកមានការត្រៀមសំរាប់ការងារថ្មីរួចហើយ។

4 **ពិការភាព/មានជំងឺ —** ប្រសិនបើមានហេតុផលសំរាប់ការមិនស្វែងរកការងារដោយសារតែអ្នកមិនមាន ការងារ/ជុំនួញ ព្រោះតែអ្នកមានការភ័យក្លាចពីជំងឺរបស់អ្នក។

5 **អសមត្ថភាព —**
អ្នកដែលមិនព្រមធ្វើការស្វែងរកការងារធ្វើព្រោះតែគេមិនមានសមត្ថភាពធ្វើការបាន។

6 ***ភាពចាស់ជរា ឬ ចូលនិវត្តន៍*** – របសិនបើអ្នកគិតថាអ្នកមានភាពជរាហើយ ឬអ្នកធ្វើការអស់រយៈពេលយូរ ណាស់មកហើយ ល្មមនិងចូលនិវត្តន៍នោះ។

7 **ជាសិស្ស ឬ នៅជាប់សិក្សានៅវិទ្យាស្ថននៅឡើយ —** ប្រសិនបើ អ្នកបច្ចុប្បន្នគឺនៅសិក្សា/រៀន ឬ និងត្រូវចូលសាលារៀននៅពេល ៣ខែទៀតនោះ ទើបបណ្តាលឱ្យពុំមានពេល ឬគ្មានឱ្យកាសក្នុងការរកការងារធ្វើនោះ។

8 **ការមិនអនុញ្ញាតិអោយ កុមារ, មនុស្សចាស់ -**
អ្នកដែលមិនអនុញ្ញាតិឱ្យធ្វើការងារ/ស្វែងរកការងារធ្វើ ព្រោះតែគាត់មានភាពជរា ឬស្ថិតក្នុងការថែទាំ។

9 **មេផ្ទះ —** ចំពោះអ្នកដែលជាប់រវល់និងកិច្ចការផ្ទះសំបែងនៅក្នុងផ្ទះរបស់គាត់

10 ផ្សេងៗ ចូរបញ្ជាក់ - ហេតុផលផ្សេងទៀតក្រៅពីខាងលើ

| **សំរាប់សមាជិកមានអាយុ១០ និងលើស ១០ ឆ្នាំ *(កូឡោន 70)*** |
|---|

**ស្ថានភាពគ្រួសារ (កូឡោន 70)**

ស្ថានភាពគ្រួសារសំដៅទៅលើបុគ្គលម្នាក់ៗនៅក្នុងច្បាប់អាពាពិពាហ៏ រឺ តាមប្រពៃណីក្នុងប្រទេស។ វាដូចជា " ស្ថានភាពស៊ីវិល " ជាធម្មតាត្រូវប្រើនៅក្នុងឯកសារជាផ្លូវការណ៏និងឯកជន ឯកសារ ការស្រុស ស្រួលគ្នា។ល។នៅក្នុងប្រទេស។

សំរាប់មនុស្សអាយុ១០ឆ្នាំហើយលើសពី១០ឆ្នាំ ចូរសួរថា :*"តើអ្នករៀបការហើយរឺនៅ?"* ចំពោះ មនុស្សអាយុក្រោម១០ឆ្នាំចូរដាកសញ្ញា“-”នៅក្នុងកូឡោន។

ចូរដាក់លេខកូដនៅក្នុងកូឡោន 70 សំរាប់ស្ថានភាពគ្រួសាររបស់មនុស្សដូច បានរាយការណ៏ដោយអ្នក ឆ្លើយ ។ លេខកូដនិងផ្នែកខុសគ្នាត្រូវបានកំនត់ដូចខាងក្រោម :

1 **មិនដែលរៀបការ** សំរាប់មនុស្សដែលមិនដែលរៀបការ ។

2 **រៀបការ**

សំរាប់មនុស្សដែលបានរៀបការស្របច្បាប់តាមទំនាមទំលាប់ប្រពៃណីក្នុងពេលដែល SESCចុះទៅសំភាសន៏រឺក៏រស់នៅដោយឡែកបណ្តោសអាសន្នពីព្រោះប្តីប្រពន្ធត្រូវបានជូលអោយ ទៅធ្វើការនៅកន្លែងណាមួយរឺក៏នៅក្នុងកងកំលាំងយោធារឺកងប្រដាប់អាវុធ ។ល ។ផ្នែកនេះក៏រួមបញ្ជូលទាំងមនុស្សដែលរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធដោយមិនបានរៀបការស្រមច្បាប់ ។

3 **មេម៉ាយ** សំរាប់មនុស្សដែលប្តីដែលបានស្លាប់ហើយមិនទាន់រៀបការឡើងវិញក្នុងពេលដែល គេ ចុះ ទៅសំភាសន៏ ។

4 **លែងលះគ្នា** សំរាប់មនុស្សដែលអាពាហ៏ពិពាហ៏របស់ពួកគេត្រូវបានលែងលះ ដូច្នេះពួកគេអាច រៀប ការឡើងវិញបាន ។

5 **រស់នៅដាច់ដោយឡែកពីគ្នា** សំរាប់មនុស្សដែលត្រូវរស់នៅដាច់ដោយឡែកពីគ្នាពីប្តីប្រពន្ធដោយ ស្រប ច្បាប់រឺមានការព្រមព្រាងគ្នាទៅវិញទៅមក ។

6 **មិនស្គាល់** សំរាប់មនុស្សដែលស្ថានភាពគ្រួសារមិនស្គាល់ច្បាស់លាស់

## សំរាប់ស្ត្រីមានអាយុ *15* ទៅ *45* ឆ្នាំ*(*កូឡោន *71 - 74)*

**មានផ្ទៃពោះកាលពី២ឆ្នាំកន្លងមក (កូឡោន 71)**

ចូរសួរសំនួរថា : "តើអ្នកមានផ្ទៃពោះកាលពី២ឆ្នាំមុនដែររឺទេរ?" ចំពោះស្ត្រីទាំងអស់ដែលមាន អាយុ 15 ទៅ 45 ឆ្នាំ ។ ចូរដាក់លេខកូដ "1" បើមានហើយដាក់លេខកូដ "2" បើចំលើយថាមិន បន្ទាប់មកដាក់សញ្ញា (-)នៅក្នុងកូឡោន 72 និង 73 ហើយបន្តទៅសមាជិកបន្ទាប់ទៀត ។

**កន្លែងសំរាលកូន (Column 72)**

ចូរសួរសំនួរថា : "តើអ្នកសំរាលកូននៅកន្លែងណា?" សំរាប់ស្ត្រីទាំងអស់ដែលមាន ផ្ទៃពោះកាលពី២ឆ្នាំ មុន។ ចូរដាក់លេខកូដនៅក្នុងកូឡោន 72 សំរាប់ទីកន្លែងមនុស្សសំរាលកូនដូចអ្នកឆ្លើយបានរៀបការ លេខកូដនិងផ្នែកខុស១គ្នាដែលអាចត្រូវបានរកឃើញនៅខាងក្រោមនៃតារាងសំនួរដូចខាងក្រោម :

1 គ្លីនិក/ មណ្ឌលសុខភាព/ មន្ទីរពេទ្យ

2 នៅផ្ទះ

3 នៅផ្ទះអ្នកជិតខាង/ ផ្ទះសាច់ញាតិ

4 ផ្សេង១ទៀត ចូរបញ្ជាក់បន្ថែម

5 មិនបានសំរាលកូន

6 មិនដឹង

បើចំលើយជាលេខកូដ 5 (មិនបានសំរាលកូន), ចូរបន្តទៅកូឡោន 74 ។

**ជំនួយដែលមាននៅក្នុងការសំរាលកូន (កូឡោន 73)**

ចូរសួរសំនួរថា : "តើនណាបានជួយអ្នកក្នុងការសំរាលកូនចុងក្រោយ?" សំរាប់ស្ត្រីទាំងអស់ ដែលមាន ផ្ទៃពោះ កាលពី២ឆ្នាំមុន។ ចូរដាក់លេខកូដ 73 នៃមនុស្សដែលជួយសំរាលកូនដូចបានរាយការណ៍ ពីអ្នកផ្តល់ចំលើយ ។ លេខកូដនិងផ្នែកដែលអាចត្រូវបានគេរកឃើញនៅខាងក្រោមតារាងសំនួរ :

1 ឆ្មប/ វិជ្ជបណ្ឌិត/ គលានុបដ្ឋយិការ

2 អ្នកចុះបញ្ជីកំណើត

3 អ្នកជិតខាង/ សាច់ញាតិ

4 ផ្សេង១ទៀត សូមបញ្ជាក់

5 មិនមាន (ប្រសូត្រដោយខ្លួនឯង)

6 មិនដឹង

**ចំនួនថ្នាំបង្កាជំងឺតេតាណុសដែលបានទទួល (កូឡោន 74)**

សួរសំណួរ : "តើអ្នកទទួលការចាក់ថ្នាំបង្ការជំងឺតេតាណុសប៉ុន្មានដងដែរ?" សំរាប់ស្ត្រីទាំងឡាយ ដែលមានផ្ទៃពោះការពី២ឆ្នាំមុន។

សរសេរលេខកូដក្នុងកូឡោន ៧៤ សំរាប់ការបង្ការជំម្ងឺតេតានុសដែលទទួលបានកត់ត្រាដោយ អ្នកឆ្លើយនូវសំណួរ។ លេខកូដនីមួយៗមានលក្ខណៈផ្សេងៗគ្នាដែលមានបង្ហាញនូវសំណួរខាងក្រោម :

**0** មិនបានធ្វើ

**1** បានធ្វើ ម្តង

**2** បានធ្វើ ពីរដង

**3** បានធ្វើបីដង ឬច្រើនដង

## ផ្នែកទី ៣-ស្តីពីពលកម្មកុមារ-ពីអាយុ ៥ ដល់ ១៧ ឆ្នាំ

ជាផ្នែកមួយនៃការស្ទង់មតិ គឺដើម្បីស្រង់យកពតិមានស្តីពីពលកម្មកុមារក្នុងស្រុក។ ពេលបច្ចុប្បន្នមាន នូវហេតុផលចំបងបី ដែលមានការចាប់អារម្មណ៍ពី អន្តរជាតិ ចំពោះបញ្ហាពលកម្មលើកុមារ : "ទីមួយ, ការយល់ឃើញជាទូទៅថា ពលកម្មលើកុមារមានការកើនឡើង យ៉ាងច្រើនពាសពេញពិភពលោក ហើយនៅតែបន្តអោយមានផលប៉ះពាល់ដូចជា ស្ថានភាពសេដ្ឋកិច្ច និង រារាំនូវការអភិវឌ្ឍន៍សង្គម ជាពិសេសនៅក្នុងតំបន់ ដែលគ្មានការងារធ្វើ និង ការអប់រំ។ ទីពី, ការកើនឡើងត្រូវបានបញ្ជាក់ថាការប្រើកំលាំងកុមារដែលមានអាយុ ចន្លោះ ៥ ដល់ ១៧ ឆ្នាំ មិនត្រូវបានគេប្រតិបត្តិតាមស្តង់ដារជាសកលទេ, ប្រទេសខ្លះបានកេងចំណេញផលប្រយោជន៍ទាំងនេះ ក្នុងវិស័យពាណិជ្ជកម្មអន្តជាតិ ហើយប្រទេសខ្លះទៀតពិបាកក្នុងការធ្វើអោយដូចនឹងស្តង់ដារ, ខ្លាំងពូកែតាមការផ្តាច់ញ្ជាមតិសាធារណៈ ជាជាង ដោយសារតែ បញ្ហាសិទ្ធិមនុស្ស និងសិទ្ធិកុមារ"(Source: ILO)

ករណីនេះបង្ហាញពីការណែនាំ សំណួរលើការធ្វើពលកម្មលើកុមារ ។

☞ ចំណាំ នៅផ្នែកនេះត្រូវបានសួរចំពោះសមាជិកគ្រួសារដែលមានអាយុចាប់ពី ៥ ទៅ ១៧ ឆ្នាំ

**ឈ្មោះកូន១តាមលំដាប់រៀងពីតូចទៅធំ (កូឡោន 1 ហើយ 2)**

ថតចំលងនូវគំរូផ្នែកទី ២ កូឡោន ១ និងកូឡោន ២ នូវចំនុចការឆ្លើយតប នូវចំនួនកូនតាមលំដាប់រៀង ពី ៥ ងល់ ១៧ ឆ្នាំ ទៅក្នុងផ្នែកទី ៣ កូឡោន ១ និង កូឡោន ២។

**កាលវិភាគសាលា (កូឡោន 3)**

សួរសំណួរថា ***"តើ មានវត្តមាននៅសាលា ឬ កន្លែងសិក្សា ឬវិទ្យាស្ថាន បណ្តោះបណ្តាល កាលពីសប្តាហ៍មុន ឬទេ? "*** ប្រសិនបើចំលើយឆ្លើយថា បាទ/ចាស់ ត្រូវសួរទៅរៀនពេញម៉ោង ឬតាមម៉ោងមួយម៉ោង១។ ប្រសិនបើ ពេញម៉ោង រទុវកត់ត្រាលេខ ១ ហើយបន្តទៅកូឡោនទី ៦ តែបើចំលើយឆ្លើយថាតាមម៉ោង វិញ ត្រូវកត់ត្រាលេខ ២ ហើយបន្តទៅកូឡោនលេខ ៦ បើចំលើយថា ទេ កត់ត្រាលេខកូដ ៣ ហើយសួរសំណួរបន្ត។ ចំណាំ សំនួរនេះសួរសំរាប់ វត្តមាន ដែលមាន ក្នុងកាលវិភាគកាលពីសប្តាហ៍មុន។ ប្រសិនបើ ក្នុងសប្តាហ៍មុន មិនមានថ្នាក់ ព្រោះសាលាវាកង/វិសមកាលនោះ ដូច្នេះ ត្រូវឆ្លើយនៅមុនពេលសាលាវាកង/វិសមកាល មួយអាទិត្យមុនពេលបិត។

**ការបោះបង់ការសិក្សា (កូឡោន 4)**

បើកូនមិនបានចូលរៀនកាលពីសប្តាហ៍កន្លងមកចូររកមូលហេតុថាតើហេតុអ្វីបានជាបោះបង់ការសិក្សាដោយសួរថា : "តើអ្នកបានបោះបងការសិក្សារឺ" បើចំលើយថាបានបោះបង់ ចូរដាក់លេខកូដ 1ហើយសួរសំនួរ បន្ទាប់ ទៀត។ បើចំលើយថាទេ ចូរដាក់លេខកូដ 2 ហើយបន្តទោកូឡោន 6 ។

**ហេតុផលក្នុងការបោះបង់ការសិក្សា (កូឡោន 5)**

បើកូនមិនបានចូលរៀនរឺបោះបង់ការសិក្សាចោល ចូរសួរសំណួរ "តើអ្វីជាមូលដ៏សំខាន់ក្នុងការបោះបង់ ការ សិក្សា?" ចូរសេរសេរនៅក្នុងលេខកូដ ។លេខកូដដែលរកឃើញនៅខាងក្រោមតារាងសំនួរដូចខាងក្រោម :

1 មិនមានសាលាសមរម្យសំរាប់ការសិក្សា

2 មិនចាប់អារម្មណ៏និងការសិក្សា

3 តំលៃសិក្សាខ្ពស់ពេក

4 សាលានៅឆ្ងាយពីផ្ទះពេក

5 ជួយធ្វើការងារផ្ទះ

6 ជួយរកស៊ីក្នុងគ្រួសារ

7 ធ្វើការងាររកកំរៃផ្គត់ផ្គង់គ្រួសារ

8 ធ្វើការងារដើម្បីផ្គត់ផ្គង់ខ្លួនឯង

9 មានជំងឺ / ពិការ

10 មូលហេតុផ្សេងទៀត ចូរបញ្ជាក់បន្ថែម

**ធ្វើការសំចាយវាយរឺបង្កើនចំណូលដល់ក្រុមគ្រួសារ (កូឡោន 6)**

សំនួរនេះត្រូវបានសួរកាលពីមុនមកហើយនៅក្នុងផ្នែកទី II ប៉ុន្តែត្រូវការសួរបួងទៀតនៅក្នុងផ្នែកនេះ ដែលអាច ធ្វើអោយអ្នកសំភាសន៏ទទួលបានជោគជ័យក្នុងការសំភាសន៏សំនួរទាំងនេះ ។ម្យ៉ាងវិញទៀត នេះជាស ំនួរ បិទបាំងមួយ ។ ធ្វើបែបនេះមានលក្ខណះងាយស្រួលក្នុងការចំលង ចំ លើយពីផ្នែកទី II ដែលអាចប៉ះពាល់ ដល់ការ សំភាសន៏។ ហើយសំ ភាសន៏ពីមុនអាចមានកំហុសខ្លះៗ នៅក្នុងចំ លើយដែលទទួលបាន ។ ចូរសួរថា “តើអ្នកបានធ្វើការ សូម្បីតែមួយ ម៉ោង កាលពីសប្តាហ៏កន្លងមកសំរាប់ចាយ រឺ គ្រួសារ រឺ ជួយដល់កសិដ្ឋានផ្ទាល់ខ្លួន រឺ ជំនួញក្នុងគ្រួសារ ដោយមិន បាច់យក ប្រាក់ដេរឺទេ” ចូរដាក់លេខកូដ 1 សំរាប់ចំលើយថាបាន ហើយបន្តទៅកូឡោន 9 ចូរដាក់លេខកូដ 2 ចំពោះចំលើយថា មិនបានហើយសួរសំនួរបន្ទាប់ទៀត ។

**ការជួយកិច្ចការក្នុងគ្រួសារ (កូឡោន 7)**

ចូរសួរថា “តើអ្នកបានចូលរៀនរឺទេ ហើយតើអ្នកជួយកិច្ចការផ្ទះរឺថែរក្សាផ្ទះដែលអ្នករស់នៅរឺ?” ចូរដាក់ លេខ កូដ 1 ចំលើយថាបាន ហើយសួរសំនួរបន្ទាប់ ។ បើចំលើយថាមិនបានដាក់លេខកូដ 2 ដាក់សញ្ញា “-”ក្នុងកូឡោន 8 ទៅ 24 ហើយបន្តទៅកូនបន្ទាប់ទៀតនៅក្នុងបញ្ជី ។

**ចំនួនម៉ោងដែលជួយកិច្ចការផ្ទះ (កូឡោន 8)**

សំនួរនេះមានបំណងស្វែងរកចំនួនម៉ោងដែលកូនជួយកិច្ចការក្នុងផ្ទះ។ វាគួរអោយជឿដែរចំពោះ ហានីភ័យខ្លាំងបំផុតចំពោះក្មេងបណ្តាលមកពីការធ្វើការងារលើសម៉ោងគឺមិនអាចទទួលផលប្រយោជន៏ពីការអប់រំ។

ការអប់រំខ្សោយវីគ្រាន់តែជាការបណ្តុះបណ្តាលតាមផ្នែកគឺជាពិការភាពដ៏ធ្ងន់ធ្ងរព្រោះតែឱកាសសំរាប់ការងារអនាគត់កើនឡើងពឹងផ្អែកទៅលើការចេះអាននិងសរសេរហើយនិងជំនាញដ៏ទៃទៀត (ILO) ។

ចូរសួរសំនួរថា : "តើអ្នកជួយធ្វើការផ្ទះប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?" ចូរកំសំគាល់ចំនួនម៉ោង ដែលចំណាយពេលធ្វើ ការ ងារផ្ទះពីមួយថ្ងៃទៅមួយថ្ងៃ។ ក្នុងករណីនេះ ចូរសួរអ្នកឆ្លើយនូវចំនួនម៉ោងដែលក្មេងជាធម្មតាចំណាយ ពេលធ្វើការងារ ចំណាយពេលភាគច្រើននៅផ្ទះ គឺ 1 ប៉ុន្តែតិចជាង 2 ម៉ោង = 1; 2 ប៉ុន្តែតិចជាង 3 ម៉ោង = 2, ។ល។ បន្ទាប់មកទៀតចូរដាក់សញ្ញា "-"នៅក្នុងកូឡោន 9 ទៅ 24 ហើយសួរបន្តទៅក្មេងដ៏ទៃទៀតនៅក្នុងបញ្ជី។

## អាយុក្មេងដែលចាប់ផ្តើមធ្វើការ (កូឡោន 9)

ចូរសួរថា : "តើអ្នកមានអាយុប៉ុន្មានពេលអ្នកចាប់ផ្តើមធ្វើការដំបូង?" ចូរពន្យល់អ្នកឆ្លើយថាការងារនៅ ទីនេះសំដៅទៅលើសកម្មភាពសេដ្ឋកិច្ចដែលក្មេងធ្វើហើយនិងមិនបញ្ចូលក្នុងកិច្ចការផ្ទះទេ។ ចូរបញ្ចូលចំលើយពេញមួយឆ្នាំគឺ 1 ប៉ុន្តែតិចជាង 2 ឆ្នាំ = 1 ។ល។

## មូលហេតុសំខាន់ចំពោះការធ្វើការងារ (កូឡោន 10)

ចូរសួរសំនួរថា:"តើជាមូលហេតុសំខាន់ក្នុងការធ្វើការងារកាលសប្តាហ៍កន្លងមក?"ចូរជ្រើសរើសលេខកូដ ពីមុន ដែលបានផ្តល់នៅខាងក្រោមនៃតារាងសំនួរដូចខាងក្រោម :

1 ស្វែងរកបទពិសោធន៏ / ទទួលការបណ្តុះបណ្តាល

2 បំពេញប្រាក់ចំណូលគ្រួសារ

3 ជួយសងបំណុលគ្រួសារ

4 បង់ថ្លៃសាលា

5 ជួយដល់សហគ្រាសខ្លួនឯង

6 រកប្រាក់កំរៃដើម្បីរកស៊ីផ្ទាល់ខ្លួន

7 ឯករាជផ្នែកសេដ្ឋកិច្ចគ្រួសារ

8 ផ្សេងៗទៀត ចូរបញ្ជាក់បន្ថែម

**កន្លែងធ្វើការ** (កូឡេាន 11)

ចូរសួរសំនួរថា : "តើអ្នកធ្វើការនៅកន្លែងណាកាលពីសប្តាហ៏កន្លងមក?" ម្យ៉ាងទៀត ការងារនៅទីនេះ សំដៅទៅលើសកម្មភាពសេដ្ឋកិច្ចរឺក៏ការងាររបស់កុមារ ។ខាងក្រោមនេះជាចំលើយដូចលេខកូដការពីមុន :

1 ផ្ទះផ្ទាល់ខ្លួន

2 ផ្ទះរបស់នយោជក់

3 ផ្ទះរបស់អ្នកដ៏ទៃ

4 ការិយាល័យ / រោងចក្រ

5 កសិដ្ឋាន

6 ផ្លូវថ្នល់

7 ទីផ្សារ

8 កន្លែងដែលមានគ្រាប់មីន / កន្លែងសាងសង

9 ផ្សេងៗទៀត ចូរបញ្ជាក់

**ការធ្វើការពលយប់ រឺ ពេលល្ងាច (កូឡេាន** 12)

ចូរសួរថា : "ជាធម្មតាតើអ្នកធ្វើការពេលយប់រឺពេលល្ងាច?" បើចំលើយថាធ្វើ ចូរសួរថា តើញឹកញាប់ប៉ុនណា។ ចូរដាក់លេខកូដ 1 បើចំលើយថាញឹកញាប់ ហើយលេខកូដ 2 បើចំលើយថា ជួនកាល ។ចូរដាក់លេខកូដ3បើចំលើយ ថាមិនធ្វើ ។

**ការរកប្រាក់ចំនួល (កូឡេាន** 13)

សំនួរនេះមានគោលបំណងស្វែងរកសមាមាត្រនៃប្រាក់ចំនូលរបស់កុមារដែលត្រូវផ្តល់អោយគ្រួសារ ។ ចូរសួរ អ្នកឆ្លើយថា "បើផ្នែក រឺ ក៏ ទាំងអស់នៃប្រាក់ចំនូលត្រូវបានផ្តល់អោយគ្រួសារ ឱពុកម្តាយ សូមបង្ហាញពីចំនួនប្រហាក់ ប្រហែលដែលបានផ្តល់ទៅគ្រួសារ" ចូរជ្រើសរើសលេខកូដអោយបានសមរម្យសំរាប់ ចំលើយនៅខាង ក្រោមតារាង សំនួរផ។ លេខកូដទាំងនោះគឺ :

1 តំនាងអោយស្មើរតែទាំងអស់ (100%)

2 ប្រហែល 3/4 (75%)

3 ប្រហែល 1/2 (50%)

4 ប្រហែល 1/4 (25%)

5 តិចជាង 1/4 (<25%)

6 មិនផ្តល់ទាល់តែសោះ

**ជំងឺ / ការរបួសដោយសារការងារ (កូឡោន 14)**

កុមារដែលធ្វើការងារភាគច្រើនប្រឈមមុខយ៉ាងខ្លាំងចំពោះរាងកាយដូចជា ការឆ្លងរោគផ្សេងៗ របួស ការ ដាច់រលាត់ មុត ជំងឺសួត។ សូម្បីតែរបរកសិកម្មក៏អាចប៉ះពាល់ដល់កុមារតាមរយៈអាកាសធាតុ សារធាតុគីមី។

ចូរសួរសំថា : "តើអ្នកមានការឈឺចាប់ពីជំងឺ រឺក៏ការរបួសពីព្រោះការងារកាលពីសប្តាហ៍កន្លងមករឺទេ?" បើចំ លើយថាមានចូរដាក់លេខកូដ 1 ហើយសួរសំនួរបន្តបន្ទាប់នៅក្នុងកូឡោន 15-23 បើមិនមានចូរដាក់លេខកូដ 2 ហើយ បន្តទៅកូឡោន 24 ។

**ការងារនិងរបួសខុសៗគ្នា (កូឡោន 15-23)**

ចូរសួរអ្នកឆ្លើយបញ្ជាក់ថា : "តើអ្នកមានការឈើចាប់រឺរបួសអ្វីខ្លះ?" ចូរកត់ត្រាចំលើយទាំងនោះ បន្ទាប់មកជំងឺនិងរបួសដែលបានដាក់សញ្ញារួច ចូរសួរថា "តើអ្នកឈឺចាប់ពីជំងឺញឹកញាប់ប៉ុនណា?" ជំងឺ ការរបួស ដែល បានលើកឡើងគឺគ្រុន (អ្វីក៏ដោយដែលជាបុព្វហេតុដូចជារាគរុស ផ្តាសសាយ ក្រុនពោះវៀន) ការឆ្លងតាមរយៈភ្នែក ឈឺភ្នែកបញ្ហាស្បែក (ដូចជាអាលាក់ស៊ី) បញ្ហាផ្លូវដង្ហើម ឈឺករ ជំងឺខ្វះឈាម ការអស់កំលាំង ជំងឺផ្សេងៗទៀត (ជំងឺអីវក៏ដោយមិនអាចត្រូវបានដាក់តាមផ្នែកដូចជាការរបួស ការមុតផ្សេងៗ ពោះពិសចិក) ។

លេខកូដដែលដាក់ពីមុនគឺ 1សំរាប់ចំលើយថាញឹកញាប់ ហើយលេខកូដ 2 សំរាប់ចំលើយថាយូរៗម្តង ហើយលេខ កូដ 3 សំរាប់ចំលើយថាកំរ។

**ការដឹងអំពីការងារដែលទាក់ទងទៅនិងបញ្ហាសុខភាព (កូឡោន 24)**

ចូរសួរថា : "តើមានការដឹងអំពីបញ្ហាសុខភាពដែលពាក់ព័ន្ធទៅនិងការងាររបស់ពួកគេដែររឺទេ? ចូរដាក់លេខកូដ 1 បើដឹង លេខកូដ 2 បើមិនដឹង លេខកូដ 3 បើចំលើយថាមិនដឹង។

# ផ្នែកទី IV – តារាងសំនួរសំរាប់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ

ផ្នែកនេះផ្តល់ការណែនាំអំពីរបេផបសួរសំនួរដែលទាក់ទងទៅនិងបញ្ហាសុខភាពដែលមានអាយុក្រោម៥ឆ្នាំ ។

| |
|---|
| ☞ ចូរចំណាំថាផ្នែកនេះត្រូវបានសួរសំរាប់តែ កុមារក្រោមអាយុ ៥ ឆ្នាប៉ុណ្ណោះ ។ |

**លេខបន្ទាត់និងឈ្មោះរបស់កុមារ (កូឡោន 1 ហើយ 2)**

ចូរចំលងពីផ្នែក II កូឡោន 1 និង 2 បន្ទាត់ចំលើយរបស់ក្មេងនីមួយៗក្រោម ៥ ឆ្នាំទៅផ្នែក IV កូឡោន 1 និង 2 ។

**អាយុ (កូឡោន 3)**

ចូរដាក់អាយុរបស់កុមារគ្រប់ខែ គឺពី 1 (អាយុ១ខែ) ទៅ 59 (ពីខែ 4 ទៅ 11 ខែ) បើកុមាមានអាយុ 1 ខែហើយច្រើនជាងប៉ុន្តែតិចជាង 2 ខែ ចូរដាក់លេខកូដ "1" ។ល។ បើសិនកុមារមាន អាយុ តិច ជាង ១ ខែចូរដាក់លេខ "0" ។

**ជំងឺរាគរុស (កូឡោន 4 - 12)**

**ការកើតឡើងនៃជំងឺរាគរុស (កូឡោន 4)**

ជំងឺរាគរុសត្រូវអោយនិយមន័យថា ត្រូវបានសង្កេតដោយម្តាយ ឬ មានការរាករុស ច្រើនដងលើសពី ៣ ដង ក្នុងមួយថ្ងៃ ឬមានឈាមនៅក្នុងសាមកនោះ ។

ចូរសួរថា "តើមានជំងឺរាគរុសរឺទេការពី២សប្តាហ៏កន្លងមក?" ចូរដាក់លេខកូដ 1 បើចំលើយថាមាន ដាក់លេខកូដ 2 បើចំលើយថាមិនមាន បន្ទាប់មកបន្តទៅកូឡោន 13 ។

ជាតិទឹកដែលផ្តល់អោយ (**កូឡោន** 5)

ចូរសួរថា "តើត្រូវផ្តល់ជាតិទឹកប៉ុន្មានដែលពេលមានជំងឺរាគរុសកាលពី២សប្តាហ៏មុន?" ចូរដាក់លេខកូដដូចខាងក្រោម :

1 ច្រើន

2 ដូចគ្នា

3 តិច

4 មិនផ្តល់

**អាហារដែលត្រូវផ្តល់អោយ (កូឡោន 6)**

ចូរសួរថា "តើអ្នកត្រូវបានទទួលអាហារប៉ុន្មានពេលមានជំងឺរាគរុសការលពី២សប្តាហ៍មុន?" ចូរដាក់លេខ កូដដូចខាងក្រោម :

1 ច្រើន

2 ដូចគ្នា

3 តិច

4 មិនផ្តល់

**ការវះកាត់រឺការព្យាដែលទទួលបាន (កូឡោន 7)**

ចូរសួរថា "តើអ្នកបានទទួលការព្យាបាលជំងឺរាគរុសដែររឺទេកាលពី២សប្តាហ៍មុន?" ចូរដាក់លេខកូដ 1 បើមាន ក្រៅពីនេះចូរដាក់លេខកូដ 2 ហើយបន្តទៅកូឡោន 13 ។

**ប្រភេទនៃការទទួលបានការព្យាបាល (កូឡោន 8-11)**

នេះគឺជាសំនួរពហុជ្រើសរើស ។ ចូរសួរអ្នកឆ្លើយថា "តើអ្នកបានទទួលការព្យាបាលប្រភេទអ្វីដែរ កាល ពី សប្តាហ៍មុន?" ។ កុំផ្តល់ចំលើយដែលអាចឆ្លើយបាន នោះគឺជាសំណួរសួរផ្ទាល់មាត់ដូចជាការផ្តល់ថ្នាំពំនើប រឺការព្យា បាលផ្សេងទៀត (ថ្នាំខ្មែរ) ។ ចូរងចាំអ្នកឆ្លើយផ្តល់ចំលើយ ។ ឧទាហរណ៏អ្នកឆ្លើយលើកឡើងពី ORS ហើយនិងថ្នាំទំនើប ចូរដាក់លេខកូដ 1 នៅក្នុងកូឡោន 8 និង10 ហើយដាក់លេខកូដ 2 ក្នុងកូឡោន 9 និង11 ។

**តើនណាព្យាបាលកុមារ (កូឡោន 12)**

ចូរសួរថា "តើនណាបានព្យាបាលកុមារក្នុងពេលមានជំងឺរាគរុសកាលពី២សប្តាហ៍មុន? លេខកូដ ដូចខាងក្រោម :

1 មណ្ឌលសុខភាព/បុគ្គលិកនៅមន្ទីរពេទ្យ

2 ថ្នាំសះ

3 អ្នកលក់ថ្នាំ

4 ឪពុកម្តាយ / សាច់ញាតិ

5 ផ្សេងៗទៀត ចូរបញ្ជាក់

**ការបំបៅដោះ (កូឡោន 13-14)**

សួរសំណួរថា "តើអ្នកធ្លាប់បានបំបៅដោះទេ?"សូមដាក់លេខកូដ 1 កូឡោន. ប្រសិន ទេ, សូម ដាក់លេខកូដ 2 ហើយបន្ទាប់មករំលងទៅកូឡោន 16 ។ នៅក្នុងកូឡោន 14 សួរថា "តើអ្នកទទួល ការបំ បៅដោះយូប៉ុន្មាន?" ចូរដាក់លេខបន្ថែមពេញគ្រប់ខែទាំងអស់ ។ បើកុមារអាយុតិចជាង ១ខែចូរដាក់លេខ 0 ។ បើនៅបៅដោះចូរដាក់លេខ 96 ។

**ការបំបៅដោះដោយឡែក (កូឡោន 15)**

សំនួរនេះត្រូវបានសួរកុមារដែលមានអាយុក្រោម 2 ឆ្នាំ (រឺក៏អាយុពី 0-23 ខែ) "តើអ្នកទទួលការបំបៅដោះ ដោយឡែកយូរប៉ុនណា?" ការបំបៅដោះមានន័យថាកុមារមិនត្រូវផ្តល់អាហារលើកលេងតែទឹកដោះម្តាយតែប៉ុណ្ណោះ ។ ចូរដាក់ខែពេញលេញ ចូរដាក់លេដ 77 បើតិចជាង 15 ថ្ងៃ លេខ 88 បើអាយុ 15-29 ថ្ងៃ ហើយលេខ 96 បើនៅបៅដោះ ។

**ការចាក់វ៉ាក់សាំងការពារ / ប្រព័ន្ធភាពស៊ាំ (កូឡោន 16-19)**

☞ កូឡោន 16-19 ត្រូវសួរតែកុមារដែលមានអាយុចាប់ពី 1 ទៅ 2 ឆ្នាំប៉ុណ្ណោះ ។

**ប័នចាក់វ៉ាក់សាំង (កូឡោន 16)**

ចូរសួរថា "តើមាប័នសំរាប់ចាក់វ៉ាក់សាំងទេ?" បើមានចូរដាក់លេខកូដ 1 នៅក្នុងកូឡោន 16 ។ បន្ទាប់មកចសួរទៅអ្នកឆ្លើយដើម្បីបង្ហាញប័ននិងការថតចំលងពីពតិមានពីប័នទៅកូឡោន 17-19 ។ បើចំលើយឆ្លើយថា មិនមានចូរដាក់លេខកូដ 2 ហើយបន្តទៅសំនួរបន្ទាប់ទៀត ។

**វ៉ាក់សាំង DPT (កូឡោន 17)**

ចូរសួរសំនួរ "តើអ្នកឥទទួលបានវ៉ាក់សាំង ***DPT*** ប៉ុន្មាន?" ចូរដាក់ចំនួនដែលបានទទួល ។ ជំរើស ផ្សេងទៀតបើអ្នកឆ្លើយមិនយល់ពាក្យ DPT ទេចូរសួរថា "តើធ្លាប់បានទទួលការចាក់ថ្នាំ វ៉ាក់ នៅ នឹង ដៃរឺទេ?" បើចំលើយថាធ្លាប់ចូរដាក់ចំនួនដងដែលកុមារត្រូវបានចាក់វ៉ាក់សាំង ហើយមិនធ្លាប់ចូរដាក់លេខ 0 ។

ភាពស៊ាំនៃជំងឺរបេង **(កូឡោន 18)**

ចូរសួរថា “តើមានធ្លាប់ចាក់វ៉ាក់សាំងការពារជំងឺរបេងទេ?” ដាក់លេខ 1បើធ្លាប់ ហើយលេខ 2 បើមិនធ្លាប់ ។ ជំរើសផ្សេងទៀតអ្នកអាចពិនិត្យមើលស្លាកស្នាមរបស់កុមារ ។

**ការចាក់ថ្នាំការពារកញ្ជិល (កូឡោន 18)**

ចូរសួរថា “តើមានចាក់ថ្នាំការការជំងឺកញ្ជិលទេ?” ដាក់លេខ 1បើធ្លាប់ ហើយលេខ 2 បើមិនធ្លាប់ ។ សូម ដាក់លេខកូដ 1 ប្រសិនជាមាន ហើយ 2 ប្រសិនទេ។ ជំរើសរើសទៀតបើមិនដឹងចូរសួរថា “តើមានធ្លាប់ចាក់ ថ្នាំ នៅចង្កេះទេ?”

**វីតាមីន A (កូឡោន 20-21)**

| |
|---|
| ☞ កូឡោន 20-21 ត្រូវសួរតែកុមារដែលមានអាយុ 6 ខែទៅតិចជាង 5 ឆ្នាំ (59 ខែ) ។ |

សួរក្នុងកូឡោន 20 “តើធ្លាប់ទទួវីតាមីន *A*ការលពីឆ្នាំមុននឹទេ?” ។ អ្នកត្រូបង្ហាញគំរបក្បាល ដប ដល់អ្នកឆ្លើយនៅពេលដែលអ្នកសួរសំនួរនេះជាលើកដំបូង ។ ដាក់លេខ 1បើធ្លាប់ ហើយលេខ 2 បើមិនធ្លាប់ ។ ដាក់លេខ 1បើធ្លាប់ ហើយលេខ 2 បើមិនធ្លាប់ ហើយថ្លឹងទំងន់និងវាស់កំពស់ ។ បើចំលើយនៅក្នុងកូឡោន 20 ដាក់លេខ 1បើធ្លាប់ ហើយលេខ 2 បើមិនធ្លាប់ ថាធ្លាប់ចូរសួរថា “ដាក់លេខ 1បើធ្លាប់ ហើយលេខ 2 បើមិនធ្លាប់ តើអ្នកទទួលបានវីតាមីន *A*ប៉ុន្មាន?” ចូរកត់ត្រានៅក្នុងកូឡោន 21 នូវចំនួនគំរបក្បាលដប ដែលបាន ផ្តលអោយរយះពេល១ឆ្នាំ ។

**ការថ្លឹងទំងនិងវ៉ាស់កំពស់ (កូឡោន 22-25)**

ការណែនាំកូឡោននេះត្រូវបានរកឃើញនៅក្នុង បញ្ជីដែលធើពីដៃរបស់UNICEF

**ការលាងដៃបន្ទាប់ពីបត់ជើង (Q26)**

សំនួរនេះត្រូវបានសួរម្តាយ អ្នកថែរក្សាកុមារក្រោម 5 ឆ្នាំថា “តើអ្នកលៀងដៃ របស់អ្នកនិង ដៃ របស់កុមារ បន្ទាប់ពីបតជើងដៃរឺទេ? ចូរគូសង្វង់លើលេខកូដនៃចំលើយដែលផ្តល់អោយ :

1 ជាមួយតែទឹក

2 ជាមួយតែទឹកនិងសាប៊ូ

3 ជាមួយតែទឹក ផេះ / ដី

4 មិនលៀងដៃ

5 ផ្សេង១ សូមបញ្ជាក់

**អាការរៈក្អកនិងផ្តាស់សាយ (Q27)**

ចូរសួរថា "តើកុមារមានរោគសញ្ញាក្អក ផ្តាសសាយដែលធ្វើអោយអ្នកនាំពួកគេទៅមន្ទីរពេទ្យ មណ្ឌល សុខភាពក្នុងខេ ស្រុក ឃុំ និងវជ្ជបណ្ឌិតដើរទេ" ចូរគូសលេខកូដចំលើយដែលផ្តល់អោយ (កុំអានចំលើយ ជ្រើសរើស ដែលផ្តល់អោយក្នុងតារាងសំណួរ):

1 មានដុះសាច់ច្រមុះ

2 ពិបាកដកដង្ហើម

3 គ្រុន

4 ដកដង្ហើមលឿនខុសពីធម្មតា

5 ឈឺរយះពេលយូរ Is ill for a long time

6 ផ្សេងៗ សូមបញ្ជាក់

7 មិនដឹង

# ផ្នែកទី V – លក្ខណះល្អិតល្អន់ក្នុងគ្រួសា និង ផ្ទះសំបែង

លក្ខណះល្អិតល្អន់របស់គ្រួសារនិងផ្ទះក្នុងផ្នែកនេះមានសំណួរដែលទាកទងទៅនិងលក្ខណះអាគារផ្ទះ លក្ខណះពីសេសរបស់ផ្ទះ ការទទួលបាននូវសេវាកម្មជាមូលដានការកាន់កាប់ដីធ្លី សកម្មភាពសេដ្ឋកិច្ច លក្ខណះឥណទានរបស់គ្រួសារ គ្រោះថ្នាក់ចរាចរដែលកើតមានឡើងក្នុងគ្រួសារ សេវាសុខភាព និងការយល់ដឹងអំពីការជ្រើរើសកុមារអោយធ្វើការ ។

ការណែនាំទូទៅក្នុងការបំពេញលក្ខណះល្អិតល្អន់អំពីផ្ទះក្នុងសំនួរដូចខាងក្រោម :

1. សំរាប់សំនួរទាំងអស់អំពីផ្ទះ (Q1-Q6) ចូរគូសរង្វង់លើចំលើយលេខកូដ ។ ក្នុងសំនួរនីមួយៗដាក់ លេខកូដបានតែមួយគត់ ។
2. ចំលើយទៅនិងសំនួរ 1 ទៅ 4 (ប្រភេទ អាគារ ផ្ទះ ដំបូលសាងសង់ ជញ្ជាំង ឥដ្ឋ ។) ប្រហែលជាត្រូវបានធ្វើការអង្កេតអោយបានច្បាស់លាស់ហើយបើមានចំងល់ចូរសួរអ្នកឆ្លើយ ។

3. សំនួរ 1 ទៅ 5 គួរតែសំដៅទៅលើលក្ខណៈនៃអាគារ ។

4. ក្នុងករណីដែលមានផ្ទះច្រើនក្នុងអាគារ សំណួរ 5 ត្រូវបានសួរគ្រួសាមួយក្នុងអាគារ ប្រសើរបំផុតគឺគ្រួសារទីមួយនៅក្នុងអាគារ ។
ចូរធ្វើតាមការណែនាំចំពោះចំលើយនៅក្នុងតារាងសំនួរដូចការរស់នៅក្នុងគ្រួសារដ៏ទៃទៀតនៅក្នុងអាគាដែរ ។

**សំណួរទី 1 – ប្រភេទនៃអគារ/ផ្ទះ**

សំរាច់ចិត្តចំពោះចំលើយ នូវសំណួរនេះ មុនពេលធ្វើការកត់ត្រា ។ ( ត្រូវមើលនូវលក្ខណៈរបស់ អគារ ដែលបានអោយនៅជំពូកទី ៤) គូសរង្វង់នៅលើលេខកូដដែលត្រឹមត្រូវនៃអគារនេះ ដែលបានផ្តល់ដោយក្រុមគ្រួសារ ។ ប្រភេទនៃអគារទាំងនេះមានដូចខាងក្រោមនេះ :

1 **ផ្ទះដែលមានលក្ខណៈដីឡូ-** រចនាសម្ព័ន្ធមានលក្ខណៈមិនជាប់ពាក់ពាន់ទៅនិងរចនាសម្ព័ន្ធរបស់ផ្ទះដ៏ទៃទៀត មានលក្ខណៈចែកដាច់ៗពីគ្នា កន្លែងទទួលភ្ញៀវ ឬជញ្ជាំង ។

2 **ផ្ទះពីជាន់/ផ្ទះល្វែង/ឬអគារដែលមានសងរួមគ្នា (2 ឬច្រើនផ្នែកទៀត)** – នេះជាប្រភេទផ្ទះដែលមាន ២ ឬច្រើនប្រភេទ ។ ដែលផ្ទះទាំនេះត្រូវមានរឿងរាវជាច្រើន ដែលមានលក្ខណៈផ្សេងៗ និង ចែកដាច់ពី ជញ្ជាំងមួយៗ ដែលមានតាំងពីជាន់ក្រោមមក ឬផ្ទះមានជាន់ៗពីរ ឬច្រើនប្រភេទ ។

ឧទាហរណ៏:

a. ផ្ទះពីរជាន់ – ជាផ្ទះដែលមានរចនាសម្ព័ន្ធរាងធំទូលាយដែលអាចរស់នៅបានពីរគ្រួសារ

b. អាគារផ្ទះល្វែងមួយបន្ទប់ - មានរាងជាបន្ទប់មួយៗហើយមានច្រើនជាប់ៗគ្នាហើយនៅពីមុខមានកន្លែងអង្គុយលេងបាន ។

c. ផ្ទះជាន់ - ជាប្រភេទផ្ទះដែលមានលក្ខណៈជាជាន់ៗហើយមានខាន់ដាច់ៗពីគ្នាពីផ្ទះមួយទៅផ្ទះមួយទៀត ។

៤. វិឡាឯកជន – ជាអគារដែលមានលក្ខណៈដីឡូ ហើយរបស់របរផ្សេងៗមានលក្ខណៈសាមញ្ញ។

**ចំណាំ :** អាគារនីមួយៗដែលវិស្វាករបានរចនាឡើងមកដូជា ផ្ទះល្វែង ផ្ទះដីឡូ ផ្ទះវិឡា ។ល។ ហើយមិនមានការកែប្រែរូបរាងដើម ឬ ជួសជុល នោះ ដូចជាជួសជុលបន្ទប់ ឬទំលាយ ជញ្ជាំងផ្សេងៗ ធ្វើជាបន្ទប់ថ្មី/ដាក់ជាក្រុម ឬរួមធ្វើបន្ទប់តែមួយ (ជាមួយនិងកន្លែងទំនេរផ្សេងៗ របស់ផ្សេងៗ ឬកន្លែងធ្លងកាត់ជាដើម) ហើយខាងក្រៅពុំមានការកែកុន រចនាសម្ព័ន្ធផ្ទះ ទាំងនោះ ត្រូវបានចាត់ទុកចូលទៅក្នុងប្រភេទផ្ទះមួយៗ ឬ ផ្ទះល្វែង តាមករណីខាងលើនេះ។

3 **អាគារដែលមានលក្ខណៈពាណិជ្ជកម្ម/ឧស្សាហកម្ម/បុរាណ —** នេះជាអគារបរុងសំរាប់ធ្វើសេដ្ឋកិច្ច សំរាប់ជួលធ្វើអាជីវកម្មផ្សេងៗ ឬ សំរាប់បំរើសេវាកម្ម ឬសំរាប់ប្រជុំ ឬធ្វើជារោងចក្រ ឬឃ្លាំងឧសាហកម្ម ឬសំរាប់គោលបំណង កសិកម្ម ហើយមិនមែនបំរុងសំរាប់គោលបំណងសំរាប់ បុគ្គលផ្ទាល់ទេ។

4 **ទីស្នាក់ការស្ថប័ន** – នេះរួមបញ្ចូលទាំងអន្ទេវាកសិទ្ធ សណ្ឋាគារ វត្ត វិហារ ជំរំអន្តោប្រវេសន៏ ជំរំយោធា និងកន្លែងផ្សេងៗទៀត។

5 **ប្រភេទផ្ទះផ្សេងៗទៀត** – នេះសំដៅទៅលើប្រភេទអាគារទាំងអស់ហើយអាគារសង់ជាលក្ខណៈធម្មជាតមិនបានរួមបញ្ចូលក្នុងផ្ទះឯកជនទេប៉ុន្តែប្រើជាផ្ទះក្នុងពេលចុះសំភាសន៏។ ជំរកមានលក្ខណៈធម្មជាតិនិងផ្ទះចល័តដូចជារថបណ្តោង ទូកដឹកទំនិញ រួមបញ្ចូលក្នុងនេះដែរ។

**Q2 – សំភារះសាសង់ដំបូល**

ចូរគូសរង្វង់លើលេខកូដចំលើយពីប្រភេទសំភារះដែលប្រើប្រាស់សាងសង់ដំបូល។ នេះត្រូវបានគេឆ្លើយតាមរយះការសំភាសន៏ប៉ុន្តែបើមានចំងល់ចូរសួរអ្នកឆ្លើយ។

ប្រភេទសំភារះដែលប្រើប្រាស់និងលេខកូដរបស់ពួកវាដូចខាងក្រោម :

1 - ស្បូវ

2 - ជើងឯង

3 - ស៊ីម៉ង់

4 - អាលុមីញ៉ូម  សំណរបាហាំង

5 - សំភារះដែលបានស្រោចស្រង់ផ្សេងៗ

6 - ចំរុះប៉ុន្តែធ្វើពីសំណ អាលុយមីញ៉ូមច្រើន និងពិស៊ីម៉ង់

7 - ចំរុះប៉ុន្តែធ្វើមកពីស្បូវ រឺក៏សំភារះផ្សេងៗ

8 - ដែលកក

9 - ស្បោងផ្លាស់ស្ទិក

**Q3 – សំភារអសាងសង់ជញ្ជំងខាងក្រៅ**

ចូរគូសរង្វង់លើលេខកូដអំពីប្រភេទសំភារះដែលត្រូវប្រើក្នុងការសាងសង់ជញ្ជាំងខាងក្រៅ ។ សំនួរនេះអាចត្រូវឆ្លើយតាមរយះការសំភាសន៏ប៉ុនែបើមានចំងល់ ចូរសួរអ្នកឆ្លើយ ។

ប្រភេទសំភារះដែលប្រើនិងលខកូដរបស់វាដូចខាងក្រោម :

1 - ឬស្សី ស្បូវ

2 - ឈើ

3 - ក្តាបន្ទះ

4 - ថ្ម ឥដ្ឋ

5 - សំណរ អាលុយម៊ីញ៉ូម

6 - ស៊ីម៉ង់

7 - សំភារះបណ្តោសអាសន្ន

8 - ផ្សេងៗទៀត ចូរបញ្ជាក់

ផ្ទះដែលមាន២ជាន់ជាពិសេសនៅជនបទនៅជាន់ផ្ទាល់ដីត្រូវប្រើសំរាប់បសុបក្សី  ប្រដាប់ប្រដាកសិដ្ឋាន ។ល ។ ចូររាយ  ការណ៏ចំពោះសំភារះប្រើសង់ជញ្ជាំងនៅជាន់ទី២ ។ ក្នុងករណីផ្សេងទៀតជញ្ជាំងត្រូវបានធ្វើពីសំភារះខុសៗគ្នា  ចូររាយ  ការណ៏សំភារះដែលប្រើប្រាស់ ។

ផ្ទះដែលមិននៅ ក្នុងអាគារដូចជានៅតាមកន្លែងលូទឹក ស្ពាន ។ល។ គូតែមាន ចំលើយ នៅលេខកូដ 7 – សំភារះ ដែល អាច ស្រោចស្រង់បាន ។

**Q4 – សំភារះនៃការសង់ជាន់តាមផ្ទះ**

ចូរគូសរង្វង់លើលេខកូដចំពោះចំលើយអំពីប្រភេទនៃសំភារះដែលប្រើប្រាស់ក្នុងការសាងសង់ជាន់តាមផ្ទះ ។ បើជាន់នៅ លើផ្ទះត្រូវបានធ្វើដោយសំភារះខុសៗគ្នា ចូររាយការណ៏សំភារះដែលត្រូវបានប្រើ ។ នេះគឺជាប្រភេទនៃសំភារះដែលបានប្រើហើយនិងលេខកូដដូចខាងក្រោម :

1 -ដី /ដីឥដ្ឋ

2 - ឈើ/ ក្តារឫស្សី

3 – ស៊ីម៉ង់

4 - ក្តារក្រាល

**5** – ថ្មដែលបានខាត់ /ថ្មកែវ

**6** - ប្លាស្ទិកម្យ៉ាង

**7** – ក្បឿង

**8** – ផ្សេងៗទៀតចូរបញ្ជាក់

**Q5 – ឆ្នាំអាគារដែលត្រូវបានសាងសង់**

ឆ្នាំដែលអាគារសាងសង់សំដៅទៅលើឆ្នាំនៅពេលសំណង់ត្រូវសាងសង់រួចស្រេច ហើយនៅ ពេលដែលវាត្រៀម សាងសង ។ជាទូទៅអាគារចាប់ផ្តើមសាងសង់ហើយនិងបញ្ចប់នៅក្នុងឆ្នាំដដែលទោះជាមានករណីនៅពេលដែលការសាងសង់ពន្យាពេលជាច្រើនឆ្នាំ ។ ចូររាយការណ៏ឆ្នាំដែលអាគារត្រូវសាងសង់ចប់ ។ បើអាគារកំពុងត្រូវសាងសង់ ប៉ុន្តែមានគេរស់នៅ ចូរដាក់ឆ្នាំនៅពេលដែលគេរស់នៅ ។

ចូរដាក់លេខកូដអោយបានសមរម្យដូចខាងក្រោម

**1** - មុន 1955

**2** - 1955 ដល់ 1969

**3** - 1970 ដល់ 1974

**4** - 1975 ដល់ 1979

**5** - 1980 ដល់ 1985

**6** - 1986 ដល់ 1990

**7** - 1991 ដល់ 1993

**8** - 1994 ដល់ 1996

**9** - មិនដឹង មិនចាំ

ក្នុងករណីដែលមានផ្ទះច្រើនជាង ១ នៅក្នុងអាគារចូរសួរឆ្នាំរបស់អាគារផ្ទះដែលត្រូវបានសាងសង់ពីអ្នកឆ្លើយ ម្នាក់ក្នុងចំនោមអ្នកឆ្លើយនៅក្នុងអាគារដូចគ្នានៃគ្រួសារពេញចិត្តជាងគេពីគ្រួសារដំបូងដែលត្រូវបានសំភាសន៍ ។

ចូរចំលងសំនូរដដែលនៅក្នុងតារាងសំនួនៃផ្ទះគ្រួសារដ៏ទៃទៀតដែលរស់នៅក្នុងអាគាតែមួយ ។

**Q6 – ចំនួនបន្ទប់**

ចូរបញ្ជាក់អោយច្បាស់ពីអ្នកឆ្លើយថាតើមានបន្ទប់ប៉ុន្មាននៅក្នុងផ្ទះដោយមិនរាប់បញ្ចូលទាំងបន្ទប់គេង ច្រកខាងក្រោម ហើយចូរគូសរង្វង់ចំលើយលើអោយបានសមរម្យ ។

បន្ទប់ត្រូវគេអោយនិយមន័យថាជាកន្លែងទំនេរនៅក្នុងផ្ទះរឺក៏ទីស្នាក់ការសំរាប់រស់នៅដោយមានជញ្ជាំង យ៉ាងហោចណាស់មានកំពស់ 2 ម៉ែត្រ មានទំហំល្មមសំរាប់ដាក់មនុស្សពេញវ័យនិងមានទំហំ 4 $m^2$ យ៉ាងហោចណាស់ ។

ចំនួនបន្ទាប់សរុប គួរតែរាយការណ៏ដូចជាបញ្ចូលទាំងបន្ទប់គេង បន្ទប់ញាំុអាហារ បន្ទប់សំរាប់សិក្សា បន្ទប់ទទួល ភ្ញៀវបន្ទប់តូចក្រោមដំបូលផ្ទះបន្ទប់សំរាប់អ្នកបំរើ ផ្ទះបាយ បន្ទប់សំរាប់ធ្វើជំនួញហើយនិងកន្លែងទំនេផ្សេងៗទៀត

រឺក៏កន្លែងសំរាប់រស់នៅផ្សេងៗដរាបណាវាមានលក្ខណះគ្រប់គ្រាន់ដូចជាជញ្ជាំងនិងជាន់តាមផ្ទះ ។

ចូរសំគាល់ថារបៀង គេហបទ កន្លែងទទួលភ្ញៀវ រានហាល បន្ទប់ទទួលភ្ញៀវ បន្ទប់គេង បង្គន់គួតែមិនត្រូវបាន រាប់បញ្ចូលជាបន្ទប់ទោះជាវាគ្រប់លក្ខខ័ណ្ឌក៏ដោយ ។

**Q7 – បរិវេនតាមកំរាលលើផ្ទះ**

ចូរសួរថា "តើបរិវេននៃកំរាលនីមួយៗតាមផ្ទះមានប៉ុន្មានម៉ែតការេ?" ចូរដាក់ចំលើយជាម៉ែតការេនៅ ក្នុងកន្លែងដែលផ្តល់អោយ ។បើចំលើយមិនដឹងពីចំនួនសរុបជាម៉ែតការេ ហើយចូរសួរដើម្បីស្មាន ។

**Q8 – លក្ខណះនៃការកាន់កាប់ផ្ទះល្វែង**

ចូរសួរអ្នកឆ្លើយ " តើអ្វីជាលក្ខណះនៃការកាន់កាប់ផ្ទះល្វែង "
លក្ខណះនៃការកាន់កាប់ផ្ទះល្វែងគួរត្រូវបានគេកត់ត្រាទុកនៅពេលដែលគេចុះទៅសំភាសន៏លើកដំបូង ។ ដូច្នេះទោះជាគ្រួសារបានជួលផ្ទះពីមុនប៉ុន្តែទទួលផ្ទះរួចមុនពេលចុះទៅសំភាសន៏បន្ទាប់គ្រួសារត្រូវបានរាយការណ៏ថាមានផ្ទះផ្ទាល់ខ្លួនហើយមិនជួលកន្លែងទេ ។ ចូរគូសលេខកូដលើចំលើយដែលបានមកពីគ្រួសារ ។ លេកូដមានដូច ខាងក្រោម :

1 **មានផ្ទាល់ខ្លួន** – គ្រួសារជាម្ចាស់ហើយមានសិទ្ធស្របច្បាប់ក្នុងការ កាន់កាប់ផ្ទះនោះ ។រួមបញ្ចូល ទាំងផ្ទះដែលបង់បន្តិចម្តងៗផងដែរ ។

2 **ជួល** – អ្នកជួលអាចបង់ប្រាក់ជាប្រាក់សុទ្ធរឺបែភេទផ្សេងទៀត ។

3 **ទទួលបានផ្ទះនៅមិនបាច់អស់ប្រាក់** - គ្រួសារមានផ្ទះនៅមាន មិនមានការអនុញ្ញាតិពី ម្ចាស់ផ្ទះ និងមិនចាំបាច់បង់ប្រាក់ថ្លៃឈ្នួលជាសាច់ប្រាក់នោះទៅអោយម្ចាស់ផ្ទះ អ្នកជួលដីឡើយ ។ រួមទាំង គ្រួសាររបស់អ្នជួលកសិដ្ឋានដែលមានផ្ទះនៅដោយមិនបងលុយទៅអោយម្ចាស់ដីដែលពួកធ្វើកសិដ្ឋានដូច្នេះនិយោជិកដែលត្រូវបានផ្ទះនៅមិនអស់លុយជាផ្នែកមួយនៃការផ្តល់ផលប្រយោជន៏ (ពួកគេផ្លាស់កន្លែងផ្ទះសំបែងពីការងារ) ។

4 ម្ចាស់ផ្ទះប៉ុន្តែមិនបានរស់នៅ – ម្ចាស់របស់ផ្ទះបានអោយគ្រួសាររស់នៅនៅតែស្ថិតក្រោមការ ចចាររបស់រដ្ឋាភិបាល ។

**Q9 – តំលៃពិតប្រាកដនៃថ្លៃជួលក្នុង១ខែ**

បើលេខកូដដែលគូសនៅក្នុង Q8 ជា "2" (ជួល) ចូរសួរអ្នកឆ្លើយតបនូវតំលៃជួល ពិតប្រាកដគិតជារៀល ដែលគាត់ជួលផ្ទះនោះរៀងរាល់ខែហើយចូរផ្លោះទៅសំនួរ Q11 (ការជួសជុល ការសាងសង់ និងផ្លាស់ទំរង់ថ្មីនៃផ្ទះ)

**Q10 – ថ្លៃជួលដែលចំណាយក្នុង១ខែ**

បើលេខកូដនៅក្នុងសំនួរ Q8 គឺ "1" (មានផ្ទះ/សងបំណុលតិចៗ) "3" (បាននៅដោយមិនគិតប្រាក់) រឺក៏ "4" (ម្ចាស់មិនបាននៅ) ចូរសួរអ្នកឆ្លើយដើម្បីស្មានចំលើយទៅសំនួរគាត់ថាតើផ្ទះទាំងរបស់ គាត់ននឹងត្រូវបានជួលរឺទេ ។

**Q11 - ការសាងសង់និងការជួសជុលផ្ទះ**

ដើម្បីកំនតថាតើអ្នកផ្តល់ចំលើយបានសាងសង់និងជួសជុលផ្នែកសំខាន់ៗនានានៅក្នុងផ្ទះរបស់ពួកគេរឺទេហើយ ចូរសួរពួកគេថា "តើអ្នកមានធ្វើការសាងសង់ ជួសជុលផ្ទះដែរឺទេនៅឆ្នាំនេះ?" ចូរដាក់លេខកូដ "1" បើចំលើយថា" ចាស " ហើយចូរសួរសំនួរ Q12 និង Q13 ។ ក្រៅពីនេះចូរដាក់លេខកូដ "2" សំរាប់ចំលើយថា" ទេ " ហើយចូរសួរទៅសំនួរ Q14 ។

**Q12 – តំលៃដែលចំណាយលើការសាងសង់**

សំនួរនេះគួរតែត្រូវបានសួរបើចំលើយក្នុងសំនួរ Q11 និង "1" ឆ្លើយថា " ចាស " ។ ចូរ សួរអ្នកឆ្លើយថា

"តើអ្នកចំណាយលើទៅលើការសាងសង់ផ្ទះអស់ប៉ុន្មានដែរ?" ។ចូរដាក់លេខកូដនៅក្នុងចន្លោះដែលបាន ផ្តល់អោយ គិតជារៀល ។ បើចំលើយថាមិនដឹងពីតំលៃចំណាយពិតប្រាកដចូរសួរដើម្បីធ្វើការស្មាន ។

**Q13 – តំលៃដែលចំណាយលើការជួសជុលសំខាន់ៗ / ការជួសជុលផ្ទះ**

សំណួរនេះគួរតែត្រូវបានសួរបើចំលើយនៅក្នុងសំនួរដាក់លេខកូដ "1" ចូរសួរសំនួថា "តើការចំណាយសរុប ចំពោះការសាងសង់អស់ប៉ុន្មាន?" ។ ចូរដាក់ចំនួនទឹកប្រាក់ចូលទៅក្នុងចន្លោះដែលបានផ្តល់អោយគិតជារៀល ។ បើអ្នក ឆ្លើយថាមិនដឹងពីតំលៃពិត ចូរសួរដេម្បីធ្វើការស្មានចំណាយនេះ ។

**Q14 –ការចំនាយផ្សេងៗ**

ការចំណាយក្នុគ្រួសារសំដៅទៅការចំណាយដែលធ្វើឡើងសំរាប់ការប្រើប្រាសផ្ទាល់ខ្លួន ។

ដូច្នេះវាមិនបានរួមបញ្ចូលដូចជា ការចំណាយដែលទាក់ទងនឹងកសិដ្ឋាន ពានិជ្ជកម្ម ការវិនិយោគ ការទិញអចលនទ្រព្យ និង ការចាយ ប្រាក់ផ្សេងៗ ដែល មិនពាក់ព័ន្ធនិងការប្រើប្រាស់ផ្ទាលខ្លួន ។ គ្រឿងសង្ហារឹមនិងសំភារះ ដែលអាចប្រើបានយូរដូច ជាឡាន ម៉ូតូ និងសំភារះផ្សេៗទៀតដែលបានទិញទៅតាមខែ (ជាប្រាក់សុទ្ធ រឺ ឥណទាន) សំរាប់ការប្រើប្រាស ់ត្រូវបានចាត់ទុកថាជាសំភារះ សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ដូច្នេះត្រូវបញ្ចូលទៅក្នុងការ ចំណាយសំរាប់គ្រួសារ ។

ហើយត្រូវរួមបញ្ចូល ទាំងការចំ ណាយផ្សេង១ដូចជាពន្ធដាប្រាក់ចំណូល ការបង់លើអចល នះទ្រព្យផ្សេង១ ថ្លៃឈ្នួលចុះឈ្មោឡាន អំណោយ ការធ្វើ វិភាគទាន ហើយការជួយខ្លះទៀតដែល ត្រូវ ផ្តល់ដោយគ្រួសារដល់អ្នកដ៏ទៃ (កាផ្តល់វិភាគទាននិងអំណោយដល់សេ វាកម្មសាសនា) និងការចំណាយផ្សេង ទៀតដូចជាកការបង់អត្រាកាប្រាក់លើប្រាកកំចីសំរាប់ការចំណាយផ្គត់ផ្គង់ជីវភាព ការខាងបង់ដោយសាផ្ទះ និងការ ចំណាយទៅលើឈ្នួលសមាជិកផ្សេង១ ។មិនបញ្ចូលដូចជាការទិញអចលណទ្រព្យ រឺ ការសងរំលូស ការសង លើប្រាក់កំចីសុទ្ធ ប្រាក់កំចិអោយទៅអ្នកក្រៅគ្រួសារ ចំនួនប្រាក់បញ្ញើរក្នុងធនាគារ ការវិនិយោគ និង ការចំ ណាយ ជ សជិលសំខាន់១ ការសងផ្ទះជាដើម ។

ដើម្បីកំនត់ការចំណាយពិតប្រាកដពី (ទោះជាជាសាច់ប្រាក់សុទ្ធ រឺជាប្រភេទអ្វីក៏ដោយ) ចូរសួរអ្នកឆ្លើយ ថា"តើអ្នក មានការចំណាយពិតប្រាកដប៉ុន្មានដែរ....( ចូរកកត់ត្រាចំនួនការ ចំណាយទាំងឡាយ ដែលបានចុះ នៅ ក្នុងកំរងសំនួរ)?" សំរាប់ការចំណាយនីមួយ១ ចូរសួរពីចំនួនដែលចំណាយជាប្រាក់សុទ្ធរឺបនឥណទាន បន្ទាប់ មក ទៀតការចំណាយ ផ្សេង១ ។បន្ទាប់មកទៀតបូកសរុបតំលៃទាំងអស់ហើយសរសេរតំលៃសរុប ។

ខាងក្រោមនេះគឺជាការណែនាំដែលត្រូវគួរពិចារណារទៅលើសំនួរ :

a. **អាហារ ភេសជ្ជៈ និងថ្នាំជក់ (ការពីសប្តាហ៏មុន)**

របស់ដែលដាក់ចូលនៅក្នុងផ្នែកនេះគួតែជាការប្រើប្រាស់កាលពីសប្តាហ៏មុន (មិនមែនការទិញ ស រុបប្រចាំ សប្តាហ៏ទេ)របស់គ្រួសារទេ ។ហេតុច្នេះបេស់ដែលត្រូវទិញប៉ុន្តែមិនត្រូវប្រើប្រាស់នៅសប្តាហ៏មុនទេហើយមិនត្រូវរាប់បញ្ចូលផងដែរ ។ ផ្នែកនេះបញ្ចូលទាំងអាហារដែលរៀបចំនៅផ្ទះ បើត្រូវញុំានៅផ្ទះ រឺក៏ទិញពីខាង ក្រៅហើយញុំានៅកន្លែងណាក៏ដោយដូចជាកន្លែងធ្វើការ សាលា ។ល ។ អា ហារដែលបាន រៀបចំពីភោ ជនីដ្ឋានហើយត្រូវញុំានៅផ្ទះក៏ត្រូវបានដាក់ជាក្រុម ។

b. **សំលាកបំពាក់និងគ្រឿងពាក់ស្បែកនៅជើង (កាលពី៦ខែមុន)**

ចូរសួរនៅក្នុងផ្នែកនេះចំពោះចំនួនដែលបានចំណាយហើយត្រូវចំណាយលើសំលាកបំពាក់និងគ្រឿងសំរាប់ពាក់នៅជើងកាលពី៦ខែមុន ។ ការចចំណាយសំរាប់ឯកសណ្ឋានសាលា នៃសមាជិក គ្រួសារ រួមបញ្ចូលទាំង ឯកសណ្ឋានសំរាប់ការអប់រំ ។ល ។ត្រូវបានរាយការណ៏នៅក្នុងផ្នែកនេះ ។ទោះជាយ៉ាងណាក៏ដោយការចំណាយសំរាប់ត្រសំល្បៀកបំពាក់ហើយនិងស្បែកជើងដែលគ្រួសារទិញ

ហើយត្រូវអោយផ្តល់មេគ្រួសារស្ត្រីបំរើក៏ត្រូវ

ដកចេញពីផ្នែកនេះហើយគួរបញ្ចូលទៅក្នុងផ្នែក៦-ប្រតិបត្តិការក្នុងគ្រួសារ ។

c. **ការថែរក្សាផ្ទះនិងការជួសជុលបន្តិចបន្តួច (កាលពី៦ខែមុន)**

ទំនាក់ទំនងការថែរក្សាផ្ទះសំបែងនិងការជួសជុលបន្តិចបន្តួចនៅក្នុងផ្ទះអំឡុងពេល៦ខែគឺត្រូវដាក់បញ្ចូលនៅក្នុងការចំណាយនេះ ។វាមិនត្រូវដាក់បញ្ចូលនៅក្នុងការរៀបចំសំខាន់ៗនិងការសាងសង់ផ្ទះ ។មិនដាក់បញ្ចូលតំលៃសេវាកម្មមិនគិតថ្លៃចំពោះការជួសជុលផ្ទះបន្តិចបន្តួច ។ការថែរក្សាផ្ទះនិងការជួសជុលបន្តិចបន្តួចសំដៅលើការការផ្លាស់ប្តូរនៅក្នុងផ្ទះបើម្បីការពារការខូចខាតរឺរក្សាផ្ទះនោះអោយមានលក្ខណះដូចដើម ។ការថែរក្សាផ្ទះនិង

ការជួសជុលបន្តិចបន្តួចរួមបញ្ចូលដូចខាងក្រោម :

(1) ការផ្លាស់ប្តូរក្បាលម៉ាសីនទឹក កន្លែងសំរាប់លាងចាននិងគ្រឿង

(2) ការជួសជុលប្រដាប់បង្ហូទឹកចេញ

(3) ការផ្លាសប្តូរបង្អួចនិបង្អួចនិងតដ្ឋដែលបាក់បែកបាក់

(4) ការជួសជុលផ្ទះ រឺជញ្ជាំងក្រដាស

(5) ការជួសជុលពីដានដែលខូចខាត ជញ្ជាំង

(6) ជួសជុលដំបូលលិច

(7) ជួសជុលរបង

(8) ជួសជុលខ្សែភ្លើង កុងតាក់ និងហ្វ៊ីដោតភ្លើង

d. **ទឹក ភ្លើង និងប្រេងឥន្ទនះ (ខែមុន)**

ចូរបញ្ចូលក្នុងនេះការប្រើប្រាស់សរុបនៃទុក ភ្លើង ហើយប្រេងឥន្ទនៈកាលពីខែមុន ។ បើអ្នកឆ្លើយ

មានវិក័យបត្រជាផ្លូវការណ៏ក្នុងការបង់ប្រាក់ដែលជាឯកសារអាចផ្តល់ពតិមានត្រឹមត្រូវហើយនិងអាចធ្វើការសំភាសន៏បានលឿន ។

ក្នុងករណីដែលគ្រួសារចែករំលែកពត៌មាននេះជាមួយគ្រួសារដ៏ទៃ ហើយការស្មានប្រេប្រាស់របស់ គ្រួសារគួរតែរួមបញ្ចូលក្នុងនេះដែរ។ ការចំណាយរបស់ LPG ប្រេងកាត អគ្គិសនី ហើយនឹងទឹកត្រូវ បានប្រើដោយគ្រួសារ ដែលមានផ្ទះជា ផ្ទះគំរូ រគួរតែ ត្រូវបានដាក់បញ្ចូលដែរ។ នៅក្នុងស្ថាន ភាពនេះ ចូរសួរពីចំនួនដែលបានចែករំលែកប្រចាំខែដោយផ្ទះគំរូរ។

LPG ប្រេងកាត អគ្គីនី និង ទឹក ត្រូវប្រើក្នុងការធ្វើអាជីវកម្មទាំងគ្រួសារនិងគ្រួសារ ដ៏ទៃទៀតដែល ចែករំលែកផ្នែកនៃផ្ទះគួរតែមិនត្រូវដាក់បញ្ចូលក្នុងនេះឡើយ។ ក្នុងករណីបែបនេះ ចូរសួរ អ្នកឆ្លើយដើម្បី ស្មានចំនួនដែលត្រូវប្រើប្រាស់សំរាប់គ្រួសារជាលក្ខណះឯកជន។សំរាប់គ្រួសារដែលបង់ទៀងទាត់ ចំពោះសេវាកម្មអគ្គិសនី រឺ ទឹក ការទិញទឹក ចូរសួរអំពីការ បង់ សរុបកាលពីខែមុន។ បើភ្លើងរឺទឹកត្រូវបាន រួម បញ្ចូលនៅក្នុងថ្លៃឈ្នួលចូរព្យាយាមសួរអំពីតំលៃប្រហាក់ប្រហែលចំពោះភ្លើងនិងទឹក។

ចូរដាក់ "ប្រភេទ " កូឡោននៃការប្រើប្រាស់អគ្គិសនី ប្រេងឥន្ទនះ និងទឹកដែលទទួលដោយមិន បង់ប្រាក់រឺជាអំណោយក្នុងករណីមានខ្មែងឈើ ដើមឈើ មែកឈើត្រូវបានប្រើជាអុស។

e. **គ្រឿងតុទូរក្នុងផ្ទះ** (កាលពី១២ខែមុន)

ការចំណាយនេះរួមបញ្ចូលទាំងគ្រឿងសង្ហារឹមដែលប្រើប្រាស់បានយូរនិងមិនបានយូរសំរាប់គ្រួសារដែលបានទទួលកាល 12 ខែមុន។

(1) សំពតលិនិន គ្រឿងសង្ហារឹម

(2) គ្រឿងប្រដាប់ប្រើក្នុងផ្ទះបាយ

(3) ប្រដាប់ប្រើប្រាស់សំខាន់ៗដូចជា ម៉ាស៊ីនភ្លើង ទូទឹកកក ហ្គាស ម៉ាស៊ីនបោកគួក។ល។

(4) ផ្នែកនៃគ្រឿងសង្ហារឹម

(5) ប្រដាប់ប្រើប្រាស់ផ្សេងៗដូចជា ឆ្នាំងអ៊ុត កង្ហារអគ្គិសនី កូនខ្ទះ ឆ្នាំងដាំបាយ។ល។

(6) កែវ ចាន ស្លាបព្រា ។ល ។

(7) សំភារៈក្នុងផ្ទះដូចជាឧបករណ៏ក្នុងសួនច្បារ ញញួរ អំបោសដុសលាងក្តារ ។ល ។

**f. ប្រតិបត្តិការគ្រួសារ** (កាលពីសប្តាហ៏មុន)

នៅចំនុចនេះបង្ហាញអំពី ការចំណាយរួមទាំងសំភារៈការងារផ្ទះសំបែង ដែលមានដូចជា សាប៊ូវ/ម្សៅសាប៊ូ សមរាប់បោកគក់ ថ្នាំបាញ់សំលាប់សត្វល្អិត ទឹកលាង/ជូតផ្ទះ ជីសំរាប់ផ្កា អំបោសសំអាត ។ល ។ របស់ទាំងនេះរួមទាំងថ្លៃសេវាកម្មសំអាតផ្សេងៗទៀតដែលមានទាក់ទង (អ្នកបំរើ, ការលាងសំអាត, អ្នកយាម, អ្នកថែសួន) ដែលអាចជួយដល់ស្ត្រីមេផ្ទះបាន វាមាន ការគិតថ្លៃ និង ការផ្តល់ជូនដោយមិនគិតថ្លៃ ដូជាការជួសជុល, ការថែទាំ នូវប្រដាប់ប្រដាប្រើប្រាស់ក្នុងផ្ទះ និងថ្លៃផ្សេងៗទៀត ដូជាសំរាម របស់របរដែលចោល និងការបោកអ៊ុតសំល្បេកបំពាក់ ។

**g. ថ្នាំពេទ្យ (ខែមុន)**

កត់ត្រាក្នុងចំនុចនេះ ពីថ្លៃ ឬការចាយវាយទៅលើ ការថែទាំសុខភាព និងការផ្តល់ជូននូវ សេវាកម្ម ថ្នាំពេយ្យល្អៗ កាលពីខែមុន ។

**h. ការធ្វើតំណើ និង ឧបករណ៏សំរាប់ទំនាក់ទំនង ផ្ទាល់ខ្លួន (ខែមុន)**

កត់ត្រានូវថ្លៃធ្វើតំណើនិងឧបករណ៏ដែលធ្វើការទំនាក់ទំនងផ្ទាល់ខ្លួនដែលបានទិញ (ជាសាច់ប្រាក់ ឬ ជាបណ្ណ័ឥទាប) កាលពីខែមុន ដូចជា កង់ ម៉ូតូ រថយន្ត ទូរស័ព្ទ ។ល ។

**i. ប្រតិបត្តិការ/មារថែទាំ នៃឧបករណ៏ធ្វើតំណើរ (ខែមុន)**

កត់ត្រានូវថ្លៃប្រតិបត្តការ និងការទំនុកបំរុង យានយន្ត ដែលមានដូចជា សាំង ម៉ាស៊ូត ហ្កាស ការលាងសំអាត ជួសជុល រើម៉ាស៊ីន និងការទិញផ្នែកផ្សេងៗនៃម៉ាស៊ីន ។

**j. ថ្លៃ ធ្វើតំណើរ និង ការទំនាក់ទំនង ដែលអាចធ្វើទៅបាន ( ខែមុន )**

កត់ត្រានូវចំនុចនេះនូវតំលៃក្នុងការធ្វើដំណើរ និង សេវាកម្មនៃការទំនាក់ទំនងគ្នាកាលពីខែមុន ដូចជាការធ្វើដំណើរតាមរយៈ ម៉ូតូ ឡានក្រុង កង់ រថយន្តឈ្នួល រទេះភ្លើង កប៉ាល់ កាណូត ទូក រទេះគោ យន្តហោះ(ក្នុងស្រុន និង អន្តរជាតិ)។ ថ្លៃសេវាកម្មទូរស័ព្ទ ក្នុងស្រុកនិងក្រៅប្រទេស ថ្លៃទូរសារ និង តេលេក្រាម និង តែមប្រសេនីយ៍ ជាដើម និងថ្លៃចំណាយផ្សេងៗទៀតដែល ទាក់ទងនិង ការធ្វើដំណើ និងទំនាក់ទំនងត្រូវបានកត់ត្រានៅក្នុងបង្គោលនេះ។

k. **ការកំសាន្ត (១២ ខែមុន)**

កត់ត្រានូវឈ្មោះមុខចំណាយចំពោះគ្រួសារ លើទំនិញ និងសេវាកម្មផ្សេងៗ ដូចជា ថ្លៃជីកជញ្ជូន ដើលេង ។ល។ ក៏រួមបញ្ចោលទាំងថ្លៃប័ណ្ណសមាជិក ផ្សេងៗ ។ល។

ប្រសិនបើសមាជិកគ្រួសារមានលេងល្បែងជល់មាន់សំរាប់ការកំសាន្តនោះ (ឧទាហរណ៍ ការប្រជល់មាន់ផ្ទាល់របស់គាត់) ចំនួនទឹកប្រាក់ដែលចំណាយក្នុងការ ទិញសត្វមាន់នោះត្រូវបាន កត់ត្រានៅក្នុងចំនុចនេះ ប្រសិនជាគាត់មានសត្វចិញ្ចឹម កត់ត្រានូវចំណាយក្នុងការចិញ្ចឹមមើលថែ (ដូចជា ចំណី, ថ្នាំបង្កាផ្សេងៗ ។ល។)

l. **ការអប់រំ (ខែមុន)**

បើមានសមាជិកគ្រួសារដែលកំពុងសិក្សានៅពេលណាក៏ដោយ ការចំណាយ ទាំងឡាយទាក់ទង ទៅ នឹងការ អប់រំនឹងត្រូវដាក់បញ្ចូលនៅក្នុងនេះ។ វារួមទាំងថ្លៃឈ្នួលសាលា ការចុះថ្លៃអោយ សមាជិក គ្រួសារដែល សិក្សាឆ្ងាយពីផ្ទះ សៀវភៅ ហើយនិងសំភារៈផ្គត់ផ្គង់នៅសាលា។ ការចំណាយលើកា សែត ទស្សនាវដ្តី រឿង កំប្លែង កូនសៀវភៅដាក់ហោប៉ៅក៏ត្រូវបានដាក់បញ្ចូលដែរ។

m. **ការយកចិត្តទុកដាក់លើសេវាកម្មនិងផលិតផល (ខែមុន)**

ចូរដាក់បញ្ចូលនៅទីនេះនូវតំលៃរបស់ដែលបានទិញ រឺ សេវាកម្មដែលអាចមានដោយគ្រួសារ ចំពោះ ការយកចិត្តទុកដាក់ផ្ទាល់ខ្លួនកាលពីខែមុនដូចជាបង្កន់ សាប៊ូ ថ្នាំដោះធ្មេញ ម្សៅ ក្រដាស់ប្រើ នៅ ក្នុង បង្គន់ ក្រដាស់ជូតមាត់ ។ទឹកអប់ ការកាត់សក់ ។ល។

n. **អានុភាពផ្ទាល់ខ្លួន** (កាលពី១២ខែមុន)

ចូរបញ្ចូលវត្ថុដែលគ្រួសារទិញសំរាប់អានុភាពផ្ទាល់ខ្លួន ដូចជាគ្រឿងអលង្កា កាបូបដៃ ការបូប កាបូប លុយ ឆ័ត្រ ។ល ។

o. **ការចំណាយផ្សេងៗ ( 12 ខែមុន)**

ចូរបញ្ចូលការចំណាយមិនមានការស្មាន ដូចជាតំលៃលិខិតឆ្លងដែន ថ្លៃប័នបើកបរ ការបង់ ពន្ធយាន យន្ត អំណោយ វិភាគទានទៅគណៈបក្សនយោបាយ មូលនិធិសង្គម សាសនា និងការចំណាយដែលកើត មាន ដោយគ្រួសារមិនត្រូវបញ្ចូលទៅក្នុងនេះទេ ។

**Q15 – ប្រភពសំខាន់ៗនៃការចែកចាយទឹកសំរាប់លៀងដៃនិងបោកគួក**

ចូរគូសរង្វង់លើលេខកូដអោយបានសមរម្យសំរាប់ប្រភពសំខាន់ៗនៃការចែកចាយទឹកលៀងដៃនិងបោកគួក ។ ប្រសិនមានប្រភព២រឺពចំពោះការចែកចាយទឹក ចូររាយការណ៍ប្រភពដែលបានប្រើច្រើនបំផុត ។

ប្រភពខុសគ្នានៃការផ្គត់ផ្គង់ទឹកសំរាប់លៀងដៃនិងបោកគួកដូចខាងក្រោម :

1 - បំពង់ទឹកនៅតាមបរិវេណ

2 - ទឹកពីរំម៉ានៃតាមសាធារណះ

3 - អន្ទូងស្នប់

4 - អណ្តូងជីកដែលមានការការពារ

5 - អន្ទូងជីកមិនដែលមានការការពារ

6 - ស្ទឹង បឹង ព្រែក ត្រពាំង

7 - ទឹកភ្លៀង

8 - ឡានដឹកទឹក ទិញទឹក

9 - ទឹកដប

10 - ផ្សេងៗងទៀតសូមបញ្ជាក់

**Q16 – ចំងាយនៃប្រភពទឹកសំខាន់ៗ**

ចូរគូសរង្វង់លើលលេខលើចំលើយចំពោះចំងាយនៃប្រភពនៃការចែកចាយទឹកសំខាន់ៗពីកន្លែងរស់នៅ ។ លេខកូដសំរាប់ចំងាយនៃប្រភពទឹកដូចខាងក្រោម :

1 នៅបរិវេណផ្ទះ

2 តិចជាង 100 ម៉ែត្រ

3 100 ដល់ 500 ម៉ែត្រ

4 500 ម៉ែត្រ ដល់ 1 គីឡូម៉ែត្រ

5 ច្រើនជាង 1 គីឡូម៉ែត្រ

9 អត់ដឹង

**Q17 - ពេលទៅយកទឹកនិងត្រឡប់មកវិញ**

ចូរសរសេររយះពេលទៅយកទឹកនិងត្រលប់មកវិញជាម៉ោងនិងនាទីក្នុងកន្លែងទំនេរដែលបានផ្តល់ដោយ ។ បើប្រភពទឹកស្ថិតនៅក្នុងនៅក្នុងបរិវេនរបស់គ្រួសារ ចូរគូសលេខកូដ "88" សំរាប់នៅក្នុងបរិវេន ។ បើចំលើយឆ្លើយ ថាមិនដឹងចំងាយប៉ុន្មាននៅពេលទៅយកទឹកនិងត្រឡប់មកវិញចូរគូសលេខកូដ "99" ។

**Q18 - Q19 ប្រភពសំខាន់នៃប្រភពការចែកចាយទឹកសំរាប់ផឹក**

សូមសួរអោយច្បាស់ថាតើគ្រួសារទទួលទឹកផឹកដូចប្រភពទឹកបោកគួកនិងលៀងចានឺទេ ហើយចូរសួរថាគ្រួសារថា "តើគ្រួសារអ្នកទទួលប្រភពទឹកផឹកដូចប្រភពនេះរឺទេ?" ចូរដាក់លេខកូដ "1" សំរាប់ចំលើយថា " ចាស " ហើយបន្តទៅសំនួរ Q20 ។ បើក្រៅពីនេះចូរដាក់លេខកូដ "2" ហើយសួរសំនួរ Q19 ។

**Q19 – ប្រភពសំខាន់នៃទឹកផឹក**

គូសរង្វង់លើចំលើយសមរម្យសំរាប់ប្រភពសំខាន់ៗនៃការចែកចាយទឹលផឹក ។ បើមានប្រភពទឹកសំរាប់ផឹក ២ រឺ ច្រើន ចូររាយការណ៏ពីប្រភពណាដែលប្រើច្រើនបំផុត ។ ប្រភពនៃការចែកចាយទឹកផឹកដូចខាងក្រោម :

1 - បំពង់ទឹកនៅតាមបរិវេណ

2 - ទឹកពីរ៉ូម៉ានែតាមសាធារណះ

3 - អន្លូងស្អប់

4 - អណ្តូងជីកដែលមានការការពារ

5 - អន្លូងជីកមិនដែលមានការការពារ

6 - ស្ទឹង បឹង ព្រែក ត្រពាំង

7 - ទឹកភ្លៀង

**8** - ឡានដឹកទឹក ទឹញទឹក

**9** - ទឹកដប

**10** - ផ្សេងៗងទៀតសូមបញ្ជាក់

**Q20 – ប្រភេទបង្គន់ដែលប្រើប្រាស់**

គោលបំណងនៃសំនួរនេះគឺដើម្បីទទួលបាននូវវិធានការនៃការកើតអនាម័យទូទៅរបស់គ្រួសារការប្រើប្រាស់បង្គន់សំខាន់ណាស់ក្នុងការទបស្កាត់ជំងឺនិងការធ្វើអោយប្រសើរឡើងនូវសុខភាព។

1 **បង្គន់បង្ហូរទឹកផ្ទាល់ខ្លួន** – បង្គន់គ្រប់ប្រភេទទាំងអស់ត្រូវប្រើដោយគ្រួសារដែលទឹកត្រូវបានចាក់ចូលទៅក្នុងចាបបង្គន់ ទឹកបន្តិចបន្តួចនៅសល់ក្នុងចានបង្គន់ ហើយគ្រាន់តែមូលប៊ូតុងកាច់ទឹកពីបំបង់ស្តុកទឹក។

2 **បង្គន់បង្ហូរទឹករួមគ្នា** - បង្គន់គ្រប់ប្រភេទទាំងអស់ត្រូវប្រើដោយគ្រួសារដែល ទឹកត្រូវបានចាក់ ចូលទៅក្នុងចាបបង្គន់ ទឹកបន្តិចបន្តួចនៅសល់ក្នុងចានបង្គន់ ហើយគ្រាន់តែមូល ប៊ូតុងកាច់ ទឹក ពីបំបង់ស្តុកទឹក។

3 **បង្គន់បិទជិត** – នេះជាប្រភេទបង្គន់ដែលមិនបាច់ប្រើទឹកនៅក្នុងចានបង្គន់ទេ ជាធម្មតាវាធ្វើពីដីឥដ្ឋដូច ជារណ្តៅធម្មតាធ្វើពីបំពង់រាងធំហើយគ្របខាងលើជិតនិងអាចបើកបាន។ វាប្រហែលជាមានរឺមនិមានប្រអប់សំរាប់អង្គុយនៅពេលបើកទេ។

4 **បង្គន់បើកជំហរ** – រណ្តៅដែលបើកជំហរគ្មានចានស្តុកទឹកទេ

5 **ផ្សេងៗទៀត** –ចូរបញ្ជាក់ពីប្រព័ន្ធបង្គន់ផ្សេងទៀតដែលគ្រួសារប្រើប្រាស់។

6 **មិនមាន**- ចូររាយការណ៏ចំពោះគ្រួសារដែលមិនមានបង្គន់ប្រើប្រាស់និងគ្មានប្រព័ន្ធបង្គន់ប្រើ ប្រាស់ ច្បាស់លាស់។

**ចំណាំ:** នៅជនបទជាពិសេស បង្គន់របស់គ្រួសារត្រូវបានសាងសង់ខាងក្រៅអាគារ ផ្ទះ។ ចូរចាត់ទុកថាវាជាបង្គន់នៅក្នុងផ្ទះ។

បង្គន់ដែលនៅឆ្ងាយពីផ្ទះជាធម្មតាជាប្រភេទបង្គនជំហរ។

**Q21 – ប្រភពនៃភ្លើងដែលត្រូវប្រើប្រាស់**

កំនតពីប្រភេទនៃប្រភពភ្លើងដែលគ្រួសារប្រើប្រាស់ច្រើនបំផុតនិងលេខកូដដ៏សមរម្យ ប្រភេទនៃការប្រើភ្លើងនិងលេខកូដរបស់វាដូចខាងក្រោម :

**1 -** អគ្គីសនីពីរដ្ឋាភិបាលហើយនិងប្រភពផ្សេងទៀត

**2 -** ម៉ាស៊ីនភ្លើង

**3 -** ទាំងអគ្គីសនីនិងម៉ាស៊ីនភ្លើង

**4 -** ប្រេងកាត

**5 -** ទាន

**6 -** ផ្សេងៗទៀត។ ចូរបញ្ជាក់

**Q22 – ប្រភេទឥប្រើសំរាប់ចំអិនអាហារ**

ចូរសួរអ្នកឆ្លើយពីប្រភេទនៃប្រេងឥន្ធនៈដែលគ្រួសារប្រើប្រាស់ប្រើនបំផុតពេលចំអិន។ ចូរគូសរង្វង់លើ លេខ កូដអោយបានសមរម្យ។ប្រសិនបើប្រភេទឥន្ធនៈនៃការចំអិនពីរច្រើនប្រភេទដែលត្រូវប្រើ ឧទាហរណ៍ អគ្គីសនី ហើយ LPG LPG ហើយនិងឈើ ប្រេងកាត ធ្យូង។ល។ ចូររាយការណ៏ពីឥន្ធនៈដែលត្រូវប្រើច្រើន បំផុតសំរាប់ ការចំអិន។

នេះជាប្រភេទនៃឥន្ធនៈដែលប្រើប្រាស់សំរាប់ចំអិនអាហារដូចខាងក្រោម :

**1 -** អុស

**2 –** ធ្យូងឧស

**3 -** ប្រេងកាត

**4 -** ហ្គាស

**5 -** អគ្គីសនី

**6 -** មិនមាន

**7 –** ផ្សេងៗទៀត សូមបញ្ជាក់

**Q23 – ប្រដាប់ប្រើប្រាស់ /ភាពជាទីគាប់ចិត្តដែលគ្រួសារមាន**

ចូរសួរអ្នកឆ្លើយអំពីប្រដាប់ប្រើប្រាស់ដែលក្រុមគ្រួសារមាន។ មិនត្រូវពឹងលើអ្វីដែលអ្នកឃើញ ព្រោះ ប្រ ហែល ជាប្រដាប់ប្រើប្រាស់ដូចជាវិទ្យុ ទូរទស្សន៏នៅក្នុងបន្ទប់គេង។ ចូរសួរសំណួរ

“តើក្រុម គ្រួសាមាន ភាពជាទី គាប់ចិត្តចំពោះប្រដាប់ប្រើប្រាស់រឺទេ?” បើមានសូមប្រមូលទិន្នន័យដោយគូស រង្វង់នៃ ជំរើស ចំ លើយដោយ ដាក់លេខកូដ ។ មិនរួមបញ្ចូលទាំងទូរទស្សន៍ វិទ្យុ ទូទឹកកក ទូរស័ព្ទ ម៉ូតូ ម៉ាស៊ីនភ្លើងដែល មិនអាចប្រើបានយូរតទៅទៀតហើយនឹងមិនត្រូវយកទៅជួសជុលដោយក្រុមគ្រួរសានោះទេ ។

**Q24 – ការផ្សព្វផ្សាយតាមសាពតិមាន /កាប្រជុំតាមសហគមន៏**

សួរចំលើយប្រាកដពីអ្នកផ្តលចំលើយថាតើសមាជិកក្នុងគ្រួសារអានកាសែត ស្តាប់វិទ្យុមើលទូរទស្សន៍ និងបាន ចូលរួមការប្រជុំក្នុងសហគមន៏ដោយសួរថា “តើកាលពីសប្តាហ៏មុនមានសមាជិកគ្រួសាររបស់អ្នក …... (ជំរើសនៃការប្រមូលទិន្នន័យ គូសលេខកូដនៃចំលើយបើឆ្លើយថាមាន) ?”.

**Q25 – ការទទួលបានសេវាកម្មផ្សេង១**

ចូរបញ្ជាក់បន្ថែមពីអ្នកឆ្លើយអំពីភាពងាយស្រួលក្នុងការទទួលសេវាកម្មផ្សេង១នៅក្នុងភូមិដូចជាទី (1) ការចូល រៀននៅ សាលាបឋមសិក្សា ទី(2) សេវាកម្មសុខភាពតាមគ្លីនិក ហើយទី (3) កាឆ្លងផ្លូវដែលជិតបំផុត ដោយឡាន ។ សំរាប់សេវាកម្មនីមួយ១ ចូរសួរអ្នកឆ្លើយថា : "តើមាន... (អ្នកប្រមូល ទិន្នន័យសំរាប់សេ វា កម្មនីមួយ១) នៅក្នុងភូមិរឺទេ?" ចូរដាក់លេខកូដ "1" បើមាន ហើយបើគ្មានចូរដាក់លេខកូដ "2" ។

**Q26 – ភាពងាយស្រួលនៃការទទួលសេវាកម្មប្រមូលទិន្នន័យ**

ចូរសួរបញ្ជាក់បន្ថែមពីអ្នកឆ្លើយថាតើសមាជិកខ្លះក្នុងក្រុមគ្រួសារបានទទួលមធ្យោបាយងាយស្រួលក្នុងនិងក្រៅភូមិដោយសួរថា : "តើសមាជិកណាខ្លះក្នុងគ្រួសាររបស់អ្នកបានទទួល............. (សេវាកម្មនៃការ ប្រមូល ទិន្នន័យ) រឺទេ?" បើមានចូរដាក់លេខកូដ "1" ក្រៅពីនេះដាក់លេខកូដ "2" ហើយដាក់សញ្ញា (-)នៅក្នុងសំណួរ Q27 ទៅ Q29 ហើយបន្តទៅសំណួរ Q30 ។

**Q27 - ចំងាយនៃការធ្វើដំណើរ**

ប្រសិនជាលេខកូដក្នុង Q26 គឺ "1" ចូរសួរអ្នកផ្តល់ចំលើយពីចំងាយដែលពួកគេធ្វើតាមទិសដៅរបស់គេ។ ចូរដាក់លេខកូដអោយបានត្រឹមត្រូវដូចខាងក្រោម :

**1** តិចជាង 1 គីឡូម៉ែត្រ

**2** 1 គីឡូម៉ែត្រ ដល់ 5 គីឡូម៉ែត្រ

**3** 5 គីឡូម៉ែត្រ រឺ ច្រើនជាងនេះ

**Q28 – ប្រភេទនៃការដំណើរ រឺ ដឹកជញ្ជូន**

ប្រសិនលេខកូដក្នុងសំណួរ Q26 គឺ "1" សូមសួរទៅអ្នកផ្តល់ចំលើយនូវប្រភេទនៃការធ្វើ ដំណើរ ទុកទៅ បំ ផុតដែលពួកគេប្រើប្រាស់។ ចូរដាក់លេខកូដអោយបានត្រឹមត្រូវនូវលេខដូចខាងក្រោម :

**1** ថ្មើរជើង

**2** ការជួលយាន / រទេះ ឯកជន

**3** ការជួលយាន / រទេះ

**4** ការធ្វើដំណើរតាមសាធារណៈ

**5** ផ្សេងៗទៀត

**Q29 - ពេលធ្វើដំណើរ**

ប្រសិនជាលេខកូដក្នុង Q26 គឺ "1" រឺ មាន, សួរគ្រួសារទៅអ្នកឆ្លើយថាតើវា ចំណាយពេល ប៉ុន្មាន ដើម្បី ទៅដល់កន្លែងដែលពួកគេចង់ទៅ។ ចូរកត់ត្រាពេលជានាទី។

**Q30 –ការកាន់កាប់ដី**

កំណត់ពីអ្នកផ្តល់ចំលើយថាតើពួកគេមានដីធ្លីកាន់កាប់រឺទេដោយសួរសំណួរថា : "តើអ្នកមាន ដីកាន់កាប់ផ្ទាល់ ខ្លួន ទេ?" ។ គូរវង្វង់លេខកូដ "1" សំរាប់មាន ហើយសួរ Q31 ទៅ Q34. ខុស ពីនោះគូរវង្វង់លេខកូដ "2" សំរាប់ទេ , ដាក់សញ្ញា (-) in Q31 ទៅ Q34 ហើយបន្តទៅសំនួរ Q35.

**Q31 - ប្រភេទដី**

ប្រសិនជាគូររង្វង់លេខកូដក្នុង Q30 គឺ "1", សួរអ្នកឆ្លើយនូវសំណួរខុសៗគ្នាពីប្រភេទដីដែលគេមាន។ នៅពេលដែលអ្នកឆ្លើយឆ្លើយពីប្រភេទដីដែលគេមាន សូមដាក់លេខកូដ 1 ក្នុង Q31ហើយសួរសំនួររំលង Q32

ទៅ Q34 ភ្លាម។ ប្រសិនចំម្លើយគឺទេ , សូមដាក់លេខកូដ 2 ក្នុង Q31 ហើយដាក់សញ្ញា (-)ក្នុង Q32-Q34 បន្តទៅសំនួរ Q35.

**Q32 - លក្ខណះនៃការកាន់កាប់ដី**

លក្ខណះនៃការកាន់កាប់ដីគួរតែត្រូវបានកត់ត្រានៅក្នុងពេលចុះសំភាសន៏លើកដំបូង ។ដូច្នេះសូម្បីតែគ្រួសារនោះជួលដីពីមុនមក ប៉ុន្តែបាន ទទួលដីរួច ហើយនៅ ពេលទៅសួរសំណួរទាំងនោះ បន្ទាប់មកទៀតក្រុមគ្រួសារ ត្រូវបាន រាយការណ៏ថាមានដីហើយមិនមែនជួលទេ។

ចូរបញ្ចូលលេខកូដទៅលើចំលើយនៅក្នុង លក្ខណះនៃការកាន់កាប់ដីដាក់លេខកូដដូចខាង

1 មានដីផ្ទាល់ខ្លួន / សងបំណុលបន្តិចម្តង – ក្រុមគ្រួសារគឺជាម្ចាសដីស្របច្បាប់ រួមបញ្ចូលទាំង ដី ដែលសងបំណុលបន្តិចម្តងរឺ ក៏ការបញ្ចាំ។

2 **ដីដែលជួល** – អ្នកកាន់កាប់ជាធម្មតាបង់ថ្លៃជួលជាប្រាក់សុទ្ធរឺជាអ្វីក៏បាន។

3 **កន្លែងនៅដោយមិនគិតប្រាក់** - ក្រុមគ្រួសារមានដី / គ្មានការអនុញ្ញាតិពីម្ចាស់ដី ហើយគ្មានការ បង់ថ្លៃឈ្នួលដល់ម្ចាស់ដីនោះឡើយ អ្នកជួលដី / អ្នកជួល។ ត្រូវបានបញ្ចូលក្នុងនេះដែរ អ្នកជួល ដីផ្សេងៗទៀតដែលមានផ្ទះជួលដោយមិនបង់ប្រាក់ /ជាពិសេសដីនេះជាកម្មសិទ្ធិរបស់ម្ចាស់ចំការ ហើយក៏ជានិយោជិកដែលត្រូវផ្តល់ដោយអោយរស់នៅក្នុងកសិដ្ឋានដែលមានរាងពហុកោណ ដែលមានអាគារ / ដី សាធារណៈ និងឯកជន ក៏ត្រូវបញ្ចូលនៅក្នុងផ្នែកនេះដែរ។

4 ម្ចាស់ដីដែលមិនសងបំណុល – គ្រួសារមានដីស្ថិតក្រោមការចចារបេស់រាជរដ្ឋាភិបាល។

បើចំលើយអ្នកឆ្លើយរបស់អ្នកឆ្លើយដាក់លេខកូដ "1" (ជាម្ចាស់/ សងបំណុលតិច) ចូរសួរសំណួរ Q33 និង Q34 បើមិនមែនលេខកូដដូចខាងលើទេចូរសួរតែសំណួរ Q34 បានហើយ។

**Q33 – ការកាន់កាប់ដីថ្មី**

សំណួរនេះគួតែសួរក្នុងករណីដែល ការកាន់កាប់ដីថ្មីក្នុងសំណួរ Q32ដែលដាក់លេខកូដ "1" រឺក៏ មានផ្ទាល់ ខ្លួន / សងបំណុលតិច។

ចូរសួរអ្នកឆ្លើយថា : "តើដីរបស់អ្នកមានការចេញផ្សាយពីក្រសួងឧស្សាហកម្មដាក់លេខកូដ "2"។ បើអ្នកឆ្លើយ មិនដឹងថាតើដីរបស់មានឯកសារត្រឹមត្រូវរឺអត់ចូរដាក់លេខកូដ "3" ។

**Q34 - ទំហំដី**

សំណួរនេះគួរតែត្រូវបានសួរអំពីប្រភេទដី ។

ចូរសួរសំណួរថា : "តើដីមានទំហំ.............. (ចូរលើកលើកឡើងពីប្រភេទដី)?" ។ ចូរដាក់លេខកូដដូច ខាងក្រោម :

| | |
|---|---|
| **1** | តិចជាង 1/2 ហិចតា |
| **2** | 1/2 ហិចតាទៅ 1 ហិចតា |
| **3** | 1 ទៅ 2 ហិចតា |
| **4** | ច្រើនជាន២ហិចតា |

**Q35 – ស្ថានភាពសេកិច្ចរបស់ក្រុមគ្រួសារ**

ពតិមានដែលអាចប្រមូលបាននឹងជាទិន្នន័យដ៏សំខាន់សំរាប់សំរាប់ការវិភាគតាមស្ថិតិ ។

ទិន្នន័យនឹងមានសារៈសំខាន់ ចំពោះ ការស្មានៃនគណនេយ្យជាតិ ។

ចូរបញ្ជាក់បន្ថែមថាតើនណានៅក្នុងផ្ទះធ្វើអាជីវកម្មការសន្មតនៅក្នុងគ្រួសារ សំណួរទាំងនោះសួរក្នុង Q35 ។ សួរទៅគ្រួ សារថា : "តើនណានៅក្នុងផ្ទះនេះធ្វើអាជីវកម្ម (ដូចជាការលក់ដូរ ការជួសជុល ការ ផ្តល់សេ វាផ្សេងៗ) រឺរបររកស៊ីមួយចំនួនទៀតដូចជាសិប្បកម្ម ការជួសជុល ការកាត់ដេរដើម្បីរក ចំនួល ដែររឺទេ?". ចូរដាក់លេខកូដ "1" បើមាន ហើយសួរសំនួរ Q36 ទៅ Q39 ។ ហើយបើមិនមានទេសូមដាក់លេខកូដ "2" រួចដាកសញ្ញា (-)នៅក្នុងសំណួរ Q36 ទៅ Q39 សួរសំណួរ Q40 ។

**Q35 – ចំនួនស្ថានភាពសេដ្ឋកិច្ចគ្រួសារ**

សំណួរនេះគួរតែត្រូវបានសួរ បើសមាជិកក្នុងគ្រួសារធ្វើអាជីវកម្មដើម្បីគ្រួសាររឺក៏ឆ្លើយសំនួរ Q35 ដែល មានដាក់លេខកូដ "1" ។ សួរទៅគ្រួសារថា : "តើក្នុងគ្រួសាមានអ្នករកស៊ីសំរាប់គ្រួសារដាច់ ដោយឡែក ប៉ុន្មាន". ពេលសួរសំណួរនេះ ត្រូវប្រាកថាមានការពន្យល់អំពីស្ថានភាពមុខរបរដល់អ្នកឆ្លើយផង ។

ចូរកត់ត្រានូវចំនួនស្ថានភាពសេដ្ឋកិច្ចគ្រួសារ ។ ចូរសំគាល់ថាស្ថានភាពមុខរបរក្នុងគ្រួរសារប្រហែលជា ទ្រព្យ សម្បត្តិផ្ទាល់ខ្លួន ចូលហ៊ុនគ្នា សហគ្រាសគ្មានការចូលហ៊ុនគ្នា រឺជាសាជីវកម្ម ។ ចូរសេរសេរ របាយ ការណ៏នេះនៅក្នុងបង្កាលនៃចំនួនអាជីវកម្មមិនមែនក្នុងសមាជិកអ្នកប្រតិបត្តិទេ ។ការធ្វើអាជីវកម្មប្រសដៀងគ្នារបស់បុគ្គលម្នាក់ក៏ចាត់ទុកថាការធ្វើអាជីវកម្មខុសៗគ្នាដែរ ។

**Q37 - Q39 –** ការរៀបរាប់ពីស្ថានភាពសេដ្ឋកិច្ច ឈ្មោះសមាជិកមេគ្រួសារ

នណាជាអ្នករកស៊ីចិញ្ចឹមគ្រួសារនិងនណាដែលមានការងារធ្វើ?

សំណួរទាំងនេះគួរតែសួរប្រសិនបើចំលើយក្នុងសំណួរ Q35 ត្រូវបានគូសលេខកូដ "1"។ ចូរសួរទៅ គ្រួសារអោយញែកកដាច់ពីគ្នាអំស្ថានភាពមុខរបរក្នុងគ្រួសារដូចជា : ភោជនីយដ្ឋាន ការលក់ដូរ ការកាត់ដេរ ត្បាញធ្វើគ្រឿងអលង្ការ ។ល ។ពេលដែលអ្នកឆ្លើយលើកឡើងពីស្ថានភាពគ្រួសារ ត្រូវសួរសំណួរ **Q38** (ឈ្មោះសមាជិក គ្រួសារដែលមានមុខរបរ) ហើយ **Q39** (ឈ្មោះមនុស្សដែលធ្វើការសំរាប់គ្រួសារ) ភ្លាម ។

**Q40 – លក្ខណៈឥនទាន**

ដើម្បីលក្ខណៈកំណត់ឥនទានត្រូវសួរទៅគ្រួសារថា " តើអ្នមានខ្ចីលុយដែររឺទេក្នុងឆ្នាំ 1994-1995?" ។ ចូរគូសនៅលើលេខកូដ "1" បើបានខ្ចីហើយសួរបន្តនូវសំណួរ Q41-Q54. បើមិនបានខ្ចីទេចូរគូសលេខកូដ "2" ហើយបន្តទៅសំណួរ Q55 ។

**Q41 – មូលហេតុក្នុងការខ្ចីលុយ**

សំណួរត្រូវសួរក្នុងករណីក្នុងពេលដែលគ្រួសារខ្ចីលុយក្នុងឆ្នាំ ១៩៩៤-១៩៩៥ រឺឆ្លើសំណួរ Q40 ថាបានខ្ចីត្រូវដាក លេខកូដ"1" ។

កំនត់ហេតុផលពីអ្នកផ្តល់ចំលើយដោយសួរថា " ហេតុអ្វីបានជាអ្នកខ្ចីលុយ?". ចូរគូសចំលើយដែលផ្តល់អោយ ចូរសំគាល់ថានេះគឺជាសំណួរពហុជ្រើសរើស ។

**Q42** ដល់ **Q50 - ប្រភព**

នេះជាសំណួរគួស្បេប្រេសិនជាចំម្លើយក្នុងQ40គឺ"1" ហើយបើនៅទីនោះគឺមានចំនួនតិចជាងមួយ គូរវង្វង់លេខកូដក្នុង Q41.

ចំពោះហេតូផលនីមួយៗ ចូរសួរអ្នឆ្លើយថាតើពួកគេបានខ្ចីលុយមកពីណា។ ចូរសួរថា “តើអ្នកខ្ចីលុយពី (ប្រភពនៃការសំភាសន៏ក្នុងសំនួរ Q42-Q50 រឺ)?” បើធានាគារដ្ឋាភិបាលជាប្រភពខ្ចីលុយ ចូរដាក់លេខកូដ "1" បើពិតមែន. បើមិនមែនជាប្រភពទេ សូមដាក់លេខកូដ "2" ។ ចូរធ្វើដូចគ្នាចំពោះធនាគាឯកជននានា អ្នកជិតខាងដែលអោយខ្ចីលុយ ពានិជ្ជករ សាច់ញាត្តិ មិត្ត អង្កការក្រៅរដ្ឋាភិបាល ។ល ។

**Q51 – ចំនួនដងនៃការខ្ចីលុយ**

សំនួរនេះគួរតែត្រូវសួរបើសិនចំលើយនៅក្នុងសំណួរ Q40 គឺដាក់លេខកូដ "1" ហើយយ៉ាងហោច ណាស់ក៏មានចំលើយមួយត្រូវគូសចំលើយក្នុងលលេខកូដនៃសំនួរ Q41 ។

ចូរសួរថា "តើអ្នកបានខ្ចីលុយប៉ុន្មានដង?" ចូរដាក់លេខកូដខាងក្រោមអោយបានត្រឹមត្រូវ ។

| | |
|---|---|
| **1** | ម្តង |
| **2** | ពីដង |
| **3** | បីដង |
| **4** | ច្រើនជាង៣ដង |
| **9** | មិនដឹង |

**Q52 – ចំនួនដែលខ្ចី**

ចូរសួរអ្នកឆ្លើយថា : " **តើអ្នកបានខ្ចីលុយប៉ុន្មាន**?" ចូរសរសេរចំនន្ទួនលុយជារៀល ។

**Q53 - អំឡុងពេលនៃការសង**

ចូរសួរថា : "តើអ្នកខ្ចីក្នុងរយះពេលប៉ុន្មាន?". ចូរដាក់លេខកូដអោយបានត្រឹមត្រូវដូចខាងក្រោម :

| | |
|---|---|
| **1** | តិចជាង ៦ ខែ |
| **2** | ៦ ខែ ទៅ ១ឆ្នាំ |
| **3** | ច្រើនជាង ១ ឆ្នាំ |

**Q54 - ចំនួនត្រូវសងវិញ**

ចូរសួរថា : "តើអ្នកនឹងសងវិញចំនួនប៉ុន្មានដែរ?" ចូរសរសេរជារៀល ។ បើសិនអ្នកឆ្លើយ មិនដឹងពីចំនួន ពិតទេ ចូរសួរដេម្បីទាយ រឺ ស្មាន ។

**Q55** ដល់ **Q57** – គ្រោះថ្នាក់ដែលកើតមានឡើងចំពោះក្រុមគ្រួសារ

ដើម្បីដឹងថាមានគ្រោះកើតឡើងចំពោះគ្រួសារ ត្រូវសួរអ្នកឆ្លើយថា "តើមាននណាខ្លះក្នុង គ្រួសាររបស់អ្នកមានការឈឺចាប់រាង្គកាយកាលពី ១២ខែមុននឹទេ?" ។ បើចំលើយថាមាន ចូរគូសលើលេខកូដ "1" ហើយសួរសំណួរបន្ទាប់ទៀត Q56 "តើគ្រោះថ្នាក់ប្រភេទអ្វី?" ហើយនៅក្នុងសំណួរ Q57 សួរថា "តើគាត់រស់ដែររឺទេ?" ។ បើចំលើយថាមានគូសលើលេខកូដ "2" ហើយបន្តទៅសំណួរ Q58 ។

សំរាប់ SESC ខាងក្រោមនេះគឺជាប្រភេទគ្រោះថ្នាក់ដែលកើតឡើង :

1 ការផ្ទុះមីន

2 ការផ្ទុះអាវុធដោយការឈ្លោះគ្នា

3 គ្រោះថ្នាក់ចរាចរ

4 ការរលៀកភ្លើងធ្ងន់ធ្ងរ (យ៉by fire/boiling liquid or food)

5 ការលិចលង់

6 ការឈឺចាប់ដោយសាសត្វពាហនៈ ពស់ពិស ឆ្កែខាំ

7 ធ្លាក់ពីលើអាគារ ដើមឈើ

8 ការពុល (ដោយជាតិគីមីនិងសាធាតុពុលផ្សេងៗទៀត)

9 ផ្សេងៗ

សំរាប់សំណួរ **Q57** គូសលេខកូដ "1" បើមនុស្សនោះបានរួចផុតពីគ្រោះថ្នាក់។ បើមិនដូច្នោះទេ ចូរគូសលេខកូដ "2" សំរាប់ការមិនផុតពីគ្រោះថ្នាក់។

**Q58 – ការស្វែងយល់អំពីការជ្រើសរើសកុមារអោយធ្វើការ**

ចូរសួរអ្នកឆ្លើយថា "តើអ្នកដឹងភ្លាមដែររឺទេចំពោះសហគមរបស់អ្នកដែលមានអាយុពី ៥-១៧ ឆ្នាំ ត្រូវបានគេជ្រើសរើសអោយធ្វើការ?" ចូរដាក់លេខកូដ "1" ប្រសិនបើឆ្លើយថាដឹង ហើយចូរសួរសំណួរ Q59 ទៅដល់ Q63។ បើមិនអញ្ចឹងទេត្រូវដាក់លេខកូដ "2" បើមិនដឹងហើយសូមបន្តទៅសំណួរ Q64។

**Q59 - អ្នកជ្រើសរើសកុមារធ្វើការ**

តាមការស្រាវជ្រាវរបស់អ្នកឆ្លើយ មនុស្ស រឺគ្រឹះស្ថានជាអ្នកជ្រើសរើសក្មេងធ្វើការ។ ចូរសួរសំនួរថា : “តើអ្នកទាំងនេះជាអ្នកជ្រើសរើសកូនរបស់អ្នកអោយធ្វើការរឺ?” បើឆ្លើយថាមែន ចូរគូសរង្វង់លើសជំរើសចំ លើយដែលបានផ្តល់អោយ។

**Q60 and Q61 - ប្រភេទការងារ**

ដើម្បីកំនត់ថាតើកុមារត្រូវគេជ្រើសរើសធ្វើការងារ ត្រូវសួរអ្នកឆ្លើយថា : "តើដឹងទេថាកុមារត្រូវ គេជ្រើសរើស អោយធ្វើការអ្វីខ្លះ?" ប្រសិនបើគេដឹង ចូរគូសរង្វង់លេខកូដ "1" ហើយសួរសំនួរ Q61 ថា "តើពួកគេត្រូវបានផ្តល់ការងារប្រភេទណា?" បើចំលើយថាមិនដឹងនៅក្នុងសំណួរ Q60 ចូរគូសលេខកូដ "2"

ហើយបន្តទៅសំណួរ Q64 ។ គោលបំណងនៃការអង្កេតនេះគឺអង្កេតលើការងារខុសៗគ្នាដែលកុមារត្រូវបានជ្រើសរើសអោយធ្វើការងារ :

1 រោងចក្រ

2 សំណង់អាគារ

3 រ៉ែ

4 ដំណាំ / កសិដ្ឋានបសុសត្វ

5 ការងារក្នុងស្រុក

6 ការកំសាន្ត

7 ផ្សេងៗទៀត

សូមគូសរង្វង់លេខសំងាត់លើចំលើយដែលផ្ទាល់ដោយអ្នកឆ្លើយនៅក្នុង Q61.

**Q62 & Q63 - កន្លែងធ្វើការ**

ស្វែងរកកន្លែងដែលក្មេងដែលត្រូវបានគេបញ្ជូនទៅហើយ Q62 គួរតែត្រូវបានសួរ ។ ចូរសួរអ្នកឆ្លើយថា " តើអ្នកដឹងថាក្មេងៗត្រូវបានបញ្ជូនទៅណា? " បើចំលើយឆ្លើយថា " ដឹង " ចូរគូសរង្វង់លើលេខកូដ " ១ " ហើយសូមសួរសំណួរ Q63 ថា: "តើពួកគេជាធម្មតាត្រូវបានបញ្ជូនទៅណា?" ហើយសរសេរទីកន្លែងដែលក្មេងត្រូវបានបញ្ជូនទៅ ។ បើចំលើយឆ្លើយថា" មិនដឹង " នៅក្នុងសំណួរ Q62, ចូរគូសវង្វង់លើលេខកូដ " ២ " ហើយបន្តទៅសំណួរ Q64 ។

**Q64 - Q66 – សុខាភិបាល**

ចូរសួរសំណួរ Q64 ថា “តើនណាម្នាក់នៅក្នុងផ្ទះនេះទទួលបាន កាចាក់ថ្នាំយ៉ាងហោចណាស់ ម្តងនៅក្នុងពិសបា្តហ៏មុនរួមទាំងប្រព័ន្ធភាពសុាំ " ចូរគូសលេខរង្វង់លើលេខកូដ 1 ប្រសិនបើបាន ប្រសិនបើចំលើយថាមិនបានចូរគូសលើលេខកូដ 2 ហើយបន្តទៅសំណួរ Q67 ។

សួរសំណួរ Q65 ថា “តើក្រុមគ្រួសារទទួលបានការចាក់ថ្នាំបង្កាប៉ុន្មានដងចំពោះបញ្ហាសុខភាព? (ជំរើស

នៃទិន្នន័យនេះត្រូវបានផ្តល់អោយនៅក្នុងបង្គាលហើយដាក់លេខអោយបានត្រឹមត្រូវចំពោះការចាក់ថ្នាំដែលបានទទួល” ។ សួរសំណួរ *Q66* “តើគ្រួសារទាំងនោះទទួលបានការចាក់ថ្នាំបង្កាពីណាមក*?*” ចូរគូសរង្វង់លើលេខកូដនៃចំលើយបានពីអ្នកឆ្លើយ ។

**Q67 - Q69** អំបិលអ៊ីយ៉ូត

ចូរផល់ពតិមានដល់អ្នកឆ្លើយដើម្បីអោយដឹងថាតើពួកគេប្រើប្រាស់អំបិលអ៊ីយ៉ូតឺរឺទេ ។

ចំលើយទាំងឡាយនៅក្នុងសំណួរ Q67-Q69 នឹងត្រូវបានកំណត់តាមរយះការអង្កេត ។

# សេចក្តីបន្ថែម A

## សញ្ញានៃទីតាំងភូមិសាស្រ្តនៅក្នុងផែនទី

ការតំរង់ទិស..........................................................................................

ព្រំដែននៅក្នុងខេត្ត...................................................................................

ព្រំដែននៅក្នុងភូមិ.................................................................................

ផ្លូវ (បញ្ជាក់ពីឈ្មោះ)................................................................

ស្ពាន........................................................................................................

ស្ទឹង / ព្រែក (បញ្ជាក់ពីឈ្មោះ)...............................................................

សាលា.......................................................................................................

ប្រាសាទ / ព្រះវិហារ.....................................................................

ផ្សារ........................................................................................................

វាលស្រែ...................................................................................................

ចំការពោត*..............................................................................................

ស្រះចិញ្ចឹមត្រី*.........................................................................................

ព្រៃ..........................................................................................................

អាគាររឺផ្ទះមួយ រឺ លើសពីមួយដែលកុំពុងរស់នៅ...................

អាគារដែលទំនេរ.....................................................

*បើវាលស្រែ ចំការពោត រឺ ស្រះចិញ្ចឹមត្រីពេញផែនទីហើយចូរសរសេរជំនួសវិញដូចជា "វាលស្រែ" ចំការពោត" "ស្រះចិញ្ចឹមត្រី" ធ្វើដូចគ្នាដែរសំរាប់កៅស៊ូ ដូង ស្ក ។ល ។